# ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

************************

## គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (M-IWRMP): កម្ពុជា

# គម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF)

ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១០

# អារម្ភកថា

ឯកាសារនេះត្រូវបានចាត់ទុកថាជា គំរោងគោលនយោបាយនៃការតាំងទីលំនៅឡើងវិញ (RPF) សំរាប់ប្រទេសកម្ពុជា។ វាត្រូវបានបង្កើតស្ថិតលើមូលដ្ឋានដែលចេញពី ការត្រួតពិនិត្យសង្គម និង បរិស្ថានជំហានដំបូង(IESE) ដែលចាត់ទុកជាឯកសារដាច់ដោយឡែកមួយ។ វាត្រូវបានភ្ជាប់ទៅនឹង គ្រឿងបរិក្ខារជំនួយទូទៅ ជាពិសេសគឺ ភ្ជាប់ទៅនឹងគំរោងគ្រប់គ្រងសង្គម និង បរិស្ថាន (ESMF) សំរាប់ការគ្រប់គ្រងធនធានទឹកចំរុះទន្លេមេគង្គ (M-IWRM) សំរាប់ប្រទេសកម្ពុជា។ គំរោងនេះ នឹងត្រូវបានអនុវត្តជាមួយនឹងការវិនិយោគទាំងអស់ ដែលត្រូវបានផ្តល់ថវិការដោយ ធនាគារពិភពលោកសំរាប់ការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេស តាមរយៈគំរោង M-IWRM សំរាប់ប្រទេសកម្ពុជាដែលពាក់ពន្ធ័ជាមួយនឹងការកាន់កាប់ដីធ្លី សំណង និង ការដាក់កំរិតទៅលើលទ្ធភាពប្រើប្រាស់ធនធាន ដែលត្រូវបានកំណត់ដោយ គោលនយោបាយគាំពាររបស់ធនាគារពិភពលោកស្តីពីការរើទីលំនៅដោយគ្មានការជ្រើសរើស(OP 4.12)។

អង្គភាពគ្រប់គ្រងគំរោងថ្នាក់ជាតិ (PMU) នៃរដ្ឋបាលជលផល (FiA) នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ (MAFF) ដែលទទួលបន្ទុកសំរាប់ការគ្រប់គ្រងទាំងអស់សំរាប់ការងារក្នុងប្រទេសកម្ពុជា ហើយអង្គភាពអនុវត្តគំរោងដែលពាក់ពន្ធ័ (PIUs) នៃ FiA ដែលទទួលបន្ទុកសំរាប់ការអនុវត្តន៍ នៃសមាភាពរងជាក់លាក់ គឺទទួលបន្ទុកសំរាប់ធ្វើការធានានូវការស្របទៅតាម RPF ដោយរួមមានការរក្សាទុកនូវឯកសារត្រឹមត្រូវនៅក្នុងសំនុំឯកសាររបស់គំរោង សំរាប់ ការត្រួតពិនិត្យឡើងវិញដោយធនាគារពិភពលោក។

ឯកសារនេះចាត់ទុកជា ឯកសាររស់ ហើយអាចត្រូវបានផ្លាស់ប្តូរ និង កែប្រែទៅស្ថានភាពប្រែប្រួល និង ទំហំនៃការងារ។ ការពិគ្រោះយោបល់ជិតស្និទ្ធជាមួយនឹងធនាគារពិភពលោក និង ការងាររបស់គំរោងគោលនយោបាយនៃការតាំងទីលំនៅឡើងវិញគឺមានសារៈសំខាន់។

## មាតិការ

ទំព័រ

**ផ្នែកទី១: សេចក្តីផ្តើម ....................................................................................................................................៣**

**ផ្នែកទី២: ការពណ៌នារបស់គំរោង .........................................................................................................................៣**

**ផ្នែកទី៣: គំរោងគោលនយោបាយនិងគំរោងស្របច្បាប់សំរាប់គំរោង RPF ..................................................................៥**

៣.១ ច្បាប់រដ្ឋាភិបាល ក្រិត្យ និង គោលការណ៍ណែនាំ ...............................................................................................៥

៣.២ គោលនយោបាយធនាគារពិភពលោកស្តីពីការរើលំនៅដ្ឋានឡើងវិញដោយមិនស្មគ្រ័ចិត្ត ....................................៦

**ផ្នែកទី៤: ដំនើរការរបស់គំរោង RPF និង ដំនើរការគាំពារសង្គមសំរាប់ M-IWRM ...............................................៧**

៤.១ កិច្ចគាំពារសង្គម ......................................................................................................................................៧

៤.២ គំរោងគោលនយោបាយសំរាប់ការកាន់កាប់ដីធ្លី និង សំណង ...................................................................................៨

១. គោលការណ៍ទូទៅ ...................................................................................................................................៨

២. សំណង និង ការផ្តល់សិទ្ធិ .........................................................................................................................៩

៣. ការពិនិត្យពិច័យពិសេស ..........................................................................................................................៩

៤. កិច្ចដំនើរការនៃការអនុវត្តន៏ ...................................................................................................................១០

៥. ការរៀបចំសំរាប់ផែនការការងាររើលំនៅស្ថានឡើងវិញ (RAP) ..........................................................................១១

៤.៣ គំរោងគោលនយោបាយសំរាប់ការដាក់ក៏រិតទៅលើលទ្ធភាពទាញយកធនធាន ..................................................១២

១. គោលការណ៍ទូទៅ .................................................................................................................................១២

២. ដំនើរការនៃការអនុវត្តន៏ ..........................................................................................................................១២

៤.៤ សេចក្តីប្រកាសពតិមាន និង ការត្រួតពិនិត្យ ....................................................................................................១៣

៤.៥ តម្លាភាព និង យន្តការណ៏សារទុក្ខ ...................................................................................................................១៤

**បញ្ជីនៃឧបសម្ពន្ធ័**

ឧបសម្ពន្ធ័ទី១: គោលការណ៏ណែនាំបច្ចេកទេសនៅពេលការកាន់កាប់ដីធ្លី សំណង និង វិភាគទានស្មគ្រ័ចិត្ត ត្រូវការសំរាប់ការងារវិនិយោគ និង គំរោងរង ....................................................................................................................១៧

ក១.១ និយមន័យនៃពាក្យបច្ចេកទេស ...................................................................................................................១៨

ក១.២ តំរូវការមូលដ្ឋានសំរាប់គោលនយោបាយគាំពារសង្គមរបស់ធនាគារពិភពលោក .................................................១៩

ក១.៣ សំណង និង ការផ្ដល់សិទ្ធិកាន់កាប់ ....................................................................................................២០
ក. សិទ្ធិទទួលបាន ....................................................................................................................២០
ខ. ការផ្ដល់សិទ្ធិកាន់កាប់ ...........................................................................................................២០
គ. ការផ្ដល់វិភាគទានដោយស្មគ្រ័ចិត្ត ...........................................................................................២៤
ឃ. ការតាំងទីលំនៅជាថ្មី និង យុទ្ធសាស្រ្តប៉ះប៉ូវប្រាក់ចំណូលឡើងវិញ ...........................................២៤
ង. ភាពងាយរងគ្រោះ យែនឌ័រ និង ក្រុមជនជាតិ .........................................................................២៥
ច. ក្រុមមនុស្សជនជាតិដើម ........................................................................................................២៥
ក១.៤ ការអនុវត្តន៍ និង ការរៀបចំសំរាប់គំរោងការងារនៃការតាំងទីលំនៅឡើងវិញ ...................................២៦
ក១.៥ ការពិគ្រោះសហគមន៍ និង ដំនើរការដែលពាក់ពន្ធ័ .........................................................................២៧
ក១.៦ យុទ្ធសាស្រ្តយែនឌ័រ ....................................................................................................................២៩
ក១.៧ ការប៉ះប៉ូវជំងឺចិត្ត .......................................................................................................................៣៤
ក១.៨ ការត្រួតពិនិត្យតាមដាន និង ការវាយតំលៃ ...................................................................................៣៦
ក១.៩ គោលនយោបាយរបស់ធនាគារពិភពលោកសំរាប់ការពិគ្រោះសាធារណៈ និង ការផ្សព្វផ្សាយពតិមាន .......៣៨
ឧបសម្ពន្ធ័ទី ២: បែបបទនៃបញ្ជីគាំពារសង្គម ..............................................................................................៤១
ឧបសម្ពន្ធ័ទី ៣: មាទ្រីកនៃពតិមានសង្ខេបស្ដីពីហេដ្ឋារចនាសម្ពន្ធ័ និង ដីធ្លីដែលរងផលប៉ះពាល់ ................................៤២
ឧបសម្ពន្ធ័ទិ ៤: មាតិកានៃ RAP ...............................................................................................................៤៣
ឧបសម្ពន្ធ័ទី ៥: គំរោងសង្ខេបសំរាប់ផែនការការងារនៃការតាំងទីលំនៅឡើងវិញ ..................................................៤៣
ឧបសម្ពន្ធ័ទី ៦: ពតិមានដែលត្រូវការសំរាប់ការរៀបចំនៃ IPDR ......................................................................៤៥
ឧបសម្ពន្ធ័ទី ៧: ការគាំពារជាបឋមសំរាប់ប្រជាជនក្នុងស្រុក .. .........................................................................៤៦

## ផ្នែកទី១: សេចក្តីផ្តើម

*១.* គោលបំណងនៃការគ្រប់គ្រងជលផលកម្ពុជា ត្រូវបានតំរែតំរង់ជាមួយនឹងគោលដៅអភិវឌ្ឍន៍គំរោងសំរាប់ការគ្រប់គ្រងធនធានទឹករួមទន្លេមេគង្គ(M-IWRM) ដែលការពណ៌នាសង្ខេបស្តីពីគំរោងត្រូវបានបង្ហាញនៅក្នុងផ្នែកទី២។ ការងារសំរាប់ប្រទេសកម្ពុជា នឹងត្រូវបានដាក់កំរិតសំរាប់សមាសភាព៣-២ ហើយវាអាចពាក់ពន្ធ័ទៅនឹងកម្មសិទ្ធិដីធ្លី ការបរិច្ចាគដីធ្លី និង ការដាក់កំរិតលើលទ្ធភាពទាញយកធនធាន។ សមាសភាពរងក្នុងប្រទេសកម្ពុជា នឹងត្រូវបានអនុវត្តតាមរយៈសកម្មភាពដូចខាងក្រោមៈ

- ធ្វើការផ្គត់ផ្គង់សំរាប់សហគមន៍នេសាទ រួមបញ្ចូលនូវៈ (ក) ការកសាង ការចុះបញ្ជី និង ការពង្រឹងអង្គភាពសំរាប់ជលផលសហគមន៍ (CFi), (ខ) ធ្វើការដាក់ការគ្រប់គ្រងជលផលទៅក្នុងដំនើរការនៃគំរោងអភិវឌ្ឍន៍សហគមន៍នេសាទ(គំរោងអភិវឌ្ឍន៍ឃុំ) (គ) ធ្វើការផ្តល់អោយសហគមន៍នេសាទនូវឱកាសចិញ្ចឹមជីវិតសំខាន់ៗ
- ធ្វើការផ្គត់ផ្គង់ដល់វិស័យសាធារណៈ ជាពិសេសសំរាប់ FiA ថ្នាក់ខេត្ត និង ស្រុក ដើម្បីធានានូវសមត្ថភាពវិស័យសាធារណៈនៅក្នុងការឃ្លាំមើលទៅលើការអនុវត្តន៏នៃផែនការគ្រប់គ្រងជលផល ទៅលើការត្រួតពិនិត្យតាមដានលើការនេសាទត្រី ទៅលើការលើកស្ទួយនៃជលវប្បកម្ម និង ទៅលើការស្តារឡើងវិញនៃពូជត្រីក្នុងស្រុកសំខាន់ៗ។

*២.* ទំហំនៃការងារក្នុងប្រទេសកម្ពុជាគឺគ្របដណ្តប់ទៅលើខ្សែទឹកកណ្តាលនៃទន្លេមេគង្គ ពីព្រំដែនប្រទេសកម្ពុជាឡាវទៅខេត្តស្ទឹងត្រែង និង ខេត្តក្រចេះ។ តំបន់នេះត្រូវបានដឹងថាជាជំរកដ៏សំខាន់បំផុតមួយ(ជាពិសេសសំរាប់ត្រីដែលភៀសខ្លួនក្នុងកំឡុងពេលរដូវប្រាំង និង រដូវត្រីពង)សំរាប់ពូជត្រីជាច្រើនដែលផ្លាស់ទីក្នុងចំងាយដ៏វែង ដោយរួមមានពូជត្រីដែលជិតផុតពូជដូចជា ត្រី Panagasius Krempfi និង ត្រី Pangasianodon Gigas និង ថនិកសត្វដ៏សំខាន់ដូចជា ផ្សោត(ដូហ្វីនទឹកសាប)។វាត្រូវបានគេដឹងថា តំបន់នេះត្រូវបានតាំងទីលំនៅដោយប្រជាជនក្នុងស្រុក ហើយវាអាចជះឥទ្ធិពលដល់ពួកគេ(ជាវិជ្ជមាន និង អវិជ្ជមាន)ដោយគំរោងនេះ។

*៣.* ដើម្បីជៀសវាងនូវផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរ ដោយសារតែ កម្មសិទ្ធិដីធ្លី ការបរិច្ចាគដីធ្លី និង ការដាក់កំរិតទៅលើលទ្ធភាពដើម្បីទាញយកធនធាន និង ដើម្បីអនុវត្តនតាមគោលនយោបាយគាំពាររបស់ធនាគារពិភពលោក(WB)ស្តីពីការតាំងទីលំនៅឡើងវិញ (OP 4.12) គំរោងគោលនយោបាយនៃការតាំងទីលំនៅឡើងវិញ (RPF)ត្រូវបានបង្កើត ហើយវានឹងត្រូវបានអនុវត្តជាមួយនឹងគ្រប់ការងារទាំងអស់នៃ M-IWRM ដើម្បីត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា។សំរាប់សកម្មភាព និង គំរោងរងថ្មីដែលត្រូវបានកំណត់ភិនភាគក្នុងកំឡុងពេលអនុវត្តន៏ កិច្ចដំនើរការនៃកិច្ចការការពារសុវត្ថិភាព

ដូចដែលត្រូវបានកំណត់នៅក្នុងគំរោងគ្រប់គ្រងសង្គម និង បរិស្ថាន(ESMF) និងបញ្ជីត្រួតពិនិត្យសង្គម(ឧបសម្ព័ន្ធទី២) នឹងត្រូវបានអនុវត្ត ហើយកំណត់ត្រានឹងត្រូវបានរក្សាទុកនៅក្នុងសំណុំឯកសាររបស់គំរោង សំរាប់ការត្រួតពិនិត្យពេលក្រោយដោយធនាគារពិភពលោក។

*៤.* ផ្នែកទី២ខាងក្រោមគឺបរិយាយពីគំរោង កំឡុងពេលដែលផ្នែកទី៣បរិយាយពីគំរោងគោលនយោបាយ និង គំរោងស្របច្បាប់សំរាប់ RPF ហើយ ឧបសម្ព័ន្ធទី១ ផ្តល់នូវគោលការណ៍ណែនាំផ្នែកបច្ចេកទេស ដោយរួមបញ្ចូលនូវទំហំសំរាប់ការរៀបចំសំរាប់ផែនការការងារនៃការតាំងទីលំនៅឡើងវិញ(RAP)ដែលនឹងត្រូវការ ប្រសិនបើការកាន់កាប់ដីធ្លី និង សំណងត្រូវបានពាក់ពន្ធ័។ ផ្នែកទី៤ បរិយាយអំពី កិច្ចដំនើរការអនុវត្តន៏ និង គោលការណ៏មូលដ្ឋានសំរាប់ RPF ដើម្បីអនុវត្តជាមួយនឹង M-IWRM(គំរោង) សំរាប់សកម្មភាពក្នុងប្រទេសកម្ពុជា ដោយរួមបញ្ចូលនូវការងារដែលត្រូវបានរ៉ាប់រងក្នុងកំឡុងពេលនៃការអនុវត្តន៏។

## ផ្នែកទី២ ការពណ៌នាពីគំរោង

***៥. គំរោង M-IWRM*** មានបំណងដើម្បីបង្កើតនូវគំរូសំខាន់ៗក្នុងការអនុវត្តន៏លើការគ្រប់គ្រងធនធានទឹករួម(IWRM) នៅក្នុងអាងស្តុកទឹកទន្លេមេគង្គក្រោម(LMB) នៅក៏រិតថ្នាក់ជាតិ ថ្នាក់ជាតិរង និង ថ្នាកតំបន់។ ការងារជាច្រើននឹងត្រូវបានអនុវត្តតាមរយៈសមាសភាពបីដូចខាងក្រោមៈ

***សមាសភាព១: ការគ្រប់គ្រងធនធានទឹកថ្នាក់តំបន់*** គោលបំណងនៃសមាសភាពនេះគឺដើម្បីបង្កើននូវកិច្ចពិភាក្សា កិច្ចសហការណ៏ និង ការយល់ដឹងស្តីពី គោលការណ៏នៃ IWRM ក្នុងចំណោមប្រទេសក្នុងតំបន់ LMB ។ ការងារសំខាន់ៗរួមមានជំនួយខាងផ្នែកបច្ចេកទេស ការកសាងសមត្ថភាព កិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា ហើយមិនទំនងជាមិនបង្កបញ្ហាដល់គោលនយោបាយគាំពាររបស់ធនាគារពិភពលោកឡើយ។

***សមាសភាព២ ការគ្រប់គ្រងធនធានទឹកថ្នាក់ជាតិ*** គោលបំណងសំខាន់គឺត្រូវតែជួយគាំទ្រ IWRM នៅក្នុងសាធារណៈរដ្ឋប្រជាមានិតឡាវដែលរ៉ាយរ៉ាប់ពីលំហូរទឹកក្នុងអាងស្តុកទឹកដែលមានចំនួនជាង៣០ភាគរយ។ការងារសំខាន់ៗ នឹងរួមមានជំនួយខាងផ្នែកបច្ចេកទេស កិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា និង សកម្មភាពកសាងសមត្ថភាពដ៏ទៀត ដូចជា គ្រឿងបរិក្ខារ យាន្តជំនិះ និង ការជួសជុលឡើងវិញនៃការិយាល័យ និង អគារតូចៗ ហើយវាមិនទំនងជានឹងបង្កបញ្ហាដល់គោលនយោបាយគាំពាររបស់ធានាគារពិភពលោកឡើយ។

***សមាសភាព៣: លើកស្ទួយតំបន់ងាយជន់លិច និង ការគ្រប់គ្រងធនធាននៃភាវមានជីវិតក្នុងទឹកនៅក្នុងតំបន់សំខាន់ៗក្នុងតំបន់*** សមាភាពនេះមានបំណងដើម្បីបង្ហាញនូវ ការអនុវត្តន៏ដ៏ជោគជ័យសំរាប់ការអនុវត្តនៃ IWRMចំពោះ (ក) ការគ្រប់គ្រងតំបន់ងាយជន់លិចនៅក្នុងអាងស្តុកទឹកទន្លេដែលត្រូវបានជ្រើសរើស នៅក្នុងប្រទេសឡាវ និង (ខ) ការអភិវឌ្ឍន៏នៃការគ្រប់គ្រងជលផលឆ្លងដែន នៅក្នុងតំបន់អទិភាពនៃសាធារណៈរដ្ឋប្រជាមានិតឡាវ និង ប្រទេសកម្ពុជា។ ការងារនឹងត្រូវបានអនុវត្តតាមរយៈសមាសភាពរង៣ដូចខាងក្រោម:

៣.១ ការគ្រប់គ្រងតំបន់ងាយជន់លិច និង អាងស្តុកទឹកទន្លេនៅក្នុងផ្នែកខាងក្រោមនៃ ខេត្ត Xa Bang Fai(XBF) និង ខេត្ត Xe Bang Hian(XBH) នៅក្នុងសាធារណៈរដ្ឋប្រជាមានិតឡាវ ការងារគន្លឹះរួមមាន:

៣.១.១ ធ្វើការគាំទ្រដល់ការអភិវឌ្ឍន៏នៃអង្គការណ៏អាងស្តុកទឹកទន្លេ និង គំរោងនៃការរៀបចំអាងស្តុកទឹក ដែលផ្តោតទៅលើ "តំបន់ងាយរងគ្រោះ" ការអភិវឌ្ឍន៏នៃគំរោងគ្រប់គ្រងតំបន់ងាយជន់លិចសំរាប់ផ្នែកខាងក្រោមនៃខេត្ត XBF និង ខេត្ត XBH ដោយផ្តោតទៅលើចំនុចប្រសព្វរវាងដៃទន្លេ និង ទន្លេមេគង្គកណ្តាល។ គំរោងនឹងផ្តត់ផ្គង់ជាជំនួយបច្ចេកទេស ការបណ្តុះបណ្តាល និង គ្រឿងបរិក្ខាររាយរង និង ការជួសជុលការិយាល័យ។

៣.១.២ ធ្វើការស្តារឡើងវិញនូវ ច្រកទ្វារទឹកដែលមានស្រាប់ដើម្បីស្តារឡើងវិញនូវការគ្រប់គ្រងតំបន់ងាយជន់លិច និង ចរាចរណ៏ត្រី នៅលើផ្ទៃដី ១៤០០០ហិចតា ហើយការស្តារឡើងវិញនៃហេដ្ឋារចនាសម្ពន្ធ័ធារាសាស្ត្រ ដើម្បីគាំទ្រដល់ការសង្គ្រោះនៃកសិកម្មក្នុងតំបន់ងាយលិចទឹក និង តំបន់ត្រីពងលើផ្ទៃដី ៨៥០០ហិកតា ដោយធ្វើការផ្តល់នូវការគាំទ្រដើម្បីលើកស្ទួយនូវប្រពន្ធ័កសិកម្មតាមរយៈការងារស៊ីវិល គ្រឿងបរិក្ខារផ្សេងៗ និង ការផ្គត់ផ្គង់ជាការសាងសង់ផ្សេងៗ។

៣.១.៣ ធ្វើការផ្តល់នូវការផ្គតផ្គង់ផ្នែកសំភារៈទៅអោយរដ្ឋបាលថ្នាក់ខេត្តនៃ WREA និង ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ(នាយកដ្ឋានជលផល និង ធារាសាស្ត្រ)សំរាប់ការអនុវត្តសមាសភាពរង។

*៣.២ ការគាំទ្រសំរាប់ការគ្រប់គ្រងនៃធនធានភាវមានជីវិតនៅក្នុងទឹកនៅក្នុងសាធារណរដ្ឋប្រជាមានិតឡាវ និង ប្រទេស កម្ពុជា* ដែលធ្វើការស្វែងរកនូវតំបន់សំរាប់ត្រីពងដ៏ល្អបំផុតសំរាប់ទន្លេមេគង្គ ហើយការងារគន្លឹះរួមមាន:

៣.២.១ ធ្វើការផ្គត់ផ្គង់ដល់អង្គការណ៏គ្រប់គ្រងជលផលសហគមន៏នៅក្នុងខេត្ត Champasak Attapeu Sekong (ប្រទេសឡាវ) និង ខេត្តស្ទឹងត្រែង និង ខេត្តក្រចេះ(ប្រទេសកម្ពុជា)ដោយរួមបញ្ចូលនូវការអភិវឌ្ឍន៏នៃផែនការគ្រប់គ្រងដែលពាក់ពន្ធ័ ការបណ្តុះបណ្តាលស្តីពីការអភិរក្ស និង គ្រប់គ្រងជលផល ការអភិវឌ្ឍន៏ និង ការអនុវត្តន៏នៃរបរចិញ្ចឹមជីវិត និងផែនការអភិវឌ្ឍន៏ឃុំ ដោយរួមមានការឧបត្ថម្ភដល់ហេដ្ឋារចនាសម្ពន្ធ័ជនបទ។គំរោងនឹងផ្តល់នូវការបណ្តុះបណ្តាល ការបង្កើតនៃយន្តការណ៏សារទុក្ខ សេវាផ្ទាល់សំរាប់សហគមន៏ ការចំនាយទៅលើកិច្ចដំនើរការ ឧបករណ៏ និង ការងារស៊ីវិលរាយរង។

៣.២.២ ធ្វើការពង្រឹងដល់ការគ្រប់គ្រងជលផលសាធារណៈសំរាប់ ស្ថាបន័ជលផលថ្នាក់ស្រុក និង ថ្នាក់ខេត្តនៅក្នុង (ក) ការប្រមូលទិន្នន័យ ការត្រួតពិនិត្យ និង បទបញ្ញត្តិស្តីពីការនេសាទ ដែលរួមបញ្ចូលជាមួយនឹងអង្គការណ៏ជលផល

សហគមន៍ (ខ) ការងារសាងសង់ផ្សេងៗ (គ) ការឧបត្ថម្ភសំរាប់ជលវប្បកម្ម និង ការស្តុកទុកនៃពូជសត្វក្នុងស្រុកតាមរយៈការស្តារឡើងវិញនៃកន្លែងភ្ញាស់ពងត្រី ជំនួយខាងផ្នែកបច្ចេកទេស និង ការចុះកម្មសិក្សាសំរាប់អ្នកនេសាទ។ គំរោងនេះនឹងផ្តល់ជាថវិការសំរាប់ការចំណាយលើ កិច្ចដំនើរការ ការបណ្តុះបណ្តាល ការងារ និង សំភារៈផ្សេងៗទៀត។

៣.២.៣ ធ្វើការផ្តល់នូវការផ្គត់ផ្គង់ជាភស្តុភារសំរាប់ការគ្រប់គ្រងសមាសភាព ទៅអោយនាយកដ្ឋានជលផល នៅក្នុង ខេត្ត Pakse Champasak (ប្រទេសឡាវ) និង ទីក្រុងភ្នំពេញ( ប្រទេសកម្ពុជា) ដោយរួមបញ្ចូលនូវការចំណាយសំរាប់កិច្ចដំនើរការ និង ការជួលជុលឡើងវិញនៃការិយាល័យតូចៗ។

***៦.*** M-IWRM គឺជាគំរោងថ្នាក់តំបន់ ដែលនឹងត្រូវបានអនុវត្តសំរាប់រយៈពេលជាង៦ឆ្នាំ(២០១១-២០១៦)គណៈកម្មការទន្លេមេគង្គ (MRC) តាមរយៈលេខាធិការដ្ឋានរបស់ខ្លួន នឹងអនុវត្តការងារសំរាប់សមាសភាព១ កំឡុងពេលដែលទីភ្នាក់ងារនៅក្នុងប្រទេសឡាវដែលស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋបាលបរិស្ថាន និង ធនធានទឹក(WREA) នឹងធ្វើការអនុវត្តការងារសំរាប់សមាសភាព២ និង សមាសភាពរង៣.១។ នាយកដ្ឋានបសុសត្វ(DLF)នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ (MAF) និង ការិយាល័យថ្នាក់ខេត្តរបស់ខ្លួន នៅក្នុងខេត្ត Champasak Sekong nig Attapeu នឹងធ្វើការអនុវត្តការងារសំរាប់សមាសភាពរង៣.២សំរាប់ការងារក្នុងប្រទេសឡាវ ។រដ្ឋបាលព្រៃឈើ(FiA)នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ(MAFF)នឹងធ្វើការអនុវត្តការងារសំរាប់សកម្មភាពនៅក្នុងប្រទេសកម្ពុជាដោយស្ថិតនៅក្រោម សមាសភាពរង ៣.២។

## ផ្នែកទី៣: គម្រោងគោលនយោបាយ និង គំរោងស្របច្បាប់នៃការតាំងទីលំនៅដ្ឋានឡើងវិញ (RPF)

### ៣.១ ច្បាប់រដ្ឋាភិបាល ក្រិត្យ និងគោលការណ៍ណែនាំ

***៧.*** រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០១ ស្តីពីច្បាប់ដីធ្លីបានបង្កើតនូវយន្តការ ដែលហៅកាត់ថាដីសម្បទានសង្គមកិច្ច (Social Land Concession) ដើម្បីប្រគល់ផ្នែកខ្លះៗនៃដីរបស់រដ្ឋទៅដល់ក្រុមគ្រួសារប្រជាពលរដ្ឋក្រីក្រ រឺអត់ដីក្នុងគោលបំណងធ្វើកសិកម្ម និងតាំងលំនៅដ្ឋាន។ កម្មវិធីដីសម្បទានសង្គមកិច្ចនៅតាមមូលដ្ឋានត្រូវបានផ្តួចផ្តើមឡើងនៅថ្នាក់ឃុំ ខណៈដែលកម្មវិធីដីសម្បទានសង្គមកិច្ចជាតិពាក់ព័ន្ធទៅនឹងប្រតិបត្តិការដែលមានលក្ខណៈទ្រង់ទ្រាយធំ ។វត្ថុបំរុងគន្លឹះដែលពាក់ពន្ធ័រួមមាន:

-ច្បាប់ស្តីពីដីធ្លីឆ្នាំ ២០០១ ចែងថា គ្មានបុគ្គលណាម្នាក់នឹងត្រូវបាន "ដកហូតនូវភាពម្ចាស់របស់ពួកគេ លើកលែងតែសកម្មភាពនេះគឺសម្រាប់ផលប្រយោជន៍សាធារណៈ" ។ ច្បាប់ទទួលស្គាល់ថា ការដកហូតភាពជាម្ចាស់ដើម្បី ផ្តល់សិទ្ធិទៅដល់ "ប្រាក់ចំណាយនៃសំណងមានលក្ខណៈសមរម្យ" ។ រដ្ឋធម្មនុញ្ញចែងថា "សិទ្ធិដើម្បីដកហូតភាពជាម្ចាស់ពីអ្នកណាម្នាក់គួរ

ត្រូវបានប្រើតែនៅក្នុងផលប្រយោជន៍សាធារណៈ” និងសិទ្ធិបើកចំហទៅលើសំណង។ ទោះជាយ៉ាងណាបច្ចុប្បន្នមិនមានបទបញ្ជា និងច្បាប់នានាដែលដឹកនាំនូវដំណើរការនៃការកំណត់ និងការទទួលយកនូវសំណងនោះទេ។

-ច្បាប់ស្តីពីដីធ្លីនៅក្នុងឆ្នាំ ២០០១ បានចង្អុលបង្ហាញនូវបន្ទាត់មួយយ៉ាងច្បាស់រវាងដីទាំងនោះដែលបើកជាចំហសម្រាប់ការ តាំងលំនៅដ្ឋាន រឺដីសម្រាប់ធ្វើកសិកម្មនៅមុនខែកក្កដា ឆ្នាំ ២០០១ និងដីទាំងនោះដែលបានតាំងលំនៅដ្ឋានរឺគោលបំណង ធ្វើ កសិកម្មមុនថ្ងៃ ខែ ឆ្នាំកំណត់នេះ។ ករណីជាបឋម អ្នកកាន់កាប់ដីមួយចំនួនអាចត្រូវបានទទួលស្គាល់ថាជាអ្នកកាន់កាប់ ដីស្របច្បាប់លើដីរបស់រដ្ឋនាពេលអនាគត់ នៅពេលដែលដីត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ក្នុងករណីទី ២ អ្នកកាន់ កាប់ដីគឺខុសច្បាប់។ មាត្រាទី ១៨ នៃច្បាប់ស្តីពីដីធ្លីផ្តល់នូវវិធីសាស្ត្រដ៏រឹងមាំដើម្បីបណ្តេញនូវអ្នករាន្តដីខុសច្បាប់។ ពួក គេ ” មិនមានសិទ្ធិដើម្បីទាមទារសំណង រឺក៏ការចំណាយសងមកវិញសម្រាប់ការគ្រប់គ្រង រឺថែរក្សានូវអចលនៈទ្រព្យដែលទទួល បានដោយខុសច្បាប់ ” (មាត្រាទី ១៩)។

*៨.* សារាចរទី ២ ត្រូវបានចេញដោយរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាន់កាប់ដីខុសច្បាប់នៃដីរបស់រដ្ឋបានចុះនៅថ្ងៃទី ២៦ ខែ កុម្ភះ ឆ្នាំ ២០០៧ ចែងថា ខណៈដែលការកាន់កាប់ដីជាទម្រង់នៃភាពជាម្ចាស់ក្លាយជាខុសច្បាប់បន្ទាប់ពី ថ្ងៃ ៣០ ខែ កក្កដា ឆ្នាំ ២០០១ មានតម្រូវការមួយសម្រាប់រដ្ឋដើម្បីអនុវត្តដីសម្បទានសង្គមកិច្ចដល់ប្រជាជនក្រីក្រ និងក្រុមដែលមិនទទួលបានផលប្រយោជន៍នានា ដើម្បីតម្រូវទៅតាមសេចក្តីត្រូវការរបស់ពួកគេសម្រាប់ដីដែលបណ្តាលមកពីការកើនឡើងនៃប្រជាពលរដ្ឋ ការបញ្ចេញពីកំណែនទ័ព និងការបាត់បង់ដីដោយសារគ្រោះមហន្តរាយធម្មជាតិ។ ទោះជាយ៉ាងណា ការចាប់យកដីរដ្ឋយ៉ាងអនាធិតេយ្យក្នុងពេលបច្ចុប្បន្នក៏ផ្តល់នូវឱកាសមួយចំនួនសម្រាប់ការយកកម្រៃពីដី និងបុគ្គលមានអំណាចមួយចំនួនដើម្បីកាន់កាប់ដីរដ្ឋខុសច្បាប់តាមរូបភាពផ្សេងៗ។ ដើម្បីឆ្លើយតបនូវស្ថានភាពបែបនេះសារាចរទី ២ កំណត់ថាៈ

១. ជាទូទៅ អ្នកកាន់កាប់ដីរបស់រដ្ឋខុសច្បាប់ ជាពិសេសអ្នកទាញយកកម្រៃពីដី មិនត្រូវបានឱ្យសិទ្ធិក្នុងការ ទទួលសំណងនោះទេ (កថាខណ្ឌ ៦.១ នៅក្នុងសារាចរទី ០២)

២. អ្នកកាន់កាប់ដីរដ្ឋខុសច្បាប់នានា ដែលជាក្រុមគ្រួសារក្រីក្រ និងគ្រួសារគ្មានដី រឺខ្វះដី និងអ្នកមិនបានទទួលនូវផលប្រយោជន៍ មិនគួរត្រូវបានផ្តល់សិទ្ធិក្នុងការផ្តល់ឱ្យសំណងទេ ប៉ុន្តែអាចទទួលបាននូវលើកទឹកចិត្តដ៏សមស្របដើម្បីទទួលនូវចំនួនដីសម្រាប់ជីវភាពរស់នៅរបស់ពួកគេ (កថាខណ្ឌ ៦.២ ក្នុងសារាចរទី ០២)។

៣. សម្រាប់ដីឯកជនរបស់រដ្ឋ អាចត្រូវបានធ្វើឡើងតាមរយៈការលក់ ជួល ផ្តល់ជារង្វាន់ សិទ្ធិអាស្រ័យផល (សិទ្ធិក្នុងការប្រើប្រាស់ និងរីករាយពីផលនានាពីដីសម្រាប់ជីវិត)ពីដីសម្បទានសង្គមកិច្ច ដីសម្បទានសេដ្ឋកិច្ច រឺអនុញ្ញាតឱ្យប្រើប្រាស់។ ការសម្រេចចិត្តទៅលើជម្រើសជាក់លាក់ត្រូវតែផ្អែកទៅលើការសម្របសម្រួលរវាងអាជ្ញាធរដែនដី

អាជ្ញាធរគ្រប់គ្រងដីរដ្ឋ និងបុគ្គលដែលប្រើប្រាស់ដីនោះ និងត្រូវបានផ្អែកទៅលើផែនការប្រើប្រាស់ដី (កថាខណ្ឌ ៧.១ សារាចរទី ០២) ។

## ៣.២ គោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅស្ថានឡើងវិញដោយមិនស្មគ្រ័ចិត្ត

***៩.*** គោលនយោបាយនៃកិច្ចប្រតិបត្តិការណ៍របស់ធនាគារពិភពលោក ៤.១២: ការរើទីលំនៅស្ថានជាថ្មីដោយមិនស្មគ្រ័ចិត្ត និង OP 4.10: ប្រជាជនក្នុងស្រុកត្រូវបានចូលរួមសំរាប់គំរោងនេះ។ គោលនយោបាយបង្ហាញពី គោលបំណង និង គោលការណ៍ណែនាំដើម្បីត្រូវបានអនុវត្តតាមស្ថានការណ៏ ដែលពាក់ពន្ធ័ទៅនឹងការមិនស្មគ្រ័ចិត្តកាន់កាប់ដីធ្លី និង ការដាក់ក៏រិតដោយបង្ខំនៃលទ្ធភាពទាញយកធនធានពីឧស្សានដែលបង្កើតឡើង និង តំបន់អភិរក្ស និង នៅពេល ដែលប្រជាជនក្នុងស្រុក រឺក៏ជនជាតិភាគតិចត្រូវបានពាក់ពន្ធ័។OP 4.12 មានបំនងដើម្បីបញ្ជៀសការរើទីលំនៅជាថ្មីដោយមិនពេញចិត្ត ទៅជាលំនៅស្ថានដែលមានភាពល្អប្រសើរ រឺក៏ដើម្បីកាត់បន្ថយ និង ជួយសំរាលដល់ផលប៉ះពាល់មិនល្អដល់សេដ្ឋកិច្ច និង សង្គម។ វាបង្កើននូវការចូលរួមនៃមនុស្សដែលគ្មានជំរកទៅក្នុង ផែនការ និង ការអនុវត្តន៏នៃការរើទីលំនៅជាថ្មី ហើយគោលដៅសេដ្ឋកិច្ចគន្លឹះរបស់វាគឺត្រូវតែជួយដល់មនុស្សអនាថា ដើម្បីលើកស្ទួយ រឺយ៉ាងហោចណាស់ក៏ប៉ះប៉ូវនូវប្រាក់ចំណូល និង ការរស់នៅរបស់គេ បន្ទាប់ពីធ្វើការផ្លាស់ទីលំនៅនោះ។ គោលនយោបាយដាក់ចេញជា សំណង និង វិធានការណ៏នៃការរើលំនៅស្ថានឡើងវិញដើម្បីសំរេចនូវគោលដៅរបស់ខ្លួន ហើយតម្រូវថា អ្នកខ្ចី រៀបចំនូវអទិភាពនៃគ្រឿងបរិក្ខារនៃផែនការរើលំនៅស្ថានឡើងវិញ ទៅកាន់ការវាយតំលៃរបស់ធនាគារសំរាប់គំរោងដែលបានស្នើ។

***១០.*** សំរាប់ការកាន់កាប់ដីធ្លី និង ការដាក់ក៏រិតទៅលើលទ្ធភាពទាញយកធនធាន គោលនយោបាយតំរូវអោយមានការព្រឹក្សាយ៉ាងជិតស្និទ្ធិ នៃចំនួនប្រជាជនដែលរងផលប៉ះពាល់ និង ការជួយបន្ធូរបន្ថយសំរាប់ផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដែលត្រូវបានផ្តល់ជាចំណាប់អារម្មណពិសេសទៅលើ ក្រុមជនជាតិ យែនឌ័រ និង បញ្ហាក្រុមដែលងាយរងផលប៉ះពាល់ដ៏ទៃទៀត។ គោលនយោបាយបង្ហាញយ៉ាងច្បាស់នូវតំរូវការសំរាប់ធ្វើការត្រួតពិនិត្យតាមដាន និង ការវាយតំលៃ និង ធ្វើការធានានូវថវិការ និង លទ្ធភាពដ៏គ្រប់គ្រាន់សំរាប់ទីភ្នាក់ងារ។

# ផ្នែកទី៤: ការគាំពារសង្គម និង ដំណើរការនៃ RPF សំរាប់ M-IWRM

## ៤.១ កិច្ចគាំពារសង្គម

***១១.*** ការត្រួតពិនិត្យសង្គម និង បរិស្ថានជំហានដំបូង (IESE) ត្រូវបានអនុវត្តកំឡុងពេលនៃការរៀបចំសំរាប់ M-IWRM (គំរោង) ដែលផ្អែកទៅលើការងារដែលត្រូវបានកំណត់អត្តសញ្ញាណមុនពេលធ្វើការវាយតំលៃ។ ការសិក្សាបានសន្និដ្ឋានថា ការរើទីលំនៅជាថ្មី រឺក៏ការកំទេចចោលផ្ទះសំបែង និង មុខជំនួញមួយចំនួន ព្រមទាំងផលប៉ះពាល់ទៅលើជំរកវប្បធម៌នឹងមិនត្រូវបានពាក់ពន្ធ័ឡើយ។ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តន៏នៃសមាសភាព៣អាចត្រូវការនូវការកាន់កាប់ដីតូចៗ

សំរាប់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ជំហានដំបូង និង អាចពាក់ពន្ធ័ទៅនឹងការដាក់កំរិតនៃលទ្ធភាពទាញយកធនធាន រឺក៏ការកាន់កាប់ដីធ្លី ។ទោះបីជាយ៉ាងណាក៏ដោយ ទំហំនៃផលប៉ះពាល់គំរោងដែលបានគិតទុក គឺតិចតួច ដែលអាចត្រូវបានគ្រប់គ្រងដោយសមាជិគសហគមន៍ដោយផ្ទាល់ ជាមួយនឹងការគាំទ្រយ៉ាងសកម្មពីបុគ្គលិកគំរោងដែលនឹងចុះទៅសហគមន៍ សំរាប់ធ្វើការអភិវឌ្ឍន៏សមត្ថភាពរបស់ពួកគេ នៅក្នុងការគ្រប់គ្រងធនធានដែលទទួលបានតាមរយៈការអនុវត្តន៏គំរោង ។វិធានការបន្ធូរបន្ថយនឹងត្រូវបានផ្តល់អោយ តាមរយៈគោលនយោបាយគាំពាររបស់ធនាគារពិភពលោក ។ដើម្បីធានាដល់ការងារនេះគ្រប់សកម្មភាពទាំងអស់ គ្រប់សមាសភាពរងទាំងអស់ និង គ្រប់គំរោងរងទាំងអស់ ដែលពាក់ពន្ធ័នឹងកម្មសិទ្ធិដីធ្លី សំណងវិភាគទានដីធ្លី និង ការដាក់កំរិតនៃលទ្ធភាពទាញយកធនធាន នឹងត្រូវបានត្រូវការដើម្បីសំរេចនូវការងារគាំពារសង្គម (ចូរមើលនៅក្នុងឧបសម្ពន្ធ័២) និង រក្សាកំណត់ត្រាផ្សេងៗនៅក្នុងសំនុំឯកសារគំរោងសំរាប់ ធ្វើការត្រួតពិនិត្យឡើងវិញដោយធនាគារពិភពលោក។ ដោយត្រូវបានផ្តល់មកជាមួយថា នឹងមានការងារដែលត្រូវបានកំណត់កំឡុងពេលនៃការអនុវត្តន៏គំរោង ការរើទីលំនៅជាថ្មី នងិ ការកំទេចចោលផ្ទះសំបែង រឺក៏មុខជំនួញផ្សេងៗ ត្រូវបានហាមឃាត់ ហើយត្រូវបានបញ្ចូលទៅក្នុង "បញ្ជីអវិជ្ជមាន" នៃគំរោងគ្រប់គ្រងសង្គម និង បរិស្ថាន(ESMF)សំរាប់ផែនការ ។

***១២.*** ដើម្បីស្វែងរកនូវផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីការកាន់កាប់ដីធ្លី វិភាគទានដីធ្លី និង ការដាក់កំរិតទៅលើការប្រើប្រាស់ធនធាននោះ RPF ត្រូវបានបង្កើត និង ត្រូវបានភ្ជាប់សំរាប់ M-IWRM បន្ទាប់ពីគោលការណ៏ណែនាំផ្នែកបច្ចេកទេសដែលបានពណ៌នានៅក្នុងឧបសម្ពន្ធ័១។ គំរោងនឹងជួយដល់សមាជិកសហគមន៍ដើម្បីបង្កើតនូវយន្តការណ៏គ្រប់គ្រងធនធានទឹករួម បង្កើតនូវធាតុផ្សំសំខាន់ដែលជាដំណោះស្រាយសំរាប់ផលប៉ះពាល់ និង ជាយន្តការណ៏លួងអារម្មណ៏និងជាការរៀបចំរួមសំរាប់ការគ្រប់គ្រងធនធានជលផល និង ធនធានទឹកដ៏មាននិរន្តភាព ។ដោយត្រូវបានផ្តល់មកជាមួយថា តម្លាភាព និង ការចូលរួមរបស់សហគមន៍គឺជាគន្លឹះដែលនាំទៅរកភាពជោគជ័យ ។ គំរោងនឹងបង្កើតនូវយន្តការណ៏ដែលនឹងជួយដល់សមាជិកសហគមន៍ ដើម្បីស្វែងរកនូវផលប៉ះពាល់របស់គំរោងដោយខ្លួនឯង ដូច្នេះសមាជិគសហគមន៍គឺអាចគ្រប់គ្រងបញ្ហាក្នុងសហគមន៍ដែលបណ្តាលមកពីការបាត់បង់ទ្រព្យសម្បត្តិ និង ប្រាក់ចំណូល ។យន្តការណ៏គ្រប់គ្រងធនធានជលផល និង ធនធានទឹកដែលត្រូវបានបង្កើតក្រោមគំរោងនោះនឹងមាននិរន្តភាព ។គំរោងនឹងផ្តល់នូវការបណ្តុះបណ្តាល និង ធ្វើការត្រួតពិនិត្យតាមដានឥតឈប់ឈរ ដូច្នេះសមាជិកសហគមន៏អាចស្វែងរកនូវផលប៉ះពាល់អវិជ្ជមាន តាមមធ្យោបាយដែលនឹងស្របទៅតាមគោលនយោបាយប្រជាជនក្នុងស្រុក និង គោលនយោបាយនៃការរើទីលំនៅឡើងវិញរបស់ធនាគារពិភពលោក ។ការអនុវត្តន៏របស់គោលការណ៏ណែនាំ និង វិធីសាស្ត្ររបស់គំរោង ត្រូវបានរៀបចំផែនការណ៏នៅក្នុងផ្នែកខាងក្រោម ។

២.១.១. គោលនយោបាយអនុវត្តរបស់ធនាគារពិភពលោក គឺជាគោលនយោបាយសង្គម និងបរិស្ថានដែលត្រូវបានយោងទៅតាមធនាគារ "គោលនយោបាយសុវត្ថិភាពនានា"។ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គត្រូវតែបានតម្រូវឱ្យស្របទៅតាមគោលនយោបាយសុវត្ថិភាពសង្គម និងបរិស្ថានរបស់ធនាគារពិភពលោក ដែលរួមមានទាំងការ បង្ហាញព័ត៌មានឱ្យដឹង និងការពិគ្រោះយោបល់ជាសាធារណៈ (O.P.17.50) ដែលបំពេញនូវសេចក្តីត្រូវការរបស់ធនាគារពិភពលោកសម្រាប់ផ្តល់ដល់ដំណើរការសាធារណៈនៅក្នុងការចងក្រងឯកសារ និងព័ត៌មានរបស់គម្រោង។

**៤.២ គំរោងគោលនយោបាយសំរាប់ការកាន់កាប់ដីធ្លី និង សំណង**

១. **គោលការណ៍ទូទៅ**

*១៣.* គម្រោងគោលនយោបាយនៃ ការតាំងទីលំនៅដ្ឋានឡើងវិញ (Resettlement Policy Framework) បង្កើត ឡើងស្មើភាពគ្នារវាងធនាគារពិភពលោក (World Bank's OP 4.12) និងច្បាប់របស់កម្ពុជាស្តីពីការតាំងទីលំនៅដ្ឋាន ដោយមិនស្មគ្រ័ ចិត្ត តាមរយៈវិធានការកំណត់ដើម្បីបំពេញនូវចន្លោះខ្វះខាតរវាងគម្រោងស្របច្បាប់ជាតិ និងគោលនយោបាយប្រតិបត្តិរបស់ ធនាគារពិភពលោក (OP 4.12)។ គោលការណ៍ និងនីតិវិធីទាំងពីរនេះបានរៀបរាប់នៅក្នុង ឆ្នាំ ២០០១នៃច្បាប់កម្ពុជា និង គោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅដ្ឋានដោយមិនមានការស្មគ្រ័ចិត្តនឹង ត្រូវបានអនុវត្ត។ នៅក្នុងន័យនេះ គោលបំណង និងគោលនយោបាយខាងក្រោមគួរត្រូវបានអនុវត្តៈ

ក. ការទទួលដី រឺទ្រព្យសម្បត្តិផ្សេងទៀត និងការតាំងទីលំនៅដ្ឋានឡើងវិញនៃប្រជាពលរដ្ឋនឹងត្រូវបានកាត់បន្ថយតាមដែលអាចធ្វើបាន។

ខ. រាល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ត្រូវបានកំណត់អត្តសញ្ញាណនូវផលប៉ះពាល់របស់គម្រោងចាប់តាំងពីថ្ងៃនៃការសិក្សាព័ត៌មានមូលដ្ឋាន។ ពួកគេត្រូវបានគេផ្តល់សិទ្ធិដើម្បីផ្តល់មតិអំពីវិធានការស្តារឡើងវិញ ដោយជួយពួកគេដើម្បីធ្វើឱ្យប្រសើរឡើង រឺយ៉ាងហោចរក្សាស្តង់ដារស់នៅរបស់ពួកគេមុនគម្រោងចាប់ផ្តើម សមត្ថភាពរកប្រាក់ចំណូល និងកម្រិតនៃផលិតភាពនានា។ កង្វះខាតនៃសិទ្ធិស្របច្បាប់ដែលឈានទៅរកបាត់បង់ទ្រព្យសម្បត្តិនឹងមិនមែនជារបាំងសម្រាប់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ និងលើការផ្តល់សិទ្ធិ/សំណង ទៅលើវិធានការស្តារឡើងវិញនានាបែបនេះនោះទេ។

គ. វិធានការស្តារឡើងវិញត្រូវបានផ្តល់ឱ្យៈ ១). ការផ្តល់សំណងជាប្រាក់នៅទីតាំងដែលធ្វើការផ្លាស់ប្តូរដោយគ្មានការដកហូតដោយឱ្យតម្លៃថោក រឺសម្ភារៈដែលអាចជួយស្រោចស្រង់បានសម្រាប់លំនៅដ្ឋាន និងទម្រង់ផ្សេងៗទៀត ២).ដីកសិកម្មដែលមានសមត្ថភាពផលិតស្មើគ្នាអាចព្រមទទួលយកទៅតាមប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ៣).ការដាក់ជំនួសនៃដីសេដ្ឋកិច្ច និងដីសម្រាប់តាំងលំនៅដ្ឋាននៃទំហំដីប៉ុនគ្នាអាចទទួលយល់ព្រមទៅតាមរបស់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ , ៤). និងបញ្ជូន និងប្រាក់ឧបត្ថម្ភឱ្យបានសមស្រប។

ឃ. ការផ្លាស់ប្តូរដីកសិកម្ម និងលំនៅដ្ឋាននឹងត្រូវស្ថិតនៅជិត១ដីដែលបានបាត់បង់ តាមដែលអាចធ្វើបាន និងទទួលការយល់ព្រមរបស់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ។

ង). ផែនការសម្រាប់ការទទួលដី និងទ្រព្យសម្បត្តិផ្សេង១ទៀត និងការផ្តល់នូវវិធានការស្តារឡើងវិញ នឹងត្រូវបានអនុវត្តនៅក្នុងកិច្ចពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ដើម្បីធានានូវការរំខាន រឺផលប៉ះពាល់តិចបំផុត ។

ច). សំណង ការតាំងលំនៅដ្ឋានឡើងវិញនិងសកម្មភាពស្តារឡើងវិញនឹងមានការពេញចិត្តមុនពេលមិនមានការជំទាស់ពី ធនាគារពិភពលោក នឹងត្រូវផ្តល់នូវការសម្រេចលើកិច្ចសន្យានៃការងារស៊ីវិលក្រោមអនុគម្រោង ។

ឆ). ប្រភពនៃមូលនិធិសម្រាប់ការស្តាបនាឡើងវិញ និងសំណងនៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់នឹងត្រូវបានផ្តល់ថវិកាឱ្យដូចតទៅៈ ការផ្តល់សំណងសម្រាប់ដីសេដ្ឋកិច្ច ដីតាំងលំនៅដ្ឋាន និងដីផ្តល់ផល (កសិកម្ម) ដែល ជា ដីនៅពីតាមភូមិ តាមរយៈការអនុម័តផ្តល់ឱ្យដោយភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវ និងសំណងជាថវិកា សម្រាប់រចនាសម្ព័ន្ធ ដើមឈើ ផលដំណាំ ការបាត់បង់ប្រាក់ចំណូល និងជំនួយការស្តាបនាឡើងវិញនឹងបានមកពី ថវិកាសមភាគីនៅក្នុងគម្រោង ។

ជ. អង្គភាពគ្រប់គ្រងគំរោង(PMU) នៃ FiA យល់ឃើញថា ការចាត់ចែងរបស់ស្ថាប័ននឹងស្ថិតនៅក្នុងកន្លែងដ៏ត្រឹមត្រូវដើម្បីធានានូវ ការអនុវត្តន៍ ការព្រឹក្សា ការរៀបចំផែនការ ការរៀបចំគំរោងដ៏មានប្រសិទ្ធិភាព និង ទាន់ពេលវេលាសំរាប់កម្មវិធីសំណង ។

ឈ. វិធានការបន្ធូរបន្ថយនៃផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ ដោយសារតែការកាន់កាប់ដីធ្លី និង ការដាក់កំរិតទៅលើលទ្ធភាពទាញយកធនធាន ត្រូវបានពិចារណាកំឡុងពេលនៃការរៀបចំរបស់គំរោង ដោយធ្វើការផ្តោតទៅលើការគ្រប់គ្រងរួមដែលផ្អែកលើសហគមន៍សំរាប់ផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ ដែលនឹងស្របទៅតាមគោលនយោបាយរបស់ធនាគារពិភពលោក ថាជាផ្នែកមួយនៃសមាសភាពរងរបស់គំរោង ។ផលប៉ះពាល់ដែលមិនមាននៅក្នុងចំនុចចាប់ផ្តើមនៃវិភាគទានដីធ្លីនោះ RAP ដែលដាច់ដោយឡែកមួយនឹងត្រូវបានរៀបចំដើម្បីអនុលោមទៅតាម OP-4.12 ។ ព្រោះតែការដាក់កំរិតនៃលទ្ធភាពដើម្បីទាញយកធនធាន យន្តការណ៍ខាងក្រោមនឹងត្រូវបានអនុវត្តៈ (១) បណ្តឹងនិងជំងឺចិត្ត នឹងត្រូវបានដោះស្រាយជាជំហានដំបូងដែលស្ថិតនៅក្រោម យន្តការណ៍ដំណោះស្រាយបញ្ហាដែលផ្អែកលើសហគមន៍ និង នៅក្រោមបុគ្គលិកគំរោង (២) ប្រសិនបើយន្តការណ៍ក្នុងស្រទាប់ដំបូងបរាជ័យដើម្បីដោះស្រាយនូវបណ្តឹង និង ជំងឺចិត្តនោះ បន្ទាប់ពីនោះ យន្តការណ៍ស្រទាប់ទី២ដែលពាក់ពន្ធ័ទៅនឹងការសំរុះសំរួលពីក្រុមទី៣ រឺក៏ពីខាងក្រៅ នឹងចាប់ផ្តើម ហើយជួយដោះស្រាយបញ្ហា ។យន្តការណ៍សារទុក្ខត្រូវបាន ពណ៌នានៅក្នុងផ្នែក៤.៥ ។

១. "ដីកសិកម្មសំរាប់ដីដែលមានលទ្ធភាពផលិតទិន្នផលបានដូចដើម" មានន័យថាដីដែលត្រូវបានផ្តល់អោយជាដីសំណង គួរតែអាចផលិតទិន្នផលបានដូចមុន រឺក៏ប្រសើរជាងនោះ ដែល PAP បានផលិតលើដីរបស់ពួកគេពីមុននោះ។ ផលិតកម្មគួរតែត្រូវបានផលិតភ្លាមៗក្នុងរដូវដាំដុះបន្ទាប់ពីទទួលបានកម្មសិទ្ធិដីធ្លី។ វាអាចស្ថិតនៅក្នុងពេលអនាគត ប្រសិនបើទឹកប្រាក់ដែលបានមកស្មើទៅនឹងទិន្នផលពីឆ្នាំមុនត្រូវបានផ្តល់សំរាប់ គ្រួសារនៃ PAP កំឡុងពេល ដែលធ្វើការរងចាំសំរាប់ដី ដើម្បីទទួលបាននូវផលិតផលដូចទៅនឹងដីពីមុន។

## ២. សំណង និង ការផ្តល់សិទ្ធិ

***១៤.សិទ្ធិទទួលបាន:*** រាល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ពីគម្រោងដែលបានកំណត់អត្តសញ្ញាណនៅក្នុងតំបន់ប៉ះពាល់ របស់ គម្រោងលើការកាត់បន្ថយនូវកាលបរិច្ឆេទ នឹងត្រូវបានផ្តល់សិទ្ធិដើម្បីសងសម្រាប់ផលប៉ះពាល់ទៅលើទ្រព្យសម្បត្តិរបស់ពួកគេ និង វិធានការនៃការស្តារឡើងវិញប្រកបដោយពេញចិត្ត ដើម្បីជួយដល់ពួកគេក្នុងការលើកកម្ពស់ រឺយ៉ាងហោចស្តង់ដារស់នៅ របស់គេ សមត្ថភាពរកប្រាក់ចំណូល និងកំរិតផលិតភាពនានា។ ការកាត់បន្ថយនូវពេលពេល វានឹងជាថ្ងៃចុងក្រោយនៃការ អង្កេតនៃ វិធានការលំអិតនូវរាល់ការវិនិយោគ។ ប្រជាពលរដ្ឋទាំងនោះដែលទន្រ្ទានដីធ្លីនៅក្នុងតំបន់វិនិយោគបន្ទាប់ពីថ្ងៃ ដែលបានកាត់ចេញនឹងមិនត្រូវផ្តល់សិទ្ធិទទួលនូវសំណង រឺជំនួយផ្សេងៗនោះទេ។

***១៥. ការផ្តល់សិទ្ធិ:*** ដោយផ្អែកលើប្រភេទនៃផលប៉ះពាល់ ក្រុមនៃ PAPs ហើយនឹងការផ្តល់សិទ្ធិសំរាប់ពួកគេនោះ M-IWRM នឹងរៀបចំនូវការផ្តល់សិទ្ធិដ៏ជាក់លាក់ទៅអោយ ក្រុមនៃ PAPs បន្ទាប់ពីម៉ាទ្រិកនៃការផ្តល់សិទ្ធិ (តារាងទី៣នៃឧបសម្ពន្ធ័១) អោយបានត្រឹមត្រូវ។ បន្ទាប់ពី ការរៀបចំផែនការយ៉ាងលំអិត DMS និង ការស្ទាប់ស្ទង់លើផ្នែកសេដ្ឋកិច្ចសង្គមនឹងក្លាយជាមូលដ្ឋានសំរាប់ធ្វើការកំណត់លើផលប៉ះពាល់ជាក់ស្តែង ហើយការស្ទាប់ស្ទង់ទៅលើការចំណាយនៃការផ្លាស់ប្តូរនឹងត្រូវបានអនុវត្តដើម្បីកំណត់នូវ អត្រា និង ការចំណាយលើការផ្លាស់ប្តូរ ដោយរួមមានពត៌មានស្តីពី ដីធ្លី និង ហេដ្ឋារចនាសម្ពន្ធ័ដែលរងផលប៉ះពាល់ ដូចដែលបានបរិយាយនៅក្នុងឧបសម្ពន្ធ័៣។ ផែនការការងារនៃការរើលំនៅស្ថានឡើងវិញ(RAP)នឹងត្រូវបានរៀបចំស្របជាមួយនឹងគោលការណ៍ណែនាំផ្នែកបច្ចេកទេស(ឧបសម្ពន្ធ័១)។

## ៣. ការពិនិត្យវិច័យពិសេស

***១៦. ភាពងាយរងផលប៉ះពាល់ យែនឌ័រ និង ក្រុមជនជាតិ :*** M-IWRM កត់សំគាល់ឃើញថា ក្រុមក្នុងសង្គមអាចមានលទ្ធភាពតិចតួចដើម្បីស្តារនូវជីវភាព របរចិញ្ចឹមជីវិត និង កំរិតនៃប្រាក់ចំនូលរបស់ពួកគេឡើងវិញ ហើយបានបញ្ចូលបញ្ហាទាំងនេះទៅក្នុងការរៀបចំ និង អនុវត្តន៏សំរាប់ការងារគំរោងតាមរយៈការអនុមត័សំរាប់ដំនើរការនៃការសំរេចចិត្ត និង ការរៀបចំផែនការដែលពាក់ពន្ធ័។ស្រ្តីនៅតាមភូមិជនបទ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការលើកកំពស់ការចិញ្ចឹមជីវិតក្នុងសហគមន៏ និង សេដ្ឋកិច្ចគ្រួសារ។ពួកគេនឹងត្រូវបានផ្តល់សិទ្ធិដើម្បីក្លាយជាសមាជិកដ៏សកម្មនៅក្នុងការងារសហគមន៏ និង គំរោង និង នៅក្នុងកិច្ចខ្ទះខ្នែងរួមគ្នាដទៃទៀតក្នុងការគាំទ្រសំរាប់ការត្រួតពិនិត្យតាមដាន និង ការអនុវត្តគំរោង។

១៧. កំឡុងពេលនៃការអនុវត្តន៏ គំរោងនឹងផ្តល់ចំណាប់អារម្មណ៏ពិសេសទៅលើស្រ្តី និង ក្រុមគ្រួសារភេទស្រីថាជាអ្នកទទួលបានប្រយោជន៏នៃការមកដល់របស់គំរោង។ការចូលរួមស្មើគ្នារបស់ស្រ្តីនៅក្នុងគំរោងទាំងមូល នឹងត្រូវបានផ្តល់ដើម្បីជួយលើកស្ទួយការចិញ្ចឹមជីវិតសំរាប់និរន្តភាពរបស់គំរោង។ ការចូលរួមយ៉ាងសកម្មពីស្រ្តី និង ក្រុមជនជាតិនឹងត្រូវបានធានាកំឡុងពេលនៃការអភិវឌ្ឍន៏នៃវិធានការដ៏ត្រឹមត្រូវ ដើម្បីឆ្លើយតបទៅនឹងតំរូវការ និង បញ្ហាជាក់លាក់សំរាប់ក្រុមទាំងនេះដែលមានដូចជា ក្រុមគ្មានដីធ្លី ក្រុមក្រីក្រ និង ក្រុមគ្រួសារដោយគ្រប់គ្រងដោយស្ត្រី ក្រុមជនពិការ ក្រុមចាស់ជរា និង ក្រុមកុមារដែលគ្មានការឧបត្ថម្ភ។ប្រសិនបើផែនការការងាររើលំនៅស្ថានឡើងវិញ(RAP)ត្រូវបានត្រូវការ មានភាពសមរម្យ និង ត្រូវបានទទួលយកនោះក្នុងចំណោមមនុស្សដែលពាក់ពន្ធ័នោះ យុទ្ធសាស្រ្តយែនឌ័រ និង ការងារជាក់លាក់របស់ក្រុមជន-ជាតិ ដូចដែលបានពណ៌នានៅក្នុងគោលការណ៏ណែនាំផ្នែកបច្ចេកទេស(ឧបសម្ពន្ធ័)នឹងត្រូវបានបូកបញ្ចូល។

***១៨. វិភាគទានដីធ្លីដោយស្មគ្រ័ចិត្ត:*** កន្លែងដែលការកាន់កាប់ដីធ្លីដ៏តិចតួច រឺក៏ការតាំងទីលំនៅជាថ្មី គឺមិនអាចជៀសផុតវាអាចកើតឡើងទៅលើមូលដ្ឋានស្មគ្រ័ចិត្ត រឺក៏ជាមួយនឹងសំណង(អាចពេលខ្លះជា អំពើសប្បុរស)ដែលត្រូវបានផ្តល់ដោយដីសាធារណ: (ជាពិសេសតាមភូមិ) តែមិនអោយចេញក្រៅពីមូលនិធិគំរោងឡើយ។ដោយស្របទៅតាម អ្នកភូមិដែលអនុវត្តន៏កសិកម្មតាមបែបប្រពៃណីនោះ អាចជ្រើសរើស ដើម្បីបរិច្ចាគដី រឺក៏ទ្រព្យសម្បត្តិដោយស្មគ្រ័ចិត្ត រឺក៏ផ្លាស់ទីលំនៅបណ្តោះអាសន្ន រឺក៏អចិន្ត្រៃយ៏ពីដីរបស់ពួកគេដោយគ្មានសំណង។ ចំនុចនេះជារឿយៗអាចត្រូវបានថ្លឹងថ្លែងពិចារណាពីព្រោះគំរោងនឹងបង្កើននូវតំលៃនៃព្រទ្យសម្បត្តិដែលនៅសល់ រឺក៏ផ្តល់នូវផលប្រយោជន៏ដោយផ្ទាល់ដ៏ទៃទៀតទៅដល់មនុស្សដែលរងផលប៉ះពាល់។

***១៩.*** ទោះបីជាយ៉ាងណាក៏ដោយ សកម្មភាពដែលរួមមានការបរិច្ចាគដោយស្មគ្រ័ចិត្ត នឹងមិនត្រូវបានអនុញ្ញាតនៅកន្លែងដែលវាធ្វើអោយខូចខាតធ្ងន់ធ្ងរដល់ប្រាក់ចំណូល រឺក៏ជីវភាពរបស់ម្ចាស់ដី រឺក៏អ្នកប្រើប្រាស់ដីឡើយ។ វិភាគទាន ស្មគ្រ័ចិត្តនឹងមិនអនុវត្តរាល់គ្រប់ព្រទ្យសម្បត្តិឡើយ លើកលែងតែវិភាគទាន និង ការបាត់បង់ដីបន្តិចបន្តួចរបស់ប្រជាពលរដ្ឋ និង ដីកសិកម្ម ដែលនៅបន្ទាប់ពីលក្ខខណ្ឌ័វិនិច្ឆ័យ និងដំនើរការដែលពណ៌នាដូចខាងក្រោម:

- វិភាគទានស្មគ្រ័ចិត្តនៃបំនែកដ៏តូចនៃដីធ្លីលំនៅស្ថាន នឹងស្របទៅតាមលក្ខខណ្ឌ័វិនិច្ឆ័យបន្តបន្ទាប់ដែលនឹង អនុលោមទៅតាម (១) ផ្ទៃដីរបស់ប្រជាពលរដ្ឋសរុបរបស់ PAP មិនតិចជាង ៣០០គីឡូម៉ែត្រការេ(គ.ម២)ឡើយ។ (២) ប្រសិនបើផ្ទៃដីលំនៅស្ថានសរុបរបស់ PAP គឺច្រើនជាង ៣០០គីឡូម៉ែត្រការេ(គ.ម២) បំនែកដីដែលអាចត្រូវបានបរិច្ចាគមិនអាចលើសពី ៥ភាគរយនៃផ្ទៃដីសរុបឡើយ ហើយ(៣) មិនមានផ្ទះសំបែង ហេដ្ឋារចនាសម្ពន្ធ័ រឺក៏អចលនទ្រព្យស្ថិតនៅលើបំនែកដីដែលពាក់ពន្ធ័ឡើយ។

- ការបរិច្ចាគដោយស្មគ្រ័ចិត្តគឺជាសកម្មភាពនៃការព្រមព្រៀងដែលបានដឹងជាមុន ហើយបុគ្គលិករបស់គំរោងនឹងធានាថា ការបរិច្ចាគដោយស្មគ្រ័ចិត្តត្រូវបានអនុវត្តជាមួយនឹងការយល់ដឹងជាអទិភាព ដែលអាចមានជំរើសដទៃសំរាប់ធ្វើការផ្លាស់ប្តូរ និង ត្រូវបានទទួលយកដោយគ្មានការ បង្ខិតបង្ខំ រឺក៏ប្រើច្បាប់ដាក់ទោស ។

- គំរោងនឹងអនុវត្ត ជាមួយនឹងការព្រឹក្សាប្រកបដោយការយល់ដឹង មុនពេល នឹងមិនមានការចំនាយ ហើយដំនើរការរៀបចំផែនការនៃការចិញ្ចឹមជីវិតដែលពាក់ពន្ធ័ ជាមួយនឹង PAPs ដើម្បីបង្កើតនូវកិច្ចព្រមព្រៀង និង ការគាំទ្ររបស់ពួកគេសំរាប់អត្តរាគមន៏ទ្រង់ទ្រាយតូច ដែលអាចត្រូវការការបរិច្ចាគដីធ្លីដោយស្មគ្រ័ចិត្តរបស់ពួកគេ ។ទោះបីជាយ៉ាងណាក៏ដោយ PAPs មានសិទ្ធិដើម្បីបដិសេធ និង ទទួលនូវ ការផ្តល់សិទ្ធិ និង សំណងរបស់ពួកគេសំរាប់ដី នឹងទ្រព្យសម្បត្តិរបស់ពួកគេដែលបាត់-បង់ ។ ។ពួកគេនឹងត្រូវបានផ្តល់ពត៌មានស្តីពី សិទ្ធិ និង លទ្ធភាពប្រើប្រាស់នូវ យន្តការណ៏សារទុក្ខ ដែលត្រូវបានពណ៌នា នៅក្នុងផ្នែក ៤.៥ នៃឯកសារនេះ ប្រសិនបើការផ្តល់សិទ្ធិ និង សំណងរបស់ពួកគេ មិនត្រូវបានផ្តល់នៅក្នុងស្ថានភាពដ៏សម-ស្រប ។

### ៤. ដំណើរការអនុវត្តន៏

***២០.*** នៅកន្លែងដែលសំណងត្រូវបានផ្តល់អោយ បុគ្គលិករបស់គំរោងនឹងធានាថា ចំនុចខាងក្រោមត្រូវបានយល់ស្របមុនពេលដែលការងារត្រូវបានទទួលធ្វើ:

- ការផ្លាស់ប្តូរដីជាមួយនឹងដីដែលមានដីជាតិដូចពីមុន រឺក៏ទ្រព្យសម្បត្តិដែលមានតំលៃស្មើ
- សំភារ: និង ជំនួយ ដើម្បីសងនូវសំណង់ដែលនឹងត្រូវបានបំផ្លាញ និង ដកចេញ ។
- ការសងវិញនូវដំណាំដែលត្រូវបំផ្លាញ ដោយស្របតាមតំលៃទីផ្សារ
- សំណងសប្បុរសធម៌ដែលអាចទទួលយកបានដទៃទៀត ។

***២១.*** សំរាប់ប្រភេទទាំងពីរនៃការកាន់កាប់ដីធ្លី (ការបរិច្ចាគដោយស្មគ្រ័ចិត្ត រឺក៏ប្រឆាំងនឹងសំណង) បុគ្គលិករបស់គំរោងនឹងធានាថាគ្រប់អ្នកកាន់កាប់ដីធ្លីទាំងអស់ និង ម្ចាស់ទ្រព្យសម្បត្តិទាំងអស់ដែលពាក់ពន្ធ័ ត្រូវបានផ្តល់ការព្រឹក្សា និង យល់ព្រមទៅនឹងការចាត់ចែង ។ ការស្នើនឹងបញ្ចូលនូវ ការពណ៌នាមួយស្តីពី មនុស្សដែលរងផលប៉ះពាល់ ផលប៉ះពាល់ដែលពាក់ពន្ធ័(ឧទាហរណ៏ ដី ដើមឈើ ដំនាំ ផ្ទះសំបែង និង សំណង់ដទៃទៀត) និង កិច្ចព្រមព្រៀងដែលត្រូវបានធ្វើ(ឧទាហរណ៏ ធម្មជាតិ និង ចំនួននៃសំណង) ។ បុគ្គលិករបស់គំរោងនឹងរៀបចំនូវកិច្ចប្រជុំក្នុងភូមិ ដើម្បីផ្តល់ពត៌មានទៅអោយអ្នកភូមិ អំពីសិទ្ធិរបស់ពួកគេចំពោះសំណង និង ចំពោះជំរើសដែលអាចជ្រើសរើសបាន ដោយអនុលោមទៅតាមគោលការណ៏ណែនាំទាំងនេះ ។លិខិតផ្លូវការមួយនឹងបង្ហាញនូវកិច្ចពិភាក្សាដែលកើតឡើង និង កិច្ចព្រមព្រៀងដែលបានធ្វើនិងបញ្ចូលនូវចំនុច

ខាងក្រោមៈ

- សំរាប់ការបរិច្ចាគដោយស្មគ្រ័ចិត្តៈ ឈ្មោះអ្នកបរិច្ចាគ ពតិមានលំអិតនៃការបរិច្ចាគ និង ស្នាមមេដៃដោយឈ្មោះរបស់ ប្តីប្រពន្ធ និង ត្រូវបានយល់ព្រមដោយអាជ្ញាធរក្នុងស្រុក។
- សំរាប់ការកាន់កាប់ទ្រព្យសម្បត្តិ និង ដីធ្លីដែលជំទាស់នឹងសំណងៈ ឈ្មោះរបស់មនុស្សដែលរងផលប៉ះពាល់ ផលប៉ះពាល់ នឹងពតិមានលំអិតស្តីពី ប្រភេទ និង កំរិតនៃសំណង។

***២២.*** បុគ្គលិករបស់គំរោងនឹងផ្តល់នូវ លិខិតស្នាមមួយច្បាប់ទៅអោយមនុស្សដែលរងផលប៉ះពាល់ និង ឆ្លើយតបនៅក្នុងកិច្ចពិភាក្សាជាលក្ខណៈឯកជនជាមួយពួកគេម្នាក់ៗ អំពីសំនើរ និងតំរូវការរបស់ពួកគេសំរាប់ សំណង កិច្ចព្រមព្រៀង និងបណ្តឹងជាយថាហេតុមួយចំនួន។ ឯកសារនឹងត្រូវបានរក្សាទុកនៅក្នុងសំនុំឯកសាររបស់គំរោង ហើយអាចប្រើប្រាស់បានសំរាប់ធ្វើការត្រួតពិនិត្យតាមដាន និង ការគ្រប់គ្រង។ចំពោះសកម្មភាព រឺក៏ការផ្តល់អោយបន្ទាប់បន្សំជាមួយនឹងការកាន់-កាប់ដីធ្លី(ឧទារហណ៏ ធ្វើការប៉ះពាល់ដល់មនុស្សជាង១០០នាក់ រឺក៏ច្រើនជាង១០ភាគរយនៃកម្មសិទ្ធិរបស់មនុស្សដែលរងផលប៉ះពាល់ពីគំរោង) របាយការណ៏ស្តីពីការកាន់កាប់ដីធ្លីដាច់ដោយឡែកមួយនឹងត្រូវបានប្រើប្រាស់។ សំរាប់ការផ្តល់អោយបន្ទាប់បន្សំដែលត្រូវការនូវចលនាស្មគ្រ័ចិត្ត រឺក៏ការរើទីលំនៅដោយស្មគ្រ័ចិត្តនៃក្រុមគ្រួសារ រឺក៏ផ្ទះសំបែងច្រើនជាង៥នោះរបាយការណ៏ស្តីពីការរើទីលំនៅនឹងត្រូវបានប្រើប្រាស់។របាយការណ៏នឹងបញ្ចូលនូវ សមាសភាពដែលពាក់ពន្ធ័ដូចខាងក្រោមៈ

- ទិន្នន័យមូលដ្ឋានដែលធ្វើកំណត់ភិនភាគលើផលប៉ះពាល់ និង មនុស្សដែលរងផលប៉ះពាល់
- ការចាត់ចែងរៀបចំសំរាប់ ការផ្លាស់ប្តូរដីធ្លី រឺសំរាប់សំណងសំរាប់ចំណាយលើការផ្លាស់ទី ដោយរួមបញ្ចូលនូវហត្ថលេខា ដោយគ្រប់ម្ចាស់ដីដែលរងផលប៉ះពាល់ទាំងអស់ដោយធ្វើការឆ្លើយតបថា ការចាត់ចែងទាំងអស់គឺទទួលដោយភាពរីករាយ
- ការរៀបចំចាត់ចែងដើម្បីធានាអោយកិច្ចដំនើរការមានភាពសមរម្យ ដោយអ្នកម៉ៅការដែលពាក់ពន្ធ័ទៅនឹងសំណងសំរាប់ផលប៉ះពាល់បណ្តោះអាសន្ន។
- បញ្ជីឯកសារសំរាប់ទ្រព្យសម្បត្តិ(ក្រៅពីដីធ្លី) ដែលនឹងត្រូវការដើម្បីទុកជាផ្នែកមួយនៃកិច្ចសន្យាសំណង់ និងហត្ថលេខា ដោយគ្រប់ម្ចាស់ដីដែលរងផលប៉ះពាល់ទាំងអស់ដោយធ្វើការឆ្លើយតបថា ការចាត់ចែងទាំងអស់គឺទទួលដោយភាពរីករាយ
- បញ្ជីឯកសារអនុវត្តន៏ដែលបង្ហាញថា ដីដែលផ្លាស់ថ្មី នឹងត្រូវបានប្រគល់អោយមុនពេលការអនុវត្តរបស់គំរោងចាប់ផ្តើម។

- ធ្វើការត្រួតពិនិត្យបួង់ និងការវាស់វែងដីធ្លីដែលត្រូវបានបញ្ជាក់ដោយអ្នកភូមិ ធ្វើការបង្ហាញនូវដីដែលទទួលបាន និង ដីដែលផ្លាស់ថ្មីដែលផ្តល់អោយ ផ្តល់ពតិមានលំអិតអោយគ្រប់គ្រាន់ដើម្បីធ្វើការផ្ទៀតផ្ទាត់ ។ការចាត់ចែងសំរាប់ការផ្សព្វផ្សាយពតិមាន ការព្រឹក្សា និង និតិវិធីសំរាប់ធ្វើការបន្តនូវសារទុក្ខ ។

២៣. បុគ្គលិករបស់គំរោងនឹងជួយដល់អ្នកភូមិនៅក្នុងការរៀបចំនូវរបាយការណ៍ដែលចាំបាច់ ដែលនឹងត្រូវបានត្រួតពិនិត្យដោយអង្គភាពអនុវត្តគំរោង(PIUs) និង ត្រូវបានអនុញ្ញាតដោយអង្គភាពគ្រប់គ្រងគំរោង(PMU) ។ គ្មានការងារណាដែលត្រូវការនូវរបាយការណ៍កាន់កាប់ដីធ្លី រឺក៏របាយការណ៍នៃការតាំងទីលំនៅឡើងវិញ នឹងត្រូវបានអនុញ្ញាតឡើយ ប្រសិនបើរបាយការណ៍មិនត្រូវបានអនុញ្ញាតដោយគណកម្មការដឹកនាំថ្នាក់ខេត្ត និង ធនាគារពិភពលោកនោះ ។ ដូច្នេះ រាល់ការងារដែលត្រូវការ បំផ្លាញចោលនូវផ្ទះសំបែង រឺក៏ទទួលបានដីបង្កបង្កើនផលជាអចិន្ត្រៃ រឺក៏បណ្តោះអាសន្ននឹងត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ដោយបុគ្គលិករបស់គំរោង ។ដំនើរការរបស់ការត្រួតពិនិត្យនឹងបញ្ជាក់ថានឹងមិនមានការមិនពេញចិត្ត ពីប្រជាពលរដ្ឋ ហើយបញ្ជាក់ថាប្រជាជនដែលរងផលប៉ះពាល់ត្រូវបានផ្តល់ពតិមានអំពីសិទ្ធិរបស់ពួកគេចំពោះសំណង និង ធានាថាពួកគេយល់ព្រមជាមួយនឹងការចាត់ចែង ។

៥. ការរៀបចំនៃផែនការការងារនៃការរើលំនៅស្ថានឡើងវិញ (RAP)

***២៤.* RAPs** ពីរប្រភេទត្រូវបានគិតទុកសំរាប់ការងាររបស់ M-IRM(ចូរមើលលក្ខខណ្ឌវិនិច្ឆ័យនៅក្នុងឧបសម្ពន្ធ១):

- *ផែនការការងារនៃការរើលំនៅស្ថានឡើងវិញ (RAP)* ។ ក្នុងករណីដែលផលប៉ះពាល់នៃដីធ្លី និង ការកាន់កាប់នូវទ្រព្យសម្បត្តិដោយ ការងារ រឺគំរោងរងមិនសំខាន់[១] *RAP* សំរាប់ការងារ រឺគំរោងរងនីមួយៗ នឹងត្រូវបានរៀបចំអោយស្របទៅតាមគោលយោបាយ ។ RAPនីមួយៗនឹងបញ្ចូលនូវ: (ក) បញ្ជីសារពើភណ្ឌ (ខ) ការស្ទាប់ស្ទង់លើសេដ្ឋកិច្ចសង្គម (គ) សំណងដ៏ល្អិតល្អន់ និង ពតិមានស្តីពីការផ្តល់សិទ្ធិ (ឃ) ការចំណាយ និង គំរោងនៃការស្តារឡើងវិញ និង (ង)ការប៉ាន់ស្មានលើការចំណាយ និង ធនធានមូលនិធិ ។ គំរោងនៃផែនការត្រូវបានផ្តល់អោយនៅក្នុងឧបសម្ពន្ធ៤ ។ គំរោងនៃផែនការត្រូវបានផ្តល់អោយនៅក្នុងឧបសម្ពន្ធ៤ ។RAP នឹងត្រូវបានដាក់ទៅអោយធនាគារពិភពលោកត្រួតពិនិត្យសំរាប់ធ្វើការបញ្ជាក់មុនពេលដែលកិច្ចសន្យាត្រូវបានទទួលដឹងលឺ ។ការអនុវត្តន៏ និង សំណងរបស់ RAP ត្រូវតែ សំរេចដោយជោគជ័យ នៅមុនពេលការចាប់ផ្តើមលើការងារស៊ីវិល ។

២ ផលប៉ះពាល់ត្រូវបានចាត់ទុកថាតិចតួចប្រសិនបើមិនមានមនុស្សដែលរងផលប៉ះពាល់ត្រូវបានរស់នៅខ្ចាត់ខ្ចាយនោះ ហើយតិចជាង១០ភាគរយនៃព្រទ្យសម្បត្តិបង្កបង្កើតផលត្រូវបានបាត់បង់ ។

- ផែនការការងារតាំងទីលំនៅឡើងវិញដំពេលលេញ ។ក្នុងករណីដែលផលប៉ះពាល់នៃដីធ្លី និង ការកាន់កាប់ នូវទ្រព្យសម្បត្តិដោយ ការងារវីគំរោងរងគីសំខាន់[9] *RAP* សំរាប់ការងារ វីគំរោងរងនីមួយៗ នឹងត្រូវបានរៀបចំអោយ ស្របទៅតាមគោលយោបាយ ។RAP នឹងត្រូវបានដាក់ទៅអោយធនាគារពិភពលោកធ្វើការត្រួតពិនិត្យសំរាប់កិច្ចព្រមព្រៀង ។ RAPនីមួយៗនឹងបញ្ចូលនូវ: (ក) បញ្ជីសារពើភណ្ឌ (ខ) ការស្ទាប់ស្ទង់លើសេដ្ឋកិច្ចសង្គម (គ) សំណងដ៏ល្អិតល្អន់ និង ពត៌មានស្តីពីការផ្តល់សិទ្ធិ (ឃ) ការងារការអនុវត្តន៏ និង ការងារស្តារឡើងវិញ (ង) និតីវិធីសារទុក្ខ (ច)ការចាត់ចែងសំរាប់ការត្រួតពិនិត្យតាមដាន និង ការវាយតំលៃ (ឆ)កាលបរិច្ឆេទនៃការអនុវត្តន៏ និង (ជ) ការប៉ាន់ស្មានទៅលើការចំណាយ និង ធនធានមូលនិធិ ។ គំរោងនៃផែនការត្រូវបានផ្តល់អោយនៅក្នុង**ឧបសម្ពន្ធ័៥ ។** RAP នឹងត្រូវបានដាក់ទៅអោយធនាគារពិភពលោកត្រួតពិនិត្យ សំរាប់ធ្វើការបញ្ជាក់អោយច្បាស់ ។ ការអនុវត្តន៏ និង សំណងរបស់ RAP ត្រូវតែ សំរេច ដោយជោគជ័យ នៅមុនពេលការចាប់ផ្តើមលើការងារស៊ីវិល ។

### ៤.៣ គំរោងគោលនយោបាយសំរាប់ការដាក់ក៏រិតទៅលើលទ្ធភាពទាញយកធនធាន

២៥. ការគ្រប់គ្រងធនធានធម្មជាតិនឹងត្រូវបានអនុវត្តដោយសមាជិកក្នុងសហគមន៏ដែលពាក់ពន្ធ័ ដោយខ្លួនពួកគេផ្ទាល់ ដោយស្ថិតនៅក្រោមការគាំទ្រពី បុគ្គលិករបស់គំរោងដែលនឹងផ្តល់នូវការគាំទ្រទូទៅសំរាប់ ការអភិវឌ្ឍន៏លទ្ធភាពដោយរួមបញ្ចូលនូវការជួលសម្រាលលើផលប៉ះពាល់អវិជ្ជមានសំរាប់គំរោង ។ ការពង្រឹងលើច្បាប់ និងបញ្ញត្តិដែលជាហេតុនាំទៅរកការដាក់ក៏រិតនៃលទ្ធភាពទាញយកនូវធនធានធម្មជាតិ គឺជារឿងរ៉ាវដ៏សមស្រប ដែលប្រសិនបើដោះស្រាយមិនល្អនោះ វានឹងជិះឥទ្ធិពលដ៏អាក្រក់សំរាប់សហគមន៏ក្នុងស្រុក និង បំផ្លាញនូវការខិតខំប្រឹងប្រែងអភិរក្ស ។ធ្វើការដាក់ក៏រិតលើការទាញយកធនធាន គឺជាសមាសភាពដ៏សំខាន់សំរាប់ការគ្រប់គ្រងធនធាន ហើយនៅក្នុងតំណាក់កាលខ្លះវាត្រូវបានស្វែងរកនៅក្នុងប្រពន្ធ័មួយចំនួននៃការគ្រប់គ្រងតំបន់អភិរក្ស ។

២៦. សិទ្ធិនៃធនធានទូទៅតាមបែបប្រពៃណីគឺចេញមកពី ការប្រើប្រាស់ក្នុងតំបន់ រឺក៏ការប្រើប្រាស់តាមបែបដូនតា រឺក៏បង្កើតដោយខ្លួនឯង ហើយមិនពឹងផ្អែកទៅលើកម្មសិទ្ធិស្របច្បាប់ឡើយ ។ ការដាក់ក៏រិតទៅលើការប្រើប្រាស់ធនធានស្របច្បាប់ដោយអ្នកប្រើប្រាស់តាមបែបប្រពៃណី ឧទាហរណ៏ នៅក្នុងការអនុវត្តច្បាប់ជាក់លាក់ក្នុងតំបន់អភិរក្ស រឺក៏ សមាជិកនៅក្នុងសហគមន៏ដែលទទួលបានប្រយោជន៏ នឹងយល់ស្របទៅលើការដាក់ក៏រិតទៅលើលទ្ធភាពទាញយកធនធានដែលផ្អែកទៅលើ គោលការណ៏តម្លាភាព និង ដំនើរនៃការសំរេចចិត្តដែលពាក់ពន្ធ័ ដែលនឹងត្រូវបានបង្កើតនៅពេលចាប់ផ្តើម ហើយនឹងត្រូវបានពង្រឹងតាមរយៈកិច្ចដំនើរការនៃការអនុវត្តន៏គំរោងតាមរយៈការគាំទ្រដ៏សកមពីបុគ្គលិករបស់គំរោង និង ជាមួយនឹងការផ្តល់នូវទំរង់មួយចំនួននៃយន្តការណ៏សំណង ដើម្បីទូទាត់ទៅនឹងការបាត់បង់នៃការប្រើប្រាស់ធនធាន ។ យន្តការគ្រប់គ្រងបញ្ហានៅក្នុងសហគមន៏ ត្រូវបានបង្កើតជាផ្នែកមួយនៃគំរោងដោយស្ថិតនៅក្រោមការគាំទ្រពីបុគ្គលិករបស់

គំរោងដែលនឹងជា យន្តការណ៍ប៉ះប៉ូវជំងឺចិត្តជំហានដំបូង និង បឋម(ផ្នែក៤.៥) ។ជាពិសេស វិភាគទានជាទ្រព្យសម្បត្តិ និង ដីធ្លីដោយស្មគ្រ័ចិត្ត ព្រមទាំងការដាក់កំរិតនៃលទ្ធភាពទាញយកធនធាននឹងត្រូវបានគ្រប់គ្រងដោយពួកគេ ។គំរោងនឹងបង្កើត នូវសមត្ថភាព និង ការត្រួតពិនិត្យតាមដានលើពួកគេយ៉ាងជិតដល់ ។កិច្ចព្រមព្រៀងដែលបានដឹងជាមុនត្រូវបង្ហាញពីដំនើរ ការមួយនៃការពិគ្រោះដែលធានារថា ការសន្និដ្ឋាន និង លទ្ធផលដែលប្រកបដោយសមធមិសំរាប់ក្រុមដែលពឹងផ្អែកលើព្រៃ ឈើ និង ក្រុមដែលងាយរងគ្រោះបំផុត ។ យន្តការណ៍ផ្សេង១ដទៃទៀតនោះគឺអាចទៅរួច និង អាចត្រូវបានបញ្ចូលទៅក្នុង:

- ការគ្រប់គ្រងធនធានដែលនាំទៅរកផលិតផលដ៏ខ្ពស់ក្នុងពេលអនាគត
- ជំនួយជាមួយនឹងការរៀបចំផែនការ និង ការគ្រប់គ្រងធនធាន
- ជំនួយដល់សិទ្ធិនៃការទាញយកធនធានដ៏មានសុវត្ថិភាពដោយធ្វើការដកចេញនូវជនដែលមកពីខាងក្រៅដែលមិន ពេញចិត្តលើសិទ្ធិទាំងនេះ
- ការចំណាយសំរាប់ការចូលរួមរបស់អ្នកភូមិនៅក្នុងការយាមល្បាត រឺក៏សកម្មភាពគ្រប់គ្រងតំបន់អភិរក្សដទៃ ទៀត
- គាំទ្រសំរាប់ការអភិវឌ្ឍន៏សហគមន៏ រឺក៏សកម្មភាពចិញ្ចឹមជីវិតដែលមាននិរន្តភាពតាមរយ:ការបំរុងទុកដោយ ផ្ទាល់ពីមូលនិធិ រឺក៏ការឧបត្ថម្ភទៅលើផ្នែកនៃសហគមន៏ដើម្បីទាក់ទាញនូវមូលនិធិពីធនធានដទៃទៀត ។

៣ ផលប៉ះពាល់ត្រូវបានចាត់ទុកថាសំខាន់ប្រសិនបើលក្ខខណ្ឌខាងក្រោមពាក់ពន្ធ័:

- មនុស្សដែលរងផលប៉ះពាល់គឺរស់នៅខ្ចាត់ខ្ចាយ ហើយជាង១០ភាគរយនៃទ្រព្យសម្បត្តិបង្កបង្កើនផលរបស់គ្រួសារគឺត្រូវបាត់បង់ រឺក៏ មនុស្ស២០០នាក់ រឺក៏ច្រើនជាងនឹងត្រូវបានប៉ះពាល់សំរាប់គំរោងរងនីមួយ១(OD 4.12) ។

២៧. លទ្ធភាពទាញយកអាចត្រូវបានកំណត់នៅកន្លែងដែលអ្នកប្រើប្រាស់ មិនមានសិទ្ធិទាញយកធនធានប្រពៃណី រឺក៏ ប្រើប្រាស់ធនធានដោយខុសច្បាប់ដែលស្ថិតនៅក្រោមនិតិកម្មរបស់ជាតិ ។ សកម្មភាពខុសច្បាប់រួមមានការប្រើប្រាស់នូវ គ្រឿងផ្ទុះ អាវុធយោធា ថ្នាំពុល រឺក៏អគ្គិសនី នៅក្នុងការបរបាញ់ និង ការនេសាទ និង ការបរបាញ់ពូជសត្វខុសច្បាប់សំរាប់ លក់ ។

## ១. ដំនើរការអនុវត្តន៏

***២៨.*** នៅក្នុងករណីដែលការដាក់កំរិតលើលទ្ធភាពទាញយកធនធានត្រូវអនុវត្ត គំរោងនឹងបង្កើតនូវកិច្ចព្រមព្រៀងប្រើប្រាស់ ធនធាននៅក្នុងភូមិ ហើយនឹងធានានូវការយល់ព្រមពីសហគមន៏ មុនពេលដែលធ្វើការអនុវត្តច្បាប់នេះដែលនឹងនាំទៅរក ការដាក់កំរិតលើការទាញយកធនធានក្នុងចំណោមអ្នកប្រើប្រាស់ទូទៅ ។ មូលនិធិដាច់ដោយឡែកមួយត្រូវបានដាក់សំរាប់ ការអនុវត្តន៏សមាសភាព៣-២សំរាប់ការពិគ្រោះ និង ការអភិវឌ្ឍន៏ដែលជួយសំរួលសំរាប់របរចិញ្ចឹមជីវិត ដែលទទួលរងផល

ប៉ះពាល់ធ្ងន់ធ្ងរ។ សកម្មភាព ៣-២-១ នឹងគាំទ្រដល់ការបង្កើតនៃអង្គភាពគ្រប់គ្រងជលផលសហគមន៍ក្នុងខេត្ត Champasak Attapeu និង ខេត្ត Sekong នៅក្នុងប្រទេសឡាវ ព្រមទាំងខេត្តស្ទឹងត្រែង និង ក្រចេះនៅក្នុងប្រទេសកម្ពុជា។ ការផ្តត់ផ្តង់ដ៏សំខាន់នឹងរួមមាន (ក) ការបង្កើតនូវ គណកម្មការគ្រប់គ្រងជលផល (ការិយាល័យ គ្រឿងបរិក្ខារត្រួតពិនិត្យ និង តាមដាន និង ឧបករណ៏ផ្សេងៗទៀត ។ល។) ការបណ្តុះបណ្តាល និង ការបង្ហាញនូវរបរចិញ្ចឹមជីវិតច្រើនប្រភេទ(ការផ្តល់អោយរាយរង) (ខ) ការរៀបចំនៃផែនការអភិវឌ្ឍន៏សហគមន៏ ផែនការគ្រប់គ្រងជលផល ការកំណត់អត្តសញ្ញាណនៃរបរចិញ្ចឹមជីវិត និង ការកំណត់អត្តសញ្ញាណនៃហេដ្ឋារចនាសម្ពន្ធ័ ជាអទិភាព (គ) ធ្វើការផ្តល់ជំនួយជាថវិការដេល់ការវិនិយោគជាអទិភាពដែលបានជ្រើសទុក និង ការកសាងសមត្ថភាព។

២៩. បុគ្គលិករបស់គំរោងនឹងទទួលបន្ទុកសំរាប់ធ្វើការធានាដល់សំនុំឯកសារដ៏ត្រឹមត្រូវ ដើម្បីបង្ហាញនូវស្នាដៃនៃគោលដៅរបស់សមាសភាពរង(ឧ ដើម្បីបង្កើតនូវ ការគ្រប់គ្រងរួមគ្នាលើជលផលដែលមានមូលដ្ឋានក្នុងសហគមន៍អោយមានប្រសិទ្ធិភាព) និង គោលដៅអភិវឌ្ឍន៏របស់គំរោង(ឧ ដើម្បីបង្កើតនូវគំរូគន្លឹះ នៃការអនុវត្តន៏លើការគ្រប់គ្រងធនធានទឹករួមគ្នានៅក្នុងតំបន់ LMB)។ កន្លែងដែលសកម្មភាពដែលបានស្នើអនុវត្ត រួមមានសមាសភាពនៃកាងារប្រត្តិបត្តិ វារួមមានឯកសារដូចខាងក្រោមៈ

- កិច្ចព្រមព្រៀងនៃការប្រើប្រាស់ធនធានក្នុងភូមិមួយច្បាប់ ដែលរួមមានពតិមានលំអិតនៃធនធានដែលពាក់ពន្ធ័ នៃតំបន់រស់នៅរបស់ពួកគេ ចំនួនដែលដកចេញ និង ក្រុមអ្នកប្រើប្រាស់ ។ការដាក់កំរិតត្រូវបានអនុវត្ត។ យន្តការណ៏សំណងត្រូវបានយល់ព្រម ។យន្តការណ៏បណ្តឹង និង ការចាត់ចែងលើការត្រួតពិនិត្យតាមដានដែលពាក់ពន្ធ័។ ធ្វើការត្រួតពិនិត្យតាមដាន និង ធ្វើការរាយការណ៏ នឹងត្រូវបានធ្វើអោយបានច្រើនដើម្បី ទទួលបាននូវតំរូវការគាំពារ ដើម្បីត្រួតពិនិត្យការវិវឌ្ឍន៏នៃគំរោង។ គំរូតាងនៃកិច្ចព្រមព្រៀងលើការប្រើប្រាស់ធនធានក្នុងភូមិដែល មុខងាររបស់ឯកសារកិច្ចព្រមព្រៀង មិនត្រូវបានភ្ជាប់ជាមួយនឹងកិច្ចសន្យាអចិន្ត្រៃយ៏ឡើយ តែត្រូវធ្វើវាអោយកាន់តែច្បាស់សំរាប់អ្នកមនុស្សគ្រប់រូបដឹងថាការចាត់ចែងនោះគឺជាអ្វី ។កិច្ចព្រមព្រៀងក្នុងភូមិ នឹងត្រូវបានកែប្រែបន្ថែម និង កែលំអ រហូតដល់ការចាត់ចែងរៀបចំត្រូវបាន យល់ថាគឺសមស្របសំរាប់មនុស្សរាល់គ្នា ។កិច្ចព្រមព្រៀង និង យន្តការណ៏បណ្តឹងរបស់គំរោងត្រូវតែត្រូវបានបង្ហាញនៅក្នុងភូមិនៅតាមតំបន់ដែលវាអាចផ្សព្វផ្សាយទៅកាន់មនុស្សទាំងអស់។

- របាយការណ៏ខ្លីមួយដែលលំអិតនូវដំនើរការនៃការពិគ្រោះដែលនាំទៅរកកិច្ចព្រមព្រៀង។ វានឹងផ្តល់នូវពតិមានលំអិតនៃវិធីសាស្រ្តសំរាប់ធ្វើការធានានូវ ការបញ្ចូលនៃក្រុមរងដែលពាក់ពន្ធ័ទាំងអស់នៅក្នុងសហគមន៏។ ប្រសិនបើសហគមន៏រាប់បញ្ចូលទាំងក្រុមជនជាតិ របាយការណ៏នឹងពន្យល់យ៉ាងលំអិតពីវិធីដែល គំនិត និង តំរូវការត្រូវដែលបានបញ្ចូល ជាទូទៅ

តាមរយៈ ការបញ្ចូលនូវការពិភាក្សាដែលមិនមានការរើសអើង និង ការប្រើប្រាស់នូវភាសាក្នុងតំបន់គ្រប់ពេលដែលអាចទៅរួច។

៣០. កំឡុងពេលការរៀបចំនៃ M-IWRM អ្នកភូមិបានកត់សំគាល់ពីប្រយោជន៏នៃការគ្រប់គ្រងធនធានដ៏តឹងរឹង និង ចង់បង្កើតនូវច្បាប់នៅក្នុងការភ្ជាប់ រដ្ឋាភិបាលក្នុងស្រុកជាមួយនឹងគំរោង។ ទោះបីជាយ៉ាងណាក៏ដោយ វាត្រូវបានគេរំពឹងថាការមកដល់នូវកិច្ចព្រមព្រៀងប្រើប្រាស់ធនធានក្នុងភូមិនឹងក្លាយជាដំនើរការយឺតៗសំរាប់ធ្វើការបង្កើននូវកិច្ចសហប្រតិបត្តិ-ការ និង ចំណេះដឹង ដែលនឹងត្រូវការជំនាញពិសេសជាមួយនឹងការព្រឹក្សា និង វិធីសាស្ត្រដែលពាក់ពន្ធ័។សមាជិករបស់សហគមន៏នឹងទទួលបានប្រយោជន៏ពី ការសិក្សាទៅលើវិធីដ៏ល្អដើម្បីគ្រប់គ្រងបណ្តឹង និង បញ្ហាក្នុងភូមិដើម្បីអភិវឌ្ឍន៏នូវការគ្រប់គ្រងធនធានជលផល និង ធនធានទឹកអោយមាននិរន្តរភាព។ គំរោងនឹងគាំទ្រដល់សហគមន៏អោយសិក្សា និង ពង្រឹងលើយន្តការណ៏។ ការពិនិត្យវិច័យនេះត្រូវបានសហការណ៏នៅក្នុងការរៀបចំផែនការណ៏សំរាប់សមាសភាពរង ៣-២។

## ៤.៤ ការត្រួតពិនិត្យតាមដាន និង ការផ្សព្វផ្សាយពតិមាន

៣១. ការត្រួតពិនិត្យតាមដានផ្ទៃកខាងក្នុង ការអនុវត្តន៏របស់ RPF នឹងត្រូវបានចាត់ចែង និង ត្រួតពិនិត្យតាមដានយ៉ាងទៀតទាត់ដោយអង្គភាពអនុវត្តគំរោង (PIUS)ដែលទទួលបន្ទុកសំរាប់ការអនុវត្តន៏ និង ការងារវិនិយោគដែលពាក់ពន្ធ័ទៅនឹងការកាន់កាប់ដីធ្លី និងរឺក៏ ការដាក់កំរិតលើលទ្ធភាពទាញយកធនធាន។ការវិនិច្ឆ័យ និង ការផ្តល់ជាអនុសាសន៏នឹងត្រូវបានកត់ត្រាទុកនៅក្នុងសំនុំឯកសាររបស់គំរោង សំរាប់ការត្រួតពិនិត្យឡើងវិញដោយធនាគារពិភពលោក។ អង្គភាពគ្រប់គ្រងគំរោង(PMU)នឹងចាត់ចែង និង ត្រួតពិនិត្យតាមដានលើដំនើរការយ៉ាងហោចណាស់ មួយដងក្នុងមួយឆ្នាំ និង បូកបញ្ចូលលទ្ធផលទៅក្នុង របាយការណ៏ប្រចាំឆ្នាំរបស់គំរោង និង ផ្តល់វាទៅអោយធនាគារពិភពលោក។ បុគ្គលិករបស់គំរោង(PIUs និង PMU)ស្ថិតនៅក្នុងការព្រឹក្សាដ៏ជិតស្និទជាមួយនឹងរដ្ឋាភិបាលក្នុងស្រុក ហើយ PAPs នឹងបង្កើតនូវសំនុំនៃសន្ទស្សន៏នៃការត្រួតពិនិត្យតាមដានដ៏ប៉ិនប្រសព្វ ដោយស្របទៅតាមគោលការណ៏នៃនាំផ្នែកបច្ចេកទេស(ឧបសម្ពន្ធ័១)។

៣២. ការត្រួតពិនិត្យតាមដានពីខាងក្រៅៈ ការងារវិនិយោគជាមួយនឹង RAP នឹងត្រូវបានដាក់នៅក្រោមការត្រួតពិនិត្យតាមដានដោយទីភ្នាក់ងារដ៏ត្រឹមត្រូវ និង អ្នកព្រឹក្សាដ៏ជំនាញឯករាជមួយ។ទីភ្នាក់ងារត្រួតពិនិត្យតាមដាន រឺក៏អ្នកព្រឹក្សាពីខាងក្រៅគួរតែត្រូវបានជួលដោយស្ថិតនៅក្រោមអំណះអំណាងដែលផ្តល់នូវភាពជាក់លាក់នៃភាពទូទៅនៃវិធីសាស្ត្រនៃការត្រួតពិនិត្យតាមដាន ការបង្កើតនូវគំរូតាង ការសំភាស និង តំរូវការនៃការរាយការណ៏។ របាយការណ៏នៃការត្រួតពិនិត្យ

តាមដាននឹងត្រូវបានថែទាំដោយ PMU នឹងត្រូវបានបង្កើតដើម្បីផ្តល់អោយក្រុមចាត់ចែងរបស់ធនាគារពិភពលោកអាចប្រើប្រាស់បាន ។

៣៣. ការផ្សព្វផ្សាយពត៌មានៈ គំរោងនឹងផ្សព្វផ្សាយនូវរបាយការណ៍ដែលអាចប្រើប្រាស់បានទាំងអស់ជាសាធារណៈ ដោយធ្វើការបង្ហាញវានៅក្នុងគេហទំព័ររបស់គំរោង ដែលបានបង្កើតឡើងនៅក្នុងការិយាល័យPMU ។

## ៤.៥ តម្លាភាព និង យន្តការណ៍សារទុក្ខ

៣៤. គោលនយោបាយនៃការរើលំនៅស្ថានឡើងវិញរបស់ធនាគារពិភពលោកតំរូវអោយគំរោងវិនិយោគ បង្កើតនូវយន្តការណ៍សំរាប់ដំណោះស្រាយជំងឺចិត្ត និង កំណត់ថា ទំនួលខុសត្រូវជាបឋមសំរាប់ធ្វើការដោះស្រាយនូវជំងឺចិត្តដែលត្រូវបានលើកឡើងដោយប្រជាជនដែលរងគ្រោះពីគំរោង(PAPs)គឺជាអ្នកបង្កើតគំរោង ។យន្តការណ៍នេះមានបំណងដើម្បីធានានូវភាពពេញចិត្តរបស់ PAPs ជាមួយនឹងការអនុវត្តន៏នៃ RAP និងផ្តល់អោយ PRPsជាមួយនឹងគោលនយោបាយស្របច្បាប់សំរាប់ការត្រួតពិនិត្យតាមដាន និង ការរាយការណ៍ស្តីពី ការអនុវត្តន៏របស់RAP ។ ជាពិសេសនោះ គោលបំណងរបស់យន្តការណ៍សារទុក្ខគឺត្រូវអនុញ្ញាតអោយ PAPs និង ប្រជាជនដែលប្រាកដថា ពួកគេគឺជាមនុស្សដែលរងផលប៉ះពាល់ដើម្បីស្វែងរកនូវដំណោះស្រាយដ៏ពេញចិត្តសំរាប់ជំងឺចិត្តដែលអាចមានទំនាក់ទំនងជាមួយនឹងការដាក់កំរិតនៃលទ្ធភាពទាញយកធនធានមានជីវិតនៅក្នុងទឹក និង ការកាន់កាប់ដីធ្លី និង អន្តរាគមន៏នៃគំរោងដ៏ទៃទៀត ។ គោលការណ៏គន្លឹះសំរាប់យន្តការណ៍សារទុក្ខគឺត្រូវតែធានាថាៈ

- ចំនាប់អារម្មណ៏ និង សិទ្ធិជាមូលដ្ឋាននៃ PAPs ត្រូវបានការពារ
- ការព្រួយបារម្ភរបស់ PAPs ដែលចេញមកពីដំនើរការអនុវត្តន៏របស់គំរោងត្រូវបានដោះស្រាយដោយសមរម្យ
- ការផ្តល់សិទ្ធិ រឺក៏ការផ្គត់ផ្គង់ជីវភាពសំរាប់ PAPsត្រូវបានផ្តល់អោយទាន់ពេលវេលា និង ស្របទៅតាមជាមួយនឹងរដ្ឋាភិបាល និង គោលនយោបាយគាំពាររបស់ធនាគារពិភពលោក
- PAPs ដឹងពីសិទ្ធិរបស់ពួកគេដើម្បីប្រើប្រាស់នូវនិតិវិធីសារទុក្ខដោយគ្មានការចំណាយសំរាប់គោលបំណងខាងលើ

៣៥. ក្នុងដំណាក់កាលដំបូងនៃការអនុវត្តន៏គំរោង គណកម្មការប៉ះប៉ូវសារទុក្ខ នឹងត្រូវបានបង្កើតឡើងពី កំរិតថ្នាក់ភូមិទៅដល់ថ្នាក់ខេត្ត ដែលបង្កើតលើរចនាសម្ពន្ធ័ដែលមានស្រាប់ ដែលរួមមាននាយកដ្ឋានគិតគូរ អង្គការធំៗ អ្នកតំណាងអោយក្រុមជនជាតិ និង ស្ត្រី ។នៅក្នុងដំណាក់កាលថ្នាក់ភូមិ រចនាសម្ពន្ធ័ដែលត្រូវបានហៅថាជា គណកម្មការគិតគូរក្នុងភូមិត្រូវបានដឹកនាំដោយមនុស្សចាស់ និង មេដឹកនាំកុលសម្ពន្ធ័ដែលទទួលស្គាល់ដោយសហគមន៏ក្នុងស្រុក ជាពិសេសក្រុមជនជាតិភាគតិច ។គំរោងនឹងផ្តល់អោយនូវការបណ្តុះបណ្តាល និង ការឧបត្ថម្ភដើម្បីពង្រឹងនូវរចនាសម្ពន្ធ័ដែលមានស្រាប់សំរាប់ធ្វើការ

ដោះស្រាយជាមួយនឹងជំងឺចិត្តដែលអាចទៅរួច ដែលអាចត្រូវបានលើកឡើងដោយ PAP កំឡុងពេលនៃការអនុវត្តរបស់ PAP ។

៣៦. ចំពោះ PAPs ប្រសិនបើមិនច្បាស់ និង មិនពេញចិត្តចំពោះការអនុវត្ត និង សំណងរបស់ RAPនោះ អាចលើកបណ្តឹងរបស់ពួកគេទៅអោយគណកម្មការថ្នាក់ភូមិ ។ការអះអាងអាចត្រូវបានធ្វើដោយផ្ទាល់មាត់ រឺក៏សសេរជាមួយនឹងជំនួយពីគណកម្មការភូមិដែលផ្តល់នូវការឆ្លើយតប ទៅកាន់អ្នកតវ៉ាក្នុងរយៈពេល៥ថ្ងៃបន្ទាប់ពីការចេញលិខិតជំងឺចិត្ត ។ប្រសិនបើអ្នកតវ៉ាមិនសប្បាយចិត្តជាមួយនឹងការសំរេចដែលធ្វើឡើងដោយថ្នាក់ភូមិនោះ ពួកគេអាចដាក់ការតវ៉ាទៅកាន់គណកម្មការថ្នាក់ស្រុកជាមួយនឹងការគាំទ្រពី PIUs ។ ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីការលិខិតតវ៉ា គណកម្មការស្រុកនឹងធ្វើការសំរេចចិត្ត និងផ្តល់នូវការឆ្លើយតបទៅកាន់អ្នកតវ៉ា។ ការតវ៉ាអាចត្រូវបានប្តឹងទៅកាក់តុលាការខេត្ត ដែលការវិនិច្ឆ័យនឹងត្រូវបានសំរេចចុងក្រោយ ។គ្រប់អ្នកតវ៉ា និង ជំងឺចិត្តទាំងអស់នឹងត្រូវបានរៀបចំ និង កត់ត្រាយ៉ាងត្រឹមត្រូវដោយគណកម្មការថ្នាក់ភូមិ និងថ្នាក់ស្រុក ព្រមទាំងPIUs ដែលត្រូវបានដោះស្រាយតាមរយៈការព្រឹក្សាទៅក្នុងតម្លាភាព និង ទង្វើទុកជាមុន។ ឯកសារសារទុក្ខ និង របាយការណ៏ទាំងនេះនឹងត្រូវបានដាក់អោយប្រើប្រាស់ជាសាធារណៈ។ ការចំនាយទាំងអស់ដែលពាក់ពន្ធ័ជាមួយនឹងដំនើរការដោះស្រាយជំងឺចិត្តដែលត្រូវបានជួបប្រទះដោយ អ្នកតវ៉ា និង អ្នកតំណាងរបស់ពួកគេនោះត្រូវបានគ្រប់គ្រងដោយអ្នកបង្កើតគំរោង ។ដំនើរការដោះស្រាយសារទុក្ខត្រូវបានពណ៌នាដូចខាងក្រោមៈ

| និតិវិធី | យុត្តាធិការ | ពេលវេលាឆ្លើយតប | ស្ថាប័ន/ផ្នែកទទួលបន្ទុក | មធ្យោបាយផ្ទៀងផ្ទាត់/ឯកសារ |
|---|---|---|---|---|
| ជំហានទី១ ថ្នាក់ ភូមិ | ការតវ៉ារបស់មតិសាធារណៈ/អ្នកដែលទទួលផលប្រយោជន៏ រឺប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ | រយៈពេល ៥ ថ្ងៃ | មេភូមិ និងគណៈកម្មាការ ភូមិ | របាយការណ៏ស្តីពីផលប៉ះពាល់ (សារទុក្ខ) តាមរយៈ ជំនួយរបស់ផ្នែកគ្រប់គ្រងថ្នាក់ខេត្ត ។ការស្នើសុំប្រចាំត្រីមាសនៃឈ្មោះ និងព័តិមានពាក់ព័ន្ធអំពីការតវ៉ានានា មូលហេតុនៃការទាមទារ ថ្ងៃ ខែ នៃការតវ៉ាដែលបានប្តឹង និងដំណោះស្រាយនៃផ្នែកគ្រប់គ្រងថ្នាក់ខេត្ត ។ |
| ជំហានទី ២- ថ្នាក់ ស្រុក | ការិយាល័យអង្គាធរស្រុក | រយៈពេល ១៥ ថ្ងៃ | អង្គាធរស្រុក/ ផ្នែកគ្រប់ គ្រងថ្នាក់ខេត្ត | របាយការណ៏ស្តីពីផលប៉ះពាល់ (សារទុក្ខ) ពីគណកម្មការភូមិ តាមរយៈ ជំនួយពីផ្នែកគ្រប់គ្រងថ្នាក់ខេត្ត ។<br>ការដាក់ស្នើសុំប្រចាំត្រីមាសនៃឈ្មោះនិងព័តិមាន |

| | | | | |
|---|---|---|---|---|
| | | | | ពាក់ព័ន្ធអំពី ការតវ៉ានានាមូលហេតុនៃការទាមទារ ថ្ងៃ ខែនៃការតវ៉ាដែល បានប្ដឹង និងដំណោះស្រាយ នៃ ផ្នែកគ្រប់គ្រងថ្នាក់ខេត្ត ។ |
| ជំហានទី ៣- ថ្នាក់ខេត្ត | ការិយាល័យរដ្ឋាភិបាលថ្នាក់ខេត្ត | រយះពេល ១០ ថ្ងៃ | រដ្ឋាភិបាលថ្នាក់ខេត្ត/ផ្នែកគ្រប់គ្រងគម្រោង | របាយការណ៏ស្ដីពីផលប៉ះពាល់(សារទុក្ខ)ពី គណកម្មការ ភូមិ និង អង្គាធរស្រុក តាមរយះជំនួយពី ផ្នែកគ្រប់គ្រងគម្រោង ។ ការដាក់ស្នើសុំប្រចាំត្រីមាសនៃឈ្មោះនិងព័ត៌មានពាក់ព័ន្ធអំពី ការតវ៉ានានា មូលហេតុនៃការទាមទារ ថ្ងៃ ខែ នៃការតវ៉ាដែលបានប្ដឹងនិងដំណោះស្រាយនៃផ្នែកគ្រប់គ្រងគម្រោង ។ |

**ឧបសម្ពន្ធ័១ គោលការណ៏ណែនាំនៅពេល កម្មសិទ្ធិដីធ្លី សំណង វិភាគទានមិនស្ម័គ្រចិត្តត្រូវបានពាក់ពន្ធ័នៅក្នុងការងារវិនិយោគ និងគំរោងរង**

**បញ្ជីមាតិកា**

ក១.១ និយមន័យពាក្យបច្ចេកទេស

ក១.២ តំរូវការមូលដ្ឋានសំរាប់គោលនយោបាយគាំពាររបស់ធនាគារពិភពលោក

ក១. ៣ សំណង និង ការផ្ដល់សិទ្ធិ

១. សិទ្ធិទទួលបាន

២. ការផ្ដល់សិទ្ធិ

៣. វិភាគទានស្ម័គ្រចិត្ត

៤. ការរើទីកន្លែង និង យុទ្ធសាស្ត្រប៉ះប៉ូវប្រាក់ចំណូល

៥. ភាពងាយរងផលប៉ះពាល់ យែនឌ័រ និង ក្រុមជនជាតិ

៦. ប្រជាជនក្នុងស្រុក

ក១.៤ ការអនុវត្តន៏ និង រៀបចំផែនការការងារនៃការរើលំនៅស្ថានឡើងវិញ

ក១.៥ ការព្រឹក្សាសហគមន៏ និង ដំនើរការដែលពាក់ពន្ធ័

ក១.៦ យុទ្ធសាស្ត្រយែនឌ័រ

ក១. ៧ ការប៉ះប៉ូវជំងឺចិត្ត

ក១. ៨ ការត្រួតពិនិត្យតាមដាន និង វាយតំលៃ

ក១. ៩ គោលនយោបាយរបស់ធនាគារពិភពលោកសំរាប់ការព្រឹក្សា និង ការផ្សព្វផ្សាយពតិមាន

## និយមន័យនៃពាក្យបច្ចេកទេស

និយមន័យនៃពាក្យគន្លឹះមានដូចខាងក្រោមៈ

**អ្នកទទួលផល**- រាល់បុគ្គល និងគ្រួសារមកពីតាមបណ្តាភូមិ ដែលស្វែងរកដោយស្មគ្រ័ចិត្តដើម្បីឱ្យប្រយោជន៏នៃ រឺជាផ្នែកនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ

**ការផ្តល់សំណង**- ការចំណាយជាសាច់ប្រាក់ រឺប្រភេទនៃការចំណាយលើការផ្លាស់លំនៅដ្ឋាននៃទ្រព្យសម្បត្តិដែលបានតម្រូវ

**ពេលវេលា-** ពេលវេលាដែលធ្វើការសម្រេចចិត្តស្តីពីអ្នកទទួលផលដែលផ្តោតលើ និងការទទួលដីធ្លីនៃតំបន់នានារបស់គម្រោងដែលត្រូវបានចេញឱ្យដោយអាជ្ញាធរដែលមានសមត្ថកិច្ច និងដែលបានប្រកាសជាសាធារណៈទៅដល់សហគមន៏ដែលផ្តោតលើមួយចំនួន និងទៅដល់ប្រជាពលរដ្ឋដែលប៉ះពាល់ រឺផ្លាស់ទីលំនៅដ្ឋាន។

**ការផ្តល់សិទ្ធិ**- លំដាប់នៃវិធានការនានារួមមាន ការផ្តល់សំណង ការជួសជុសប្រាក់ចំណូល ជំនួយការក្នុងការផ្លាស់ប្តូរ ប្រាក់ចំណូលនៃការតាំងលំនៅដ្ឋានឡើងវិញ និងការយកមកជំនួសដល់ប្រជាពលរដ្ឋដែលទទួលរងនូវប៉ះពាល់ដែលពឹងទៅលើធម្មជាតិដែលពួកគេបាត់បង់ ដើម្បីស្តារឡើងវិញនូវផ្នែកសង្គម និងសេដ្ឋកិច្ចរបស់ពួកគេ។

**គ្រួសារ**- មានន័យថារាល់មនុស្សដែលកំពុងរស់នៅ និងហូបចុករួមគ្នាដែលជាផ្នែកនៃសង្គមតែមួយ។ ការជំរឿនដែលបានប្រើប្រាស់នូវនិយមន័យនេះ និងព័តិមានដែលបានធ្វើឡើងតាមរយៈជំរឿនបង្កើតនូវមូលដ្ឋានសម្រាប់ការកំណត់នូវគ្រួសារ។

**ការប៉ះប៉ូវប្រាក់ចំណូលឡើងវិញ**- មានន័យថា បង្កើតនូវប្រភពប្រាក់ចំណូលឡើងវិញ និងជីវភាពរស់នៅនៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ទៅក្នុងកម្រិតនៃមុនពេលគម្រោងរបស់ពួកគេ។

**ការលើកកម្ពស់**- រចនាសម្ពន័ដែលបានសាងសង់ (ការរស់នៅ របង រោងតូច១ ទ្រុងជ្រូក សារៈប្រយោជន៏នានា មធ្យោបាយនានា សហគមន៏ តូប ឃ្លាំងអីវ៉ាន់.....។ល។) និងធញ្ញជាតិ ដើមឈើដែលបានដាំដោយប្រជាពលរដ្ឋ គ្រួសារ រឺអង្គភាព (ក្រុម)។

**សិទ្ធិកាន់កាប់ដីធ្លី**- ជាដំណើរការដែលបុគ្គលម្នាក់ដែលត្រូវបានបង្គាប់-ផ្តល់ដោយភ្នាក់ងាររដ្ឋាភិបាលដើម្បីផ្ទេរសិទ្ធិទាំងអស់ រឺ ផ្នែកខ្លះ១នៃដីដែលបុគ្គលនោះកាន់កាប់ដើម្បីធ្វើជាម្ចាស់ និងកាន់កាប់នៃភ្នាក់ងាររដ្ឋាភិបាលសម្រាប់គោលបំណងសាធារណៈ ដើម្បីផ្លាស់ប្តូរសម្រាប់ធ្វើការពិចារណា។

**ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ដោយគម្រោង-** រួមមានទាំងប្រជាពលរដ្ឋទាំងឡាយណា រឺអង្គភាព រឺអង្គការដែលបានទទួលផលប៉ះពាល់ដោយគម្រោង អ្នកដែលស្ថិតនៅក្រោមករណីនៃអ្នកដែលមិនស្ម័គ្រចិត្តទទួលយកនៃទ្រព្យ-សម្បត្តិនៅក្នុងការគាំទ្រលើការអនុវត្តនៃគម្រោងអ្នកទាំងនោះគួរមាន (១). កម្រិតនៃការរស់នៅដែលបានទទួលផលប៉ះពាល់អាក្រក់ (២). សិទ្ធិ សិទ្ធិទទួល រឺ រាល់ផលប្រយោជន៍ រឺផ្នែកផ្សេងៗទៀតនៃផ្ទះ និងសំណង់នានា ដី (រួមទាំងដីតាំងលំនៅដ្ឋាន ជំនួញ កសិកម្ម ចំការធំៗ ព្រៃឈើ និងដីវាលស្មៅ) ធនធានទឹក ស្រះត្រី ដែននេសាទតាមឃុំ ឈើហូបផ្លែ និងដំណាំដែលមានរយៈពេលតាមរដូវ រឺរយពេលយូរ រឺទ្រព្យសម្បត្តិ ដែលអាចផ្លាស់ប្តូរបាន រឺមិនអាចផ្លាស់ប្តូរបានដែលត្រូវបានតម្រូវ រឺកាន់កាប់ទាំងស្រុង រឺដោយផ្នែកខ្លះៗ ដោយអចិន្ត្រៃ រឺបណ្តោះអាសន្ន និង (៣). មុខរបរ វិជ្ជាជីវះ ការងារ រឺប្រភពនៃប្រាក់ចំណូល និងជីវភាពរស់នៅដែលបាត់បង់ទាំងស្រុង រឺផ្នែកខ្លះៗ ដោយអចិន្ត្រៃ រឺបណ្តោះអាសន្ន។

**តម្លៃនៃការផ្លាស់ប្តូរ-** គឺជាពាក្យដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់នូវចំនួនគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរនូវទ្រព្យសម្បត្តិដែលបាត់បង់នានា និងដែលរួមបញ្ចូលទាំងតម្លៃស្រុះស្រួល។ នៅពេលដែលច្បាប់នៅតាមមូលដ្ឋានមិនបំពេញនូវស្តង់ដានៃការផ្តល់សំណងពេញលេញនៃតម្លៃនៃការផ្លាស់ប្តូរ សំណងស្ថិតនៅក្រោមច្បាប់នៅតាមមូលដ្ឋានគឺត្រូវបានបន្ថែមតាមរយៈភាពចាំបាច់នៃនីតិវិធី ដើម្បីឱ្យស្របទៅ តាមកម្រិតស្តង់ដាតម្លៃ។

**ការតាំងលំនៅស្ថានឡើងវិញ-** គឺជាពាក្យទូទៅដែលទាក់ទងទៅនឹងការផ្តល់ដី និងសំណងសម្រាប់ការបាត់បង់នៃទ្រព្យសម្បត្តិ ទោះបីជាពាក់ពន្ធ័ជាមួយការតាំងលំនៅថ្មីជាក់ស្តែង ការបាត់បង់ដី ជម្រក ទ្រព្យសម្បត្តិ រឺជីវភាពរស់នៅ។

**ក្រុមដែលងាយទទួលរងនូវផលប៉ះពាល់-** គឺជាក្រុមដែលផ្សេងៗនៃមនុស្សដែលអាចទទួលនូវភាពឈឺចាប់ដោយមិនស្មើភាព រឺប្រឈមទៅនឹងភាពគ្រោះថ្នាក់នៃការគម្រាមកំហែងនាពេលខាងមុខដោយ សារផលប៉ះពាល់នៃការតាំងលំនៅដ្ឋានឡើងវិញ និងជាពិសេសផលប៉ះពាល់ទាំងនោះរួមមានះ (១). គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មនុស្សចាស់ រឺពិការ (២). គ្រួសារដែលរស់នៅស្ថិនៅក្រោមភាព ក្រីក្រខ្លាំង (៣). គ្រួសារដែលគ្មានដី និងទី (៤). ក្រុមជនជាតិដើមភាគតិច។

## ក១.២ តំរូវការមូលដ្ឋានសំរាប់គោលនយោបាយគាំពារសង្គមរបស់ធនាគារពិភពលោក

***២. តំរូវការស្នូល*** តារាងសង្ខេបទី១ស្តីពីគោលនយោបាយសុវត្ថិភាពសង្គមរបស់ធនាគារពិភពលោកនិងតម្រូវការសំខាន់ៗរបស់ខ្លួនដែលស្ថិតនៅក្រោមគោលនយោបាយសុវត្ថិភាពនីមួយៗះ

តារាងទី១

| **គោលនយោបាយធនាគារពិភពលោក** | **ការសង្ខេបនៃតម្រូវការសំខាន់ៗ** | **ការពិគ្រោះយោបល់ជាសាធារណៈ** |
|---|---|---|
| ការតាំងទីលំនៅដ្ឋានឡើងវិញដោយមិនយល់ស្របនិងការទទួលបានមកវិញនូវដី (OP/BP 4.12) | គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនឹងត្រូវអនុវត្តគោលការណ៍នៃសំណង និងការតាំងលំនៅដ្ឋាន ដើម្បីធានាថាមនុស្សដែលបានប៉ះពាល់របស់គម្រោងនឹងត្រូវបានសងសម្រាប់ការបាត់បង់របស់ពួកគេតាមតម្លៃនៃការប្តូរទីតាំង និងត្រូវផ្តល់នូវវិធានការស្តាបនាឡើងវិញដើម្បីជួយដល់ពួកគេលើកកម្ពស់ រឺយ៉ាងហោចណាស់ថែរក្សាសមត្ថភាពនៃការរកប្រាក់ចំណូល និងស្តង់ដាជីវភាពរស់នៅ។ | ពិគ្រោះជាមួយប្រជាពលរដ្ឋដែលបានទទួលរងផលប៉ះពាល់ពីគម្រោង និងសហគមន៍ដើម្បី សហការណ៍សំដែងនូវទស្សនៈនានានៅក្នុងផែនការតាំងលំនៅដ្ឋាន ឡើងវិញ កត់ត្រានូវជម្រើសនានារបស់ប្រជាពលរដ្ឋដែលទទួល ផលប៉ះពាល់ពីគម្រោង។ |
| ជនជាតិដើមភាគតិច (OD 4.20) | គម្រោងនឹងអនុវតតាមគោលការណ៍សំខាន់ៗនៃគោលនយោ-បាយធនាគារពិភពលោកទាក់ទងទៅនឹងក្រុមជាជាតិដើមភាគតិចដែល "ធានាថាក្រុមជនជាតិដើមភាគតិចមិនមានការឈឺចាប់ដោយសារផលប៉ះពាល់ជាអវិជ្ជមានក្នុង កំឡុងនៃដំណើរការនៃការអភិវឌ្ឍន៏" និងប្រាកដថាពួកគេទទួល "ផល-ប្រយោជន៏ នៃសេដ្ឋកិច្ច និងសង្គម ស្រុះស្រួលក្នុងផ្នែកវប្បធម៌"។ ក្រុមជនជាតិរដើមភាគតិចត្រូវបានយកចិត្តទុកដាក់ពីគម្រោង M-IWRMP ។ | ដើម្បីពិគ្រោះជាមួយក្រុមជនជាតិដើមភាគតិចពីផែនការវិនិយោគ ការអនុវត្តនិងការវាយតម្លៃ លើការតាមដាននិងវាយតម្លៃ។ ទាក់ទងជា មួយអង្គការពាក់ព័ន្ធក្រៅរដ្ឋាភិបាលនានាដើម្បីជួយនៅក្នុងផែនការវិនិយោគនិងការរៀបចំនិងការអនុវត្តនៃផែនការអភិវឌ្ឍន៏ក្រុមជនជាតិ ជាតិដើមភាគតិច។ |
| ធនធានវប្បធម៌រូបសាស្ត្រ (OP 4.11) | គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនឹងត្រូវបានតាមដាន និងផ្តល់នូវសារពើភណ្ឌ័នៃធនធានវប្បធម៌នានាដែលអាចមានសក្តដានុពលប៉ះពាល់។ | ចងក្រងឯកសារ និងពិគ្រោះយោបល់នូវធនធាន ដែលប៉ះពាល់ដោយគម្រោងដល់ប្រជាពលរដ្ឋដោយទាក់ទង ជាមួយមន្ត្រី ថ្នាក់ជាតិ ខេត្ត និងស្រុក/អាជ្ញាធរ និងអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធនានា។ |

***៣. ការគាំពារសង្គម និង ឯកសារដែលត្រូវការ*** គ្រប់គំរោងវិនិយោគ និង រាល់ការងារទាំងអស់នឹងរៀបចំការគាំពារសង្គមដើម្បីកំណត់ភិនភាគនៃផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ និង វិធានការជួយសំរាលដ៏ត្រឹមត្រូវ( ចូរមើលនៅក្នុងឧបសម្ពន្ធ័២) ហើយប្រសិនបើការកម្មសិទ្ធដីធ្លី និង ទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ត្រូវបានពាក់ពន្ធ័ ផ្តល់នូវពតិមានលំអិតបន្ថែមលើដីធ្លី និង ទ្រព្យសម្បត្តិដែលរងផលប៉ះពាល់( ចូរមើលតារាងក្នុងឧបសម្ពន្ធ័៣) តារាង២ ខាងក្រោមផ្តល់នូវគោលការណ៏នៃនាំ

ទូទៅសំរាប់ធ្វើការកំណត់នូវប្រភេទនៃឯកសារគាំពារសង្គម ដែលត្រូវការក្នុងកំឡុងពេលដែលពតិមានលំអិតបន្ថែមត្រូវបាន ផ្តល់អោយនៅក្នុង ឧបសម្ពន្ធ័ ៤, ៥, ៦, និង ៧។

- **ភាពខុសគ្នាសំខាន់ៗនៅក្នុងច្បាប់ប្រទេសកម្ពុជា និងគោលនយោបាយធនាគារពិភពលោក**

២.១.៣. គោលនយោបាយប្រតិបត្តិ (កថាខ័ណ្ឌ ទី១៥) ផ្តល់ជំនួយដល់ការតាំងលំនៅដ្ឋានឡើងវិញទៅដល់ "ប្រជាពលរដ្ឋដែលមិនបានទទួលស្គាល់សិទ្ធិស្របច្បាប់ រឺក៏ប្តឹងតវ៉ានូវដីដែលពួកគេកាន់កាប់យក"។ នៅក្នុងករណីបែបនេះ គោលនយោបាយប្រតិបត្តិ ៤.១២ មិនតម្រូវឱ្យមានការធ្វើសំណងសម្រាប់ដី ប៉ុន្តែសម្រាប់ការបាត់បង់នូវទ្រព្យ-សម្បត្តិដែលមិនមែនជាដីធ្លី (ដូចជាអាគារ ដើមឈើ កសិផលនានា) និងជំនួយនៃការតាំងលំនៅដ្ឋានឡើងវិញអាចមានជាប្រាក់ ទ្រព្យសម្បត្តិផ្សេងៗទៀត ការផ្តល់ការងារ រឺដីជាទីគាប់ចិត្ត។ គោលនយោបាយប្រតិបត្តិ ៤.១២ មិនសំដៅលើរវាងអ្នកក្រ និងអ្នកដែលរស់នៅមិនមានការអនុញ្ញាត និងអ្នកទន្ទ្រានយកដី ប៉ុន្តែព្រមព្រៀងនូវការផ្តល់សិទ្ធិដូចគ្នាទៅនឹងជំនួយនៃការតាំងលំនៅដ្ឋានឡើងវិញ។ ហេតុដូចនេះមានចំណុចពីរនៃភាពមិនជាប់លាប់រវាងគម្រោងស្របច្បាប់កម្ពុជា និងគោលនយោបាយប្រតិបត្តិ (OP 4.12) ដែលគម្រោងគោលនយោបាយនេះនឹងបង្ហាញដូចខាងក្រោមៈ

១).អ្នកកាន់កាប់ដីក្រីក្រដែលមិនត្រូវបានផ្តល់សិទ្ធិដែល (ក) មិនមានកន្លែងផ្សេងៗទៀតសម្រាប់រស់នៅជាជាងដីដែលពួកគេចាប់យកនៅក្នុងតំបន់ដីសម្បទានសង្គមកិច្ច និង/រឺ (ខ). ពឹងផ្អែលើដីកសិកម្មសម្រាប់ចិញ្ចឹមជីវិត នឹងមិនអាចបន្តប្រើប្រាស់ដីដែលពួកគេចាប់យក (ប្រសិនបើដីនោះវាមិនមានទំហំដល់ដីសម្បទានសង្គមកិច្ចសម្រាប់អ្នកតាំងទីលំនៅថ្មី) រឺត្រូវបានផ្តល់ឱ្យនូវដីជំនួសវិញ (មានភាពស្មើគ្នាទៅនឹងដីសម្បទានសង្គមកិច្ចសម្រាប់អ្នកតាំងលំនៅដ្ឋានថ្មី)។ ប្រសិនបើមានផលប៉ះពាល់ក្នុងការទទួលយកដីនៅក្នុងតំបន់ដីសម្បទានសង្គមកិច្ច អ្នកចាប់យកដីបែបនេះត្រូវបានគេផ្តល់សិទ្ធក្នុងការទទួលបាននូវសំណងចំពោះការបាត់បង់ទ្រព្យសម្បត្តិនានា។

២).អ្នកកាន់កាប់ដីដែលមិនមែនជាអ្នកក្រីក្រ ដែលបានផ្តល់សិទ្ធិ និងមិនពឹងទៅលើដីពួកគេកំពុងប្រើប្រាស់នៅក្នុងតំបន់ដីសម្បទានសង្គមកិច្ចសម្រាប់ជីវភាពរស់នៅរបស់គ្រួសារ
នឹងមិនត្រូវបានគេផ្តល់សិទ្ធិដើម្បីសុំសម្រាប់ដី
សម្បទានសង្គមកិច្ច ប៉ុន្តែអាចទទួលបាននូវសំណងតែមួយគត់សម្រាប់ការវិនិយោគនៅក្នុងទ្រព្យសម្បត្តិ (ដំណាំ ដើមឈើ និងរចនា សម្ព័ន្ធផ្សេងៗ) លើការបន្តមិនលើសពី ៥ ហិចតានៅក្នុងតំបន់ដីសម្បទានសង្គមកិច្ចដែលមានទំហំធំនៃការវិនិយោគត្រូវបានធ្វើឡើង។

អ្នកកាន់កាប់ដីក្រីក្រ (ទោះជាអ្នកកាន់កាប់ដីស្របច្បាប់ រឺអ្នកប្រើប្រាស់ដីដែលមិនមានការអនុញ្ញាត) ត្រូវបានកំណត់ជាគ្រួសារដែលមិនមែននៅក្នុងសេចក្តីប្រកាសលេខ ២៦៣ ខែ កក្កដា ក្នុងឆ្នាំ ២០០៧ ដែលចេញដោយក្រសួងកិច្ចការ សង្គម និងនិតិសម្បទា។ លក្ខណៈវិនច្ឆ័យទាំងនេះរួមមានៈ

(ក). គ្រួសារដែលគ្មានដី ដែលមិនអាចមានដីសម្រាប់តាំងលំនៅដ្ឋានបាន

(ខ). គ្រួសារក្រីក្រ រឺគ្មានដីដែលមិនអាចមានដីកសិកម្ម និង

(គ). គ្រួសារដែលមានប្រាក់ចំណូលមិនគ្រប់គ្រាន់ដើម្បីគាំទ្រការរស់នៅរបស់ពួកគេ

## ផ្នែកទី ៣: គម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF)

### ៣. ទស្សនៈទូទៅនៃគម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ

៣.១.សុវត្ថិភាពសង្គមត្រូវបានគេស្គាល់ជាទូទៅថា ជាគោលនយោបាយប្រតិបត្តិ ៤.១២:ការតាំងទីលំនៅដ្ឋានដែលមិនមានការយល់ព្រម និងគោលនយោបាយប្រតិបត្តិ ៤.២០: ជនជាតិដើមភាគតិច គឺតែងតែត្រូវបានប៉ះពាល់ខណៈដែលមានបញ្ហានៃការតាំងលំនៅដ្ឋានឡើងវិញ ទាក់ទងទៅនឹងសកម្មភាពនានាដែលត្រូវបានផ្តល់ថវិការដោយគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ រឺខណៈដែលមានផលប៉ះពាល់ជាអវិជ្ជមានត្រូវបានប៉ាន់ស្មានទុកជាមុនទៅលើជនជាតិដើមភាគតិច និងក្រុមដែលងាយរងគ្រោះ។

៣.២. គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ បានរៀបចំគម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ ដែលត្រូវបានពន្យល់ជាជំហាន៧យ៉ាងលំអិត ដើម្បីរៀបចំផែនការតាំងលំនៅដ្ឋានឡើងវិញក្នុងការវិនិយោគនានា។ ប្រសិនបើគោលនយោបាយប្រតិបត្តិមានផលប៉ះពាល់ ធនគារពិភពលោកតម្រូវឱ្យមានផែនការអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច (IPDP) ដើម្បីដាក់ស្នើជាអាទិភាពទៅដល់ការអនុម័ត និងការវាយតម្លៃលើការវិនិយោគ។ **តារាងទី ៣** បង្ហាញនូវការទំហំនៃផលប៉ះពាល់សង្គមជាអវិជ្ជមាន និងការឆ្លើយតបរបស់វាដែលបានតម្រូវក្នុងការរៀបចំឯកសារសុវត្ថិភាព។

**ឧបសម្ព័ន្ធទី ៣:** ផ្តល់នូវព័ត៌មានសង្ខេបស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងដីដែលបានផលប៉ះពាល់

**តារាងទី ២:** បង្ហាញពីច្បាប់ទូទៅសម្រាប់ការកំណត់នូវឯកសារសុវត្ថិភាពសង្គម ដែលបានតម្រូវដោយគម្រោងគ្រប់គ្រងធនធានទឹកចម្រុះ មានដូចខាងក្រោម:

**តារាងទី ២**

| **ទំហំនៃផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម** | **ប្រភេទឯកសារមួយចំនួនដែលត្រូវបានតម្រូវ** |
|---|---|
| - សម្រាប់ការវិនិយោគដែលត្រូវបានគេកំណត់ថាមានផល ប៉ះពាល់ តិចតួចដែលត្រូវបានកំណត់នៅក្រោមគោលនយោបាយ ៤.១២ ខណៈដែល" ប្រជាពលរដ្ឋបានរងផលប៉ះពាល់ដែលមិនបានធ្វើការផ្លាស់ប្តូរជារូបសាស្ត្រនឹងតិចជាង១០ភាគរយនៃ ទ្រព្យសម្បត្តិរបស់ពួកគេ ដែលបានបាត់បង់" ។ | **<u>ផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានសង្ខេបត្រូវបានតម្រូវ</u>** ផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានសង្ខេបត្រូវបានតម្រូវនៅក្នុង តារាងឧបសម្ព័ន្ធទី ៤។ |
| - សម្រាប់ការវិនិយោគដែលអាចមានលទ្ធផលប៉ះពាល់សំខាន់ៗ ឧ. ការផ្លាស់ទីតាំងនៃប្រជាពលរដ្ឋ និងដែលច្រើនជាង ១០ ភាគរយនៃទ្រព្យសម្បត្តិដែលបាត់បង់នានា។ | **<u>ផែនការសកម្មភាពនៃការតាំងលំនៅដ្ឋាននឹងត្រូវបានរៀបចំ:</u>** សេចក្តីសង្ខេបនៃផែនការសកម្មភាពត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ៥ |
| - សម្រាប់ការវិនិយោគដែលអាចមានលទ្ធផលប៉ះពាល់ជាអវិជ្ជមាន ទៅលើជនជាតិដើមភាគតិច។ | ● ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ត្រូវតែបានរៀបចំជាឯកសារ ដាច់ដោយឡែក។ បញ្ជីនៃព័ត៌មានដែលត្រូវបានតម្រូវនៃផែនការ អភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) ត្រូវបានបង្ហាញនៅក្នុង តារាងឧបសម្ព័ន្ធទី ៦។<br>● គំរូនៃការផ្សព្វផ្សាយសម្រាប់ជនជាតិដើមភាគតិចនៅក្នុងគម្រោង អភិវឌ្ឍន៍ត្រូវបានបង្ហាញនៅក្នុងតារាងឧបសម្ព័ន្ធទី ៧។ |

**កំណត់សំគាល់:**

(១). សម្រាប់ការវិនិយោគដែលមិនបានស្មានទុកជាមុននូវលទ្ធផលនៃការផ្លាស់ទីកន្លែង និងដែលមានការបាត់បង់ទ្រព្យ-សម្បត្តិនានា គឺបានស្មានទុកជាមុនដែលអាចធ្វេសប្រហែសបាន បន្ទាប់មកព័ត៌មាននេះគួរត្រូវបានបញ្ជាក់ផងដែរនៅក្នុងការវាយតម្លៃវិនិយោគ ដោយស្របទៅតាមសំណើដើម្បីលើកលែងតម្រូវការសម្រាប់ផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានដែលបានសង្ខេប និង(២).ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចមិនមានភាពចាំបាច់ ខណៈដែលក្រុមជនជាតិដើមដែលបានកំណត់អត្តសញ្ញាណត្រូវបានដាក់បញ្ចូលទៅក្នុងសេដ្ឋកិច្ច និងសងមជាមួយប្រជាពលរដ្ឋដែលមានសិទ្ធិអំណាច ប៉ុន្តែសេចក្តីលំអិតនៃផលប៉ះពាល់លក្ខណៈសេដ្ឋកិច្ចសង្គមសំខាន់ៗនៃជនជាតិដើមភាគតិច និងវិធានការក្នុងការជួយសម្រាល ដែលបានស្នើឡើងនឹងត្រូវបានដាក់បញ្ចូលទៅជាលិខិតភ្ជាប់នៅក្នុងផែនការសកម្មភាពនៃការតាំងលំនៅដ្ឋាន។

### ៣.៣. ការផ្តល់សិទ្ធិ និងការផ្តល់សំណង

**សិទ្ធិទទួលបាន**

៤. រាល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ពីគម្រោងដែលបានកំណត់អត្តសញ្ញាណនៅក្នុងតំបន់ប៉ះពាល់របស់គម្រោងលើការកាត់បន្ថយនូវកាលបរិច្ឆេទ នឹងត្រូវបានផ្តល់សិទ្ធិដើម្បីសងសម្រាប់ផលប៉ះពាល់ទៅលើទ្រព្យសម្បត្តិរបស់ពួកគេ និងវិធានការនៃការស្តារឡើងវិញប្រកបដោយពេញចិត្ត ដើម្បីជួយដល់ពួកគេក្នុងការលើកកម្ពស់ រឺយ៉ាងហោចស្តង់ដារស់នៅរបស់គេ សមត្ថភាពរកប្រាក់ចំណូល និងកំរិតផលិតភាពនានា។ ការកាត់បន្ថយនូវពេលពេលវានឹងជាថ្ងៃចុងក្រោយនៃការអង្កេតនៃ វិធានការលំអិតនូវរាល់ការវិនិយោគ។ ប្រជាពលរដ្ឋទាំងនោះដែលទន្រ្ទានដីធ្លីនៅក្នុងតំបន់វិនិយោគបន្ទាប់ពីថ្ងៃដែលបានកាត់ចេញនឹងមិនត្រូវផ្តល់សិទ្ធិទទួលនូវសំណង រឺជំនួយផ្សេងៗនោះទេ។

**ការផ្តល់សិទ្ធិនានា**

តារាងម៉ាទ្រិកនៃការផ្តល់សិទ្ធិមាននៅក្នុងតារាងទី ៣ សង្ខេបពីប្រភេទសំខាន់ៗនៃភាពបាត់បង់ និងការឆ្លើយតបនូវព្រំដែន និងមូលហេតុនៃការផ្តល់សិទ្ធិ ដែលមានការរៀបចំយ៉ាងលំអិតនូវការអង្កេតសេដ្ឋកិច្ចសង្គម វិធានការយ៉ាងលំអិតនឹងជាមូលដ្ឋានគ្រឹះដើម្បីកំណត់ពីផលប៉ះពាល់ជាក់ស្តែង និងការអង្កេតលើតម្លៃនៃការផ្លាស់ទីលំនៅនឹងត្រូវបានអនុវត្តដើម្បីកំណត់អត្រា និងតម្លៃនៃការផ្លាស់ប្តូរទីតាំងជាក់ស្តែង។

**តារាងឧបសម្ព័ន្ធទី ២:** ផ្តល់នូវព័ត៌មានស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងដីធ្លីដែលទទួលផលប៉ះពាល់

៥. យោងទៅលើប្រភេទនៃផលប៉ះពាល់នានា ចំណាត់ថ្នាក់នៃប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ពីគម្រោង និងសិទ្ធិនានាគួរ ត្រូវបានរៀបចំ ដើម្បីបង្ហាញពីសិទ្ធិជាក់លាក់នៅក្នុងចំណាត់ថ្នាក់នីមួយៗនូវរាល់ប្រជាពលរដ្ឋដែលបានទទួលរងនូវផលប៉ះពាល់ពីគម្រោង។ តារាងផ្តល់សិទ្ធិត្រូវបានបង្ហាញនៅក្នុងតារាងទី ៣ ជាឯកសារយោង។

**តារាងទី ៣: តារាងម៉ាទ្រិចនៃការផ្តល់សិទ្ធិ:**

| ប្រភេទនៃការបាត់បង់ | អ្នកកាន់កាប់ | សិទ្ធិកាន់កាប់ | បញ្ហានៃការអនុវត្ត |
|---|---|---|---|
| ដីដែលអាចផ្តល់ផល(ដីស្រែដីដំណាំនិងចំការម៉ៃសាក់) | អ្នកកាន់កាប់ដីស្របច្បាប់ រឺ អ្នកចាប់យកដី ត្រូវបានកំណត់អត្តសញ្ញាណខណៈពេលធ្វើជំរឿន និងដាក់ស្លាកសញ្ញា | • សម្រាប់ការបាត់បង់ដីការផ្តល់សំណងជាប្រាក់ជាតម្លៃជំនួស ដែល មានតម្លៃស្មើ ទៅនឹងតម្លៃទីផ្សារនៃដីនៅតាមភូមិនៃ ប្រភទស្រដៀងគ្នា ចំណោតថ្នាក់ និងសមត្ថភាពផលិត តម្លៃនៃការលក់ ដោយសេរី (ពន្ធការបង់ថ្លៃសេវារដ្ឋបាល)<br>• ប្រសិនបើផលប៉ះពាល់លើដីសរុបគឺ ១០ ភាគរយ រឺច្រើនជាង នេះ ជាអាទិភាពដីដែលផ្លាស់ទីតាំង និងដែលមានលក្ខណៈស្រដៀងគ្នា ចំណោត់ថ្នាក់ និងសមត្ថភាពផលិតនៃដីនៅជិត រឺនៅ ក្នុងភូមិជាដីដែលមានសិទ្ធិកាន់កាប់ ។ប្រសិនបើគម្រោងដីមានសិទ្ធិកាន់កាប់នៅក្នុងតំបន់នោះ។ ប្រសិនបើដីប្រើបាស់បណ្ណ័កម្ម សិទ្ធិត្រូវបានចុះរួច។ រឺនៅក្នុងដំណាក់ការទទូចសុំនៃប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ នោះការផ្តល់សំណងជាប្រាក់នៅក្នុង តម្លៃផ្លាស់ប្តូរ បូករួមទាំងជំនួយដើម្បីទិញ និងចុះបញ្ជីផងដែរ។ | • អ្នកកាន់កាប់ស្របច្បាប់គឺអ្នកទាំងនោះ ដែលបានទទួលដី ប្រើប្រាស់ រឺ សិទ្ធិ បណ្ណ័កាន់កាប់ដីពីគម្រោងផ្តល់សិទ្ធិដីធ្លី<br>• ការបរិច្ចាគដោយស្ម័គ្រចិត្តនៃដីដែលផ្តល់ផលិតផលនឹង មិនត្រូវបានអនុញ្ញាត ដោយគម្រោង |
| ដីសម្រាប់ការតាំងទី លំនៅដ្ឋាន | អ្នកកាន់កាប់ស្របច្បាប់ រឺអ្នកចាប់យកដី ត្រូវបានកំណត់អត្តសញ្ញាណខណៈពេលធ្វើ ជំរឿន និងដាក់ស្លាកសញ្ញា | • ជាមួយដីដែលនៅសេសសល់ដើម្បីតាំងលំនៅដ្ឋាន/រចនាសម្ព័ន្ធ: (១). ការផ្តល់សំណងជាប្រាក់នៅតម្លៃនៃការផ្លាស់ទីលំនៅ គឺ មានតម្លៃស្មើទៅនឹងតម្លៃទីផ្សារនៃប្រភេទដីដែលមានចំណោត់ថ្នាក់ និងមានលក្ខណៈស្រដៀងគ្នា និងរួចពីតម្លៃលក់ (ពន្ធ និង ការបង់ថ្លៃសេវារដ្ឋបាល) និងទី (២). អាជ្ញាធរស្រុកបង្កើនដី ដែលសម្រាប់តាំងលំនៅដ្ឋានដែល សេសសល់ដោយមិនមានការយកតម្លៃពីប្រជាពលរដ្ឋ។ ដែលទទួលរងនូវផលប៉ះពាល់ (ឧ. បំពេញ រឺ | • អ្នកកាន់កាប់ដីស្របច្បាប់គឺអ្នកដែលមានបណ្ណ័កម្មសិទ្ធិដី រឺឈ្មោះកាន់កាប់ដីពីគម្រោងផ្តល់ឱ្យ។<br>• ការបរិច្ចាកដោយស្ម័គ្រចិត្តនៃក្បាលដីតូចៗនូវដីសម្រាប់លំនៅដ្ឋាននឹងត្រូវបានអនុញ្ញាតឱ្យដោយគម្រោងដែលបាន ផ្តល់ឱ្យដោយស្របទៅតាមការវិនិច្ឆ័យយ៉ាងតឹងរឹងដែល បានចងក្រង :(១).ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ដីលំនៅដ្ឋានទាំងស្រុងគឺមិនតិចជាង ៣០០ ម៉ែត្រ ការ៉េ |

| ប្រភេទនៃការបាត់បង់ | អ្នកកាន់កាប់ | សិទ្ធិកាន់កាប់ | បញ្ហានៃការអនុវត្ត |
|---|---|---|---|
| | | ក៏រីត) ធ្វើដូចនេះ អាចឱ្យប្រជាពលរដ្ឋទាំងនោះអាច ត្រលប់ទៅរស់នៅលើដីទំនេរនោះបាន ។<br>• ដោយមិនមានដីដែលនៅសេសសល់ដើម្បីតាំងលំនៅដ្ឋាន/រចនាសម្ព័ន្ធ: (១). ការផ្លាស់ប្តូរដីដែលមានទំហំប៉ុនគ្នា ចំណាត់ថ្នាក់ និងប្រភេទដូចគ្នា ដោយមិនមានការបង់ប្រាក់ ការចុះបញ្ជី និងការកាត់ដីឈ្មោះដី ប្រសិនបើគម្រោងផ្តល់សិទ្ធិកាន់កាប់ដី កំពុងដំណើរការនៅក្នុងតំបន់នោះ។ ប្រសិនបើអត់ នោះ បណ្ណ័កម្មសិទ្ធិដី រឺ (២).ការផ្តល់នូវសំណងជាប្រាក់នៅតម្លៃនៃការផ្លាស់ទីតាំងគឺមានតម្លៃស្មើទៅនឹងតម្លៃទីផ្សារនៃចំណាត់ថ្នាក់ និងប្រភេទដីដែលរួចពីពន្ធ តម្លៃលក់ (ពន្ធ និងការបង់ថ្លៃ សេវា រដ្ឋបាលផ្សេងៗ) បូករួមទាំងជំនួយដើម្បីទិញ និងចុះ បញ្ជីផងដែរ ។ | (២).ប្រសិនបើដីតាំងលំនៅដ្ឋានទាំងនោះច្រើនជាង ៣០០ ម៉ែត្រ ការ៉េនោះក្បាលដីដែលត្រូវបាន បរិច្ចាគមិនអាចច្រើនជាង ៥ ភាគរយ នៃផ្ទៃដីសរុប និងទី (៣). មិនមានផ្ទះ រចនាសម្ព័ន្ធ រឺក៏អចលនៈ ទ្រព្យសម្បត្តិ ស្ថិតពីចំណែកដីដែលបានទទួលផលប៉ះពាល់ ។<br>• ការបរិច្ចាគដីដោយស្ម័គ្រចិត្តយោងទៅតាមការ វិនិច្ឆ័យទាំងនេះ នឹងដែលអនុញ្ញាតឱ្យ ដំណើរការស្របទៅតាមវិធី អនុវត្តរបស់ធនាគារពិភពលោកដែលដូចគ្នាទៅនឹងក្រិត្យច្បាប់ទី១៩២ របស់រាជរដ្ឋាភិបាលឆ្នាំ ២០០៥ ។ |
| ស្រែៈត្រី (តំបន់សេសសល់ គឺនៅបានរឹអាចត្រូវបាន សង្ឃឹមថាតម្រូវទៅតាម ទិន្នផលសេដ្ឋកិច្ចរឺផ្ទាល់ ខ្លួន | ម្ចាស់ដីស្រែះដែលទទួលរងផលប៉ះពាល់ | • ការផ្តល់សំណងជាប្រាក់នៃចំណែកដី ដែលទទួលផលប៉ះពាល់ នៅក្នុងតម្លៃផ្លាស់ប្តូរ គឺមានតម្លៃស្មើទៅនឹងតម្លៃទីផ្សារបច្ចុប្បន្ន នៃស្រែះត្រី កំលាំងពលកម្ម និងការជួលនៃសម្ភារៈដើម្បីជីកស្រែះ ត្រី ហើយរួចពីពន្ធពីតម្លៃលក់ (ពន្ធ និង ការបង់ថ្លៃសេវារដ្ឋបាលផ្សេងៗ) ។<br>• ប្រសិនបើក្នុងពេលបច្ចុប្បន្នត្រីមិនទាន់ដល់ពេលប្រមូលផលមុនពេលគម្រោងធ្វើការកាន់កាប់នៃស្រែះត្រីនោះ ការផ្តល់សំណងជាប្រាក់សម្រាប់តម្លៃត្រីដែលអាចលក់បានធ្វើឡើងក្នុងកំឡុងពេលនៃការផ្តល់សំណង ។<br>• អាជ្ញាធរស្រុកធ្វើការកសាង រឺ ជួសជុល | • ពេលវេលាគ្រប់គ្រាន់បាន ផ្តល់ ដល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ដើម្បីប្រមូលផលត្រី<br>• ការបរិច្ចាគនៃដីស្រែះចិញ្ចឹមត្រីនឹងមិនត្រូវបានអនុញ្ញាតដោយគម្រោង |

| ប្រភេទនៃការបាត់បង់ | អ្នកកាន់កាប់ | សិទ្ធិកាន់កាប់ | បញ្ហានៃការអនុវត្ត |
|---|---|---|---|
| | | ឡើងវិញនូវស្រះត្រី ដែលនៅសេសសល់។ ប្រសិនបើការគាំទ្រមិនអាចត្រូវបានផ្តល់ឱ្យតាមរយៈកិច្ចសន្យាប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ទាំងនោះនឹងត្រូវបានផ្តល់សិទ្ធិទទួលយកនូវជំនួយជាប្រាក់ទៅលើការចំណាយនៃកំលាំងពលកម្មនិងថ្លៃជួលនៃសម្ភារៈដើម្បីកសាងនិងជួសជុល ស្រះត្រី។ | |
| ផ្ទះ/តូបដែលប៉ះពាល់ទាំងស្រុង និង រចនាសម្ព័ន្ធទី ២ (ផ្ទះបាយ ជង្រុកស្រូវ) ផ្ទះ/តូបដែលប៉ះពាល់ខ្លះៗប៉ុន្តែមិនមានរយៈពេលយូរ (នឹងតម្រូវឱ្យតាំងលំនៅដ្ឋានថ្មីឡើងវិញ) | អ្នកកាន់កាប់ដីផ្ទះដែលទទួលរងផលប៉ះពាល់បើទោះជារឺមិនមែនដីត្រូវបានកាន់កាប់ | • ការផ្តល់សំណងជាប្រាក់នៅក្នុងតម្លៃនៃការផ្លាស់ប្តូរសម្រាប់ រចនាសម្ព័ន្ធទាំងមូលមានតម្លៃស្មើទៅនឹងតម្លៃទីផ្សារបច្ចុប្បន្ននៃ(១). សម្ភារៈ នានា ដោយមិនមានការដកហូតសម្រាប់ការ បញ្ចុះថ្លៃនៃ រចនាសម្ពន្ធ័រឺសម្ភារៈដែលបាន មកវិញ (២). សម្ភារៈដឹកជញ្ជូន និងទី (៣). តម្លៃពលកម្មដោយរួមទាំងការ រុះរើ ដឹកជញ្ជូន និង កសាងឡើងវិញ និង<br>• ដោយមិនរួមបញ្ចូលនូវការផ្លាស់ត្រឡប់ទៅកាន់ដីលំនៅដ្ឋានរបស់ពួកគេវិញរបស់ទិញទុកជាមុននៃត្រាក់ទ័រដែលខូចសម្រាប់ការអូសទាញផ្ទាល់ខ្លួន ដែលមិនមានតម្លៃចំពោះប្រជាពលរដ្ឋដែលទទួលរងនូវ ផលប៉ះពាល់។ | • ពេលវេលាគ្រប់គ្រាន់ត្រូវបានផ្តល់ឱ្យប្រជាពលរដ្ឋដែល ទទួលរងនូវផលប៉ះពាល់ដើម្បីជួសជុលរឺស្ថាបនាឡើងវិញនូវរចនាសម្ព័ន្ធនានា<br>• ផ្ទះនិងតូបលក់ដែលប៉ះពាល់ដែលមិនអាចស្ថិតនៅបានយូរ គឺជាផ្ទះនិងតូបដែលសេសសល់ចំណែកដីដែលបានប៉ះពាល់មិនមានរយៈពេលយូរ សម្រាប់ការតាំងលំនៅដ្ឋាន។ |
| ការប្រើប្រាស់បណ្តោះអាសន្ននៃដី | អ្នកកាន់កាប់ស្របច្បាប់រឺអ្នកចាប់យកដី | • សម្រាប់ដីតាំងលំនៅដ្ឋាននិងដីកសិកម្ម ត្រូវបានប្រើប្រាស់ដោយម្ចាស់កិច្ចសន្យាការងារស៊ីវិលតាមរយៈនៃការធ្វើផ្លូវវាងរឺកន្លែងសម្រាប់ ម្ចាស់កិច្ចសន្យា សម្រាប់ធ្វើការ (១). ការជួលដីត្រូវបាន យល់ព្រមរវាងម្ចាស់ដីនិងម្ចាស់កិច្ចសន្យាការងារស៊ីវិលប៉ុន្តែមិនគួរតិចជាងប្រាក់ចំណូលដែលមិនបានដឹងនិងចំណូលដែលអាចត្រូវបានបង្កើតឡើញតាមរយៈទ្រព្យសម្បត្តិក្នុងកំឡុងពេលនៃការប្រើប្រាស់ បណ្តោះអាសន្ននៃដី(២).ការផ្តល់ | • ទីប្រឹក្សាគ្រប់គ្រងសំណង់នឹងធានាថា(១).ទីតាំងនិងភាព ត្រូវគ្នានៃការ សាងសង់ផ្លូវវាងត្រូវបានលើកឡើងតាមរយៈការងារស៊ីវិលនានា និងមានផលប៉ះពាល់តិច (២). ដែលម្ចាស់ដីគឺត្រូវបានប្រាប់ពីសិទ្ធិរបស់គេ និងការ ផ្តល់សិទ្ធិទៅតាមគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ គម្រោង និង (៣). កិច្ចព្រមព្រៀងត្រូវបានធ្វើ រវាងម្ចាស់ដីនិងម្ចាស់កិច្ច សន្យា។ |

| ប្រភេទនៃការបាត់បង់ | អ្នកកាន់កាប់ | សិទ្ធិកាន់កាប់ | បញ្ហានៃការអនុវត្ត |
|---|---|---|---|
| | | នូវសំណងជាប្រាក់នៅ តម្លៃនៃការផ្លាស់ទីតាំង សម្រាប់អចលនៈទ្រព្យដែលប៉ះពាល់ (ឧ. រចនាសម្ព័ន្ធ ដើមឈើ ដំណាំ) និងទី (៣). ការសាងសង់ឡើងវិញនូវដីដែលប្រើប្រាស់បណ្តោះអាសន្ន រយៈពេល។ ១ ខែ បន្ទាប់ពីការបញ្ចប់នៃការសាងសង់ផ្លូវវាង រឺការ រុះរើនៃសម្ភារៈពីទីកន្លែងការងាររបស់ម្ចាស់ កិច្ចសន្យាដោយអាស្រ័យទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងរវាងម្ចាស់ដី និងម្ចាស់កិច្ច សន្យា។ | |
| ផ្ទះ/តូបដែលមានប៉ះពាល់ខ្លះៗ និង រចនាសម្ព័ន្ធផ្សេងៗទៀត (នឹងមិន តម្រូវឱ្យតាំងលំនៅដ្ឋានថ្មីឡើង វិញ) | អ្នកកាន់កាប់ដីផ្ទះដែលទទួលរងផលប៉ះពាល់បើទោះជា រឺមិនមែនជាដីត្រូវបានកាន់កាប់ ក៏ដោយ | • ការផ្តល់សំណងជាប្រាក់ទៅតាមការផ្លាស់ទីតាំងសម្រាប់ចំណែកដីដែលទទួលផលប៉ះពាល់ត្រូវមានតម្លៃស្មើទៅនឹងតម្លៃនៃទីផ្សារ (១). កំលាំងពលកម្ម និងសម្ភារៈដោយមិនមានការ រិបអូស តាមរយៈការបញ្ចុះតម្លៃនៃរចនាសម្ព័ន្ធ រឺសម្ភារៈដែលបានមកវិញ (២). សម្ភារៈដឹកជញ្ជូននានា និងទី (៣). តម្លៃនៃ ការជួសជុលនៃចំណែកដែលមិនត្រូវរងប៉ះពាល់។ | |
| ការបាត់បង់ប្រាក់ ចំណូលពីមុខរបរក្នុងកំឡុងពេលនៃការរុះរើ/ជួសជុលនៃចំណែកដីដែលប៉ះពាល់(ដោយមិនមានការតាំងលំនៅដ្ឋានថ្មី) | ម្ចាស់តូបលក់ទំនិញ | • សម្រាប់មុខរបរធម្មតា(តូបលក់) ការផ្តល់សំណងជាប្រាក់ស្មើ នឹងអត្រាប្រាក់ឈ្នួលប្រចាំថ្ងៃ (ឧ. ២ ដុល្លា/ថ្ងៃ) ត្រូវបានគុណជាមួយនឹងចំនួនថ្ងៃនៃការរកស៊ី | វានឹងត្រូវការរយៈពេល១ថ្ងៃដើម្បីផ្លាស់ទីតាំង តូចលក់ប្រសិនបើតូបនោះធ្វើឡើងពី សម្ភារៈតាមបែបប្រពៃណី (ឬស្សី) ដែលការផ្លាស់ប្តូរ(អាចត្រូវបានអនុវត្តដោយមិនមានការរុះរើ។ វានឹងប្រើពេលរយៈពេល ២ថ្ងៃដើម្បីរុះរើ និងជួសជុលចំណែកប៉ះពាល់នៃតូបដែលសាងសង់ដោយ សម្ភារៈ អចិន្ត្រៃយ (ដូចជាឈើ ប្រណីត និងស៊ីម៉ង់ត៍)។ អត្រានឹងត្រូវបានបញ្ជាក់តាមរយៈការធ្វើសម្ភាសន៍ជាមួយ ម្ចាស់តូបនានាដើម្បីប៉ាន់ប្រមាណនូវផល |

| ប្រភេទនៃការបាត់បង់ | អ្នកកាន់កាប់ | សិទ្ធិកាន់កាប់ | បញ្ហានៃការអនុវត្ត |
|---|---|---|---|
| | | | ចំណេញប្រចាំថ្ងៃ។ |
| ដំណាំ និងដើមឈើហូបផ្លែ | ម្ចាស់នៃដំណាំ និងដើមឈើ ទោះបីជា វីដីមិនត្រូវបានកាន់កាប់ | • ប្រសិបបើជាប្រភេទដំណាំតាមរដូវកំពុងទុំ រឺមិនអាចត្រូវបាន ប្រមូលផល នោះការផ្តល់ជាសំណងជាប្រាក់នូវតម្លៃផ្លាស់ប្តូរស្មើនឹងតម្លៃផលិតផលខ្ពស់បំផុតនៃដំណាំដោយរួមទាំងរយៈពេល ៣ឆ្នាំ គុណនឹងតម្លៃទីផ្សារដំណាំបច្ចុប្បន្ន។<br>• សម្រាប់ដំណាំដែលអាចរស់នៅបានច្រើនឆ្នាំ និងដើមឈើមួយ ចំនួន ការផ្តល់សំណងជាប្រាក់នូវតម្លៃផ្លាស់ប្តូរស្មើនឹងតម្លៃ ទីផ្សារ បច្ចុប្បន្នដោយយោង ទៅលើប្រភេទ អាយុនិងសមត្ថភាព នៃការផ្តល់ផល។<br>• សម្រាប់ប្រភេទឈើហ៊ុបការផ្តល់សំណងជាប្រាក់នូវតម្លៃ ផ្លាស់ប្តូរ ស្មើនឹងតម្លៃទីផ្សារបច្ចុប្បន្នដោយផ្អែកលើប្រភេទអាយុ និង មុខកាត់នៃឈើ។ | |
| ការបាត់បង់ជាអចិន្ត្រៃយ៍នៃធនធានវប្បធម៌ជារូបវន្ត/រចនាសម្ព័ន្ធសាធារណៈ/ភូមិរឹកម្មសិទ្ធិសមូហភាព | អ្នកភូមិ រឺគ្រួសារនៅក្នុងភូមិ | • ការផ្តល់សំណងជាប្រាក់នូវតម្លៃនៃការផ្លាស់ប្តូរសម្រាប់វត្តមាន/រឺរចនាសម្ព័ន្ធដែលមាន ស្រាប់ ត្រូវបានយោងទៅលើតម្លៃរបស់វានាពេលបច្ចុប្បន្ន។ | |
| ផ្នូរសាកសពដែលស្ថិតនៅក្នុងតំបន់រងនូវការប៉ះពាល់ពីគម្រោង | ម្ចាស់នៃផ្នូរសាកសព | • ការផ្តល់សំណងជាប្រាក់សម្រាប់ធ្វើការផ្លាស់ប្តូរ ការជីក ការ ផ្លាស់ទីតាំងថ្មី ការបញ្ចុះសពឡើងវិញនិងចំណាយផ្សេងៗទៀត នឹងត្រូវបានចំណាយជាប្រាក់ទៅដល់រាល់ក្រុមគ្រួសារដែលទទួលរងផលប៉ះពាល់។ | |

| ប្រភេទនៃការបាត់បង់ | អ្នកកាន់កាប់ | សិទ្ធិកាន់កាប់ | បញ្ហានៃការអនុវត្ត |
|---|---|---|---|
| បង្គោលភ្លើង | ក្រុមហ៊ុនអគ្គិសនី | • ការផ្តល់សំណងជាប្រាក់នូវតម្លៃសម្រាប់ការរុះរើ ដឹក និង សាងសង់ឡើងវិញ | |
| ការផ្តល់ប្រាក់ឧបត្ថម្ភសមរម្យ | ការតាំងលំនៅដ្ឋានថ្មីគ្រួសារ-ការតាំង លំនៅដ្ឋានថ្មីនៅលើដីដែលសេសសល់ រឺ ទីកន្លែងផ្សេងៗទៀតដែលមានប្រជាពលរដ្ឋមានផលប៉ះពាល់ដែលបាត់បង់ ១០ ភាគរយ រឺក៏ច្រើនជាងនេះនៃដីដែលឱ្យផលរបស់ ពួកគេ | • ការតាំងលំនៅដ្ឋានថ្មីនៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ដោយមិនមានផលប៉ះពាល់ដល់មុខរបរ រឺប្រភពនៃប្រាក់ចំណូលនឹងត្រូវបានផ្តល់ដោយប្រាក់ រឺក៏ផ្តល់ជាស្រូវចំនួន ១៦ គ.ក្រនូវតម្លៃទីផ្សារបច្ចុប្បន្នសម្រាប់រយៈពេល៣ឆ្នាំក្នុងមួយ សមាជិកគ្រួសារ ។<br>• ការតាំងលំនៅដ្ឋានថ្មី នៃប្រជាជនដែលទទួលរងនូវផលប៉ះពាល់ដែលមាន ប្រភពសំខាន់ៗនៃប្រាក់ចំណូល ( ឧ. មកពីមុខរបរ) រឺ ប្រជាជន ដែលទទួលរងនូវផលប៉ះពាល់ដែលបាត់បង់ច្រើនជាង ១០ភាគរយនៃដីដែលអាចផលិតនោះនឹងត្រូវបានផ្តល់នូវប្រាក់ រឺជំនួយជាស្រូវចំនួន ១៦ គ.ក្រ តាមតម្លៃទីផ្សារបច្ចុប្បន្នសម្រាប់ រយៈពេល ៦ ខែក្នុងមួយសមាជិកគ្រួសារ ។ | |
| ប្រាក់ឧបត្ថម្ភនៃការដឹកជញ្ជូន | ការតាំងលំនៅដ្ឋានថ្មីរបស់គ្រួសារទៅកាន់ទីកន្លែងផ្សេងៗទៀត ។ | ការផ្តល់នូវត្រាក់ទ័រចាស់ៗដើម្បីដឹកសម្ភារៈអាគារចាស់ៗ ថ្មី និង ទ្រព្យសម្បត្តិផ្ទាល់ខ្លួនផ្សេងៗ ទៀត | ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់អាចជ្រើសរើសយកការជំនួយជាប្រាក់( តម្លៃនៃកំលាំងពលកម្ម និង ចំងាយពី ការតាំងលំនៅដ្ឋានថ្មី) ត្រូវបានកំណត់ក្នុងកំឡុងពេលនៃការអនុវត្តគម្រោង ។ |
| ផលប៉ះពាល់ដែលមានលក្ខណៈខ្លាំងលើប្រជាពលរដ្ឋដែលងាយរងគ្រោះ ( ការតាំងទីលំនៅថ្មីរ | ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ និងរងគ្រោះខ្លាំង ដូចជាអ្នកក្រីក្រ រឺ គ្រួសារ ដែលស្ត្រីជាមេគ្រួសារចាស់ ជរា រឺជនពិការ និងក្រុមជនជាតិដើមភាគតិច ។ | • ប្រាក់ឧបត្ថម្ភបន្ថែមរយៈពេល ១ ខែ ផ្គត់ផ្គង់ អង្ករក្នុង ម្នាក់នៅ ក្នុងគ្រួសារ<br>• លើកទឹកចិត្តដើម្បីចូលរួមនៅក្នុងកម្មវិធីស្តារប្រាក់ចំណូល<br>• ម្ចាស់កម្មសិទ្ធិនឹងអនុវត្តនូវកិច្ចប្រឹងប្រែងប្រកបដោយហេតុផលដើម្បីជ្រើសរើសនូវផលប៉ះពាល់ធ្ងន់ធ្ងរនិងប្រជាពលរដ្ឋដែលដែលងាយទទួលរងគ្រោះថ្នាក់ដូចជា | អ្នកក្របំផុតជាប្រជាពលរដ្ឋដែលស្ថិតនៅក្រោមបន្ទាត់ក្រីក្រជាតិ ដូចដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងភាពជាដៃគូរនៃភាពក្រីក្រជាមួយធនាគារពិភពលោក ។ |

| ប្រភេទនៃការបាត់បង់ | អ្នកកាន់កាប់ | សិទ្ធិកាន់កាប់ | បញ្ហានៃការអនុវត្ត |
|---|---|---|---|
| បស់ប្រជាពលរដ្ឋដែល ទទួលនូវផលប៉ះពាល់ និងអ្នកដែល បាត់បង់ ១០ ភាគរយរឺច្រើនជាងនេះ នៃទ្រព្យសម្បត្តិដែលអាចឱ្យផល) ។ | | កំលាំង ពលកម្មសម្រាប់កសាង ផ្លូវ និងការងារថែរក្សាផ្លូវ ។ | |

គ. វិភាគទានស្មគ្រ័ចិត្ត

*៦.* វិភាគទានស្មគ្រ័ចិត្តនឹងមិនអនុវត្តសំរាប់ទ្រព្យសម្បត្តិទាំងអស់នោះទេ លើកលែងតែ វិភាគទានបន្តិចបន្តួច និង ការបាត់បង់នៃដីកសិកម្ម និង ដីធ្លីលំនៅស្ថានបន្តិចបន្តួច ដែលស្របទៅតាមលក្ខខណ្ឌវិនិច្ឆ័យ និង ដំនើរការដែលបានពណ៌នា នៅក្នុងគំរោងនេះ។ វិភាគទានស្មគ្រ័ចិត្តសំរាប់បំនែកតូចមួយនៃដីធ្លីលំនៅស្ថាន នឹងធ្វើស្របទៅតាមលក្ខខណ្ឌវិនិច្ឆ័យយ៉ាង តឹងរឹងដូចខាងក្រោមៈ

- ផ្ទៃដីលំនៅស្ថានសរុបរបស់PAP គឺមិនតិចជាង២០០ម៉ែត្រការេ (ម២)
- ប្រសិនបើផ្ទៃដីលំនៅស្ថានសរុបរបស់PAP គឺច្រើនជាង ៣០០ម៉ែត្រការេនោះ ចំរៀកដីដែលអាចបរិច្ចាគ គឺមិនអាចលើស ពី៥ភាគរយនៃផ្ទៃដីសរុបឡើយ។
- គ្មានផ្ទះសំបែង សំណង់ផ្សេងៗ រឺក៏អចលនទ្រព្យស្ថិតនៅលើដីដែលរងផលប៉ះពាល់នោះឡើយ

*៧.* វិភាគទានស្មគ្រ័ចិត្តដែលស្របទៅនឹងលក្ខខណ្ឌវិនិច្ឆ័យនេះនឹង ប្រព្រឹត្តស្របទោតាមបទបញ្ញត្តិរដ្ឋាភិបាល ដូចដែលត្រូវ បានបង្ហាញនៅក្នុងគោលការណ៏ណែនាំនៃការអនុវត្តគំរោងមូលនិធិឃុំសង្កាត់ នៃគណកម្មការជាតិសំរាប់ការគ្រប់នៃវិមជការ និង ការកែទំរង់វិមជការ "NCDD"។ ម៉ាទ្រិកនៃការផ្តល់សិទ្ធិមិនអាចត្រួតពិនិត្យ ផលប៉ះពាល់គ្រប់ប្រភេទឡើយ តែអាច ត្រូវបានលើកកំពស់នៅក្នុងគំរោងផែនការណ៏នៃការរើលំនៅស្ថានជាថ្មី ដែលផ្តែកលើការផ្តល់មូលនិធិសំរាប់ការវាយតំលៃ សង្គម និង ផលប៉ះពាល់ធ្ងន់ធ្ងរ។ ស្តង់ដារដែលត្រូវបានពណ៌នា នឹងមិនមានក៏រិតទាបឡើយ តែអាចត្រូវបានលើកកំពស់នៅ ក្នុងផែនការការងាររើលំនៅស្ថានឡើងវិញ(RAP) ដូចដែលបានត្រូវការ។

**ឃ. ការតាំងលំនៅដ្ឋានថ្មី និងយុទ្ធសាស្ត្រនៃការស្តារប្រាក់ចំណូល**

*៨.* គ្រួសារដែលត្រូវតែផ្លាស់ទីលំនៅដ្ឋានថ្មី នឹងចូលរួមនៅក្នុងការកំណត់ និងជ្រើសរើសដើម្បីផ្លាស់ទីតាំងលំនៅដ្ឋានថ្មី នៅ លើក្បាលដីរបស់ពួកគេដែលមានស្រាប់ រឺក៏ផ្លាស់ប្តូរទៅកាន់ក្បាលដីដែលបានផ្តល់ឱ្យដោយស្រុក រឺក៏ទទួលប្រាក់ឧបត្ថម្ភ (សំណង) និងស្វែងរកទីតាំងលំនៅដ្ឋានថ្មីដោយខ្លួនឯង។ ក្នុងករណីដែលមុខរបររកស៊ីត្រូវបានផ្លាស់ទីតាំងដែរនោះ ពួកគេ នឹងត្រូវបានជួយរកទីតាំងថ្មីដែលអាចប្រកបមុខរបរបាន។គ្រួសារដែលបានទទួលនូវផលប៉ះពាល់ធ្ងន់ធ្ងរ តាមរយៈនៃការ បាត់បង់ ១០ ភាគរយ រឺទ្រព្យសម្បត្តិច្រើនជាងនេះនឹងត្រូវបានផ្តល់នូវដីជំនួស រឺត្រូវបានជួយដើម្បីទិញដីជំនួស។ ប្រជាពល រដ្ឋដែលទទួលនូវផលប៉ះពាល់នឹងត្រូវបានផ្តល់ផងដែរនូវដីស្រែដើម្បីបង្កើនផលិតភាពនៅលើដីសេសសល់ និង/រឺ ដីជំនួស។ កម្មវិធីស្តារជីវភាពរស់នៅត្រឹមត្រូវនឹងត្រូវបានរៀបចំ និងត្រូវបានអនុវត្តក្នុងកំឡុងពេលអនុវត្តគម្រោងក្នុងកិច្ចពិគ្រោះ យោបល់ជាមួយប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់។ ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់នឹងមិនត្រូវបាន ផ្លាស់ទីកន្លែងរហូតដល់ដីដែលផ្តល់ឱ្យដោយភូមិដូចគ្នា រឺភូមិជិតខាង។

**ង. ភាពងាយរងគ្រោះថ្នាក់ យេនឌ័រ និងជនជាតិដើមភាគតិច**

*៩.* គម្រោងតាំងលំនៅដ្ឋានទទួលស្គាល់ថា ក្រុមសង្គមមួយចំនួនមានលទ្ធភាពតិចតួចដើម្បីស្ថាបនាឡើងវិញនូវល័ក្ខខ័ណ្ឌជីវភាព រស់នៅ និងប្រាក់ចំណូលរបស់ពួកគេ។ ដូចនេះពួកគេមានភាពងាយរងគ្រោះយ៉ាងខ្លាំងខណៈដែលដីរបស់ពួកគេ និងទ្រព្យសម្បត្តិផ្សេងៗទៀតត្រូវបានទទួលរងផលប៉ះពាល់។ គម្រោងនឹងកំណត់អត្តសញ្ញាណនូវរាល់តម្រូវការចាំបាច់ រឺភាពពាក់ព័ន្ធដែលត្រូវការត្រូវបានយកចិត្តទុកដាក់សម្រាប់ជនជាតិដើមភាគតិច និងក្រុមដែលងាយទទួលរងនូវគ្រោះថ្នាក់ដូចជាប្រជាពលរដ្ឋជាស្ត្រីដែលមិនមានដី ជនពិការ ចាស់ជរា រឺកុមារដែលមិនមានការគាំទ្រ។ យុទ្ធសាស្ត្រយេនឌ័រ និងសកម្មភាពជាក់លាក់នៃជនជាតិដើមភាគតិចដូចដែលបានតម្រូវនឹងត្រូវបានរួមបញ្ចូលទៅក្នុងផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានឡើងវិញ។

**ច. ជនជាតិដើមភាគតិច**

១០. ដើម្បីធានាថាជនជាតិដើមភាគតិចទទួលនូវផលប្រយោជន៍ពេញលេញលើសកម្មភាពតាំងលំនៅដ្ឋានឡើងវិញ ទាក់ទងទៅនឹងការផ្តល់សំណង និងការទទួលបាននូវដី ខាងក្រោមនេះជាសកម្មភាពជាក់លាក់មួយចំនួនៈ

(១). នៅតាមបណ្តាភូមិដែលមានជនជាតិដើម តំណាងស្ត្រីម្នាក់ និងបុរសម្នាក់មកពីគ្រប់ក្រុមជនជាតិដើម ភាគតិចនឹងត្រូវបានដាក់បញ្ចូលទៅក្នុងគណៈកម្មការតាំងលំនៅដ្ឋាននីមួយៗ (ថ្នាក់ភូមិ និងស្រុក)។

(២). កំឡុងពេលនៃទីបញ្ចប់នូវការអង្កេតវិធានការលំអិត ស្ត្រី និងបុរស និងស្ត្រីដែលដឹកនាំគ្រួសារជនជាតិដើមភាគតិចនឹងចូលរួមនៅក្នុងការអង្កេតវិធានការលំអិត និងត្រូវបានអមដោយគណៈកម្មការកំណែទម្រង់ស្រុក (DRC) រឺគណៈកម្មការកំណែទម្រង់ភូមិ (VRC) ដែលនឹងផ្តល់ការបកប្រែដើម្បីធានាថាប្រជាពលរដ្ឋដែលទទួល រងនូវផលប៉ះពាល់ និងយល់ព្រមជាមួយលទ្ធផលនៃការអង្កេតវិធានការលំអិតនេះ (DMS)។

(៣). ការផ្តល់នូវសំណងនឹងត្រូវបានផ្តល់ទៅដល់ស្ត្រី និងបុរសដែលមកពីគ្រួសារជនជាតិភាគតិច

(៤). ខណៈដែលគ្រួសារជនជាតិដើមភាគតិចត្រូវបានតម្រូវឱ្យកសាងឡើងវិញ ផ្លាស់ទីតាំងថ្មី នោះជម្រើសនៃ កសាងឡើងវិញ និងទីតាំងនានានឹងត្រូវបានទទួលស្គាល់ដល់គ្រួសារ និងធានាថាពួកគេអាចបន្តជីវភាពរស់នៅ និងរបៀបនៃការរស់នៅបាន និងបន្សល់ទុកនៅជាមួយសហគមន៍របស់ពួកគេ (ប្រសិនបើពួកគេត្រូវបាន ជ្រើសរើស)។

(៥). ខណៈដែលដីត្រូវបានតាំងលំនៅ រឺសិទ្ធិត្រូវបានចាត់ចែង ការចុះបញ្ជី និងក្នុងនាមជាឈ្មោះរបស់ប្តី រឺប្រព័ន្ធ ប្រសិនបើដីដែលទទួលផលប៉ះពាល់ត្រូវបានតម្រូវជាអាទិភាពដើម្បីរៀបការ និងការចុះឈ្មោះរួមគ្នាក្នុងនាម ជាប្តី-ប្រពន្ធសម្រាប់ជនជាតិដើមភាគតិច។

(៦). រាល់ព័ត៌មានសាធារណៈ និងកិច្ចពិគ្រោះយោបល់នៅក្នុងបណ្តាភូមិជនជាតិដើម នឹងរួមមានទាំងការបកប្រែជាភាសាជនជាតិដើម ដូចនេះព័ត៌មាន និងការផ្លាស់ប្តូរនូវទស្សនៈនានាត្រូវបានសម្របសម្រួលសម្រាប់រាល់ស្ត្រី និងបុរសដែលជាប្រជាពលរដ្ឋទទួលរងនូវផលប៉ះពាល់។ ការប្រជុំនៅតាមភូមិនឹងជួយលើកឡើងនូវការយល់ដឹង និងការយល់ដឹងពីការតាំងទីលំនៅទាក់ទងទៅនឹងបញ្ហានានា ដូចជាពេលវេលានៃគម្រោង ការផ្តល់សិទ្ធិ ការផ្តល់នូវ សំណង និងការចំណាយ

ដំណើរការនៃសារទុក្ខ ការគាំទ្រសម្រាប់ការតាំងលំនៅដ្ឋានថ្មី/ការស្ដារឡើងវិញ។ល។ និងក្រុមស្ត្រីនឹងត្រូវបានជួយដើម្បីដោះស្រាយនូវបញ្ហាដូចគ្នា។

(៧).វិធានការស្ដារឡើងវិញសម្រាប់មុខរបរនឹងធានាថាជនជាតិដើម និង/រឺគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ក៏ដូចជាប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ត្រូវបានគោរពស្មើភាពគ្នាក្នុងន័យជួយស្វែងរក និង រឺការតាំងទី លំនៅថ្មី និងផ្ដល់នូវប្រាក់ឧបត្ថម្ភ (រួមទាំងការបាត់បង់ប្រាក់ចំណូលនៃមុខរបរការផ្លាស់ប្ដូរ និងប្រាក់ឧបត្ថម្ភ ផ្សេងៗ)។

(៨).ខណៈដែលគ្រួសារជនជាតិដើមភាគតិចរស់នៅក្នុងភូមិមួយចំនួនជាមួយជនជាតិដើមផ្សេងៗទៀត នោះ គណៈកម្មការតាំងលំនៅដ្ឋានថ្មីនឹងធ្វើការយកចិត្តទុកដាក់ដល់សំណេងរបស់ពួកគេ។ ការតាមដានពីខាងក្រៅនឹង ពិនិត្យឡើងវិញផងដែរនៅក្នុងករណីទាំងនេះ។

(៩). ការតាមដានលើការរៀបចំផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានថ្មី ការយល់ដឹង ពិគ្រោះយោបល់ការ អនុវត្តនិងការស្ដារឡើងវិញនៃប្រជាពលរដ្ឋដែលទទួលនូវផលប៉ះពាល់ និងភាពពេញចិត្តនឹងត្រូវបានអនុវត្ត ដោយប្រើទិន្នន័យដោយឡែកៗពីជនជាតិភាគតិច។

(១០). ការតាមដាននៅក្នុងគម្រោង នឹងពិគ្រោះយោបល់ដោយភ្ជាប់ជាមួយនូវការបកប្រែជាភាសាជនជាតិដើម ភាគតិចនៅតាមភូមិដែលមានជនជាតិដើមរស់នៅ និងសម្រាប់ក្រុមជនជាតិភាគតិចដែលកំពុងរស់នៅនៅតាម បណ្ដា ភូមិជាមួយជនជាតិដើមផ្សេងៗទៀត។

(១១). សមាជិកស្ត្រី និងបុរសជនជាតិដើមភាគតិចនឹងអាចចូលរួមនៅក្នុងការងារនានា ដែលត្រូវបានបង្កើតឡើង ក្នុងកំឡុង ពេលនៃការស្ដាបនា និងថែទាំផ្លូវនៅតាមទីតាំងរបស់គម្រោងនានា។

## ក១.៤. ការរៀបចំផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានថ្មី

### ១. ការរៀបចំ

***១១.*** ប្រសិនបើការតាំងលំនៅដ្ឋានថ្មីគឺមិនអាចជៀសបាន និងការរៀបចំផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានថ្មីត្រូវបានតម្រូវ ផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានថ្មីនឹងរៀបចំការប្រើប្រាស់នូវនីតិវិធីដូចខាងក្រោម:

(១). អនុវត្តជំរឿននូវរាល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់

(២). អនុវត្តនូវវិធានការអង្កេតឱ្យបានស៊ីជម្រៅ ការអង្កេតវិធានការលំអិតនូវរាល់ការបាត់បង់នៃប្រជាជនដែល ទទួលរងផលប៉ះពាល់ទាំងអស់។ ក្នុងពេលដំណាលជាមួយគ្នានោះ បង្ហាញពីសក្ដានុពលប្រជាជនដែលទទួលរង ផលប៉ះពាល់ (ដោយមិនមានការរើសអើង) ដោយការវិនិយោគ ដូចជាផលប៉ះពាល់ និងគោលការណ៍នានា និង ការផ្ដល់សិទ្ធិដែលជាគម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានថ្មី។

(៣). អនុវត្តការអង្កេតទៅលើសេដ្ឋកិច្ចសង្គម (SES) ដែលយ៉ាងហោច ១០ ភាគរយនៃ APs និង ២០ ភាគរយ នៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ និងចំនួននៃជនជាតិដើមភាគតិច។

(៤). អនុវត្តការអង្កេតពីតម្លៃការផ្លាស់ទីតាំងនូវប្រភេទផ្សេងៗនៃការប៉ះពាល់ទ្រព្យសម្បត្តិ ដែលជាមូលដ្ឋានគ្រឹះ ដើម្បីកំណត់ពីអត្រានៃសំណងនៅក្នុងតម្លៃនៃការផ្លាស់ប្តូរ។ កំណត់នូវការបាត់បង់ដោយយោងទៅតាមតារាង ម៉ាទ្រិកនៃការផ្តល់សិទ្ធិ។

(៥).ផ្តល់នូវព័ត៌មាននៃការតាំងទីលំនៅដ្ឋានថ្មី និងគម្រោងទៅដល់ប្រជាពលរដ្ឋដែលបានទទួលផលប៉ះពាល់នៅ ក្នុងរូបភាព និងភាសាដែលអាចឱ្យពួកគេយល់ និងពិគ្រោះយោបល់ជាមួយពួកគេយ៉ាងជិតស្និទ្ធស្តីពីការផ្តល់ សំណង និងជម្រើស នៃការតាំងលំនៅដ្ឋានថ្មី ដោយរួមមានទាំងទីតាំងសាងសង់ថ្មី និងការស្តារសេដ្ឋកិច្ចឡើងវិញ។

(៦). រៀបចំនូវពង្រៀងផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានថ្មី ជាមួយនូវពេលវេលានៃផែនការអនុវត្តនីតិវិធី នានាសម្រាប់យន្តការសារទុក្ខ និងតាមដាន និងវាយតម្លៃ និងថវិកា។

(៧). បញ្ចប់នូវការផែនការវិនិយោគសកម្មភាពនៃការតាំងលំនៅដ្ឋានថ្មី និងបកប្រែជាភាសាតំបន់ (មូលដ្ឋាន)

(៨).បិទផ្សាយនូវពង្រៀង និងបញ្ចប់នូវផែនការសកម្មភាពនៃការតាំងទីលំនៅដ្ឋានថ្មីដោយស្របទៅតាមគោលនយោបាយធនាគារពិភពលោកស្តីពីការផ្សព្វផ្សាយជាសាធារណៈទៅកាន់សហគមន៍ដែលទទួលរងនូវផលប៉ះពាល់ និងស្តីពីព័ត៌មានសារធារណៈ (Infoshop) របស់ធនាគារពិភពលោក។ សេចក្តីព្រៀងផែនការសកម្មភាពនៃ ការតាំងទីលំនៅដ្ឋាន ថ្មីនឹងត្រូវបានបិទផ្សាយទៅដល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ជាមុនដើម្បីធ្វើ ការដាក់ជូនទៅធនាគារពិភពលោកដើម្បីអនុម័ត។ សេចក្តីបញ្ចប់ផែនការសកម្មភាពនៃការតាំងទីលំនៅដ្ឋានថ្មី នឹងត្រូវបានបិទផ្សាយ បន្ទាប់ពីមានការអនុម័ត។

**តារាងទី ៤: ការអង្កេតសម្រាប់ការរៀបចំផែនការសកម្មភាពនៃការតាំងទីលំនៅដ្ឋានថ្មី**

| | |
|---|---|
| **វិធានការអង្កេតលំអិត** | ការជំរឿន និងវិធានការអង្កេតលំអិតនៃការបាត់បង់ទ្រព្យសម្បត្តិនឹងត្រូវបានប្រមូលទិន្នន័យស្តីពីទ្រពសម្បត្តិដែលបានប៉ះពាល់ ពី ១០០ ភាគរយនៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់តាមរយៈការរៀបចំវិស្វកម្មលំអិត។ ទិន្នន័យដែលបានប្រមូល ក្នុងកំឡុងពេលនៃការធ្វើវិធានការអង្កេតលំអិតនឹងបង្កើតឡើងនូវមូលដ្ឋានជាក់លាក់មួយសម្រាប់ការកំណត់នូវការផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ និងកម្រិតនៃការផ្តល់សំណង។ សម្រាប់ប្រជាពលរដ្ឋដែលទទួលរងនូវ ផលប៉ះពាល់ សេចក្តីសង្ខេបនៃទិន្នន័យនឹងរួមបញ្ចូល:<br>• ទីតាំងសរុបនៃដីដែលទទួលរងផលប៉ះពាល់ទៅតាមប្រភេទនៃដីនីមួយៗ<br>• ទីតាំងសរុបនៃរចនាសម្ព័ន្ធដែលទទួលរងផលប៉ះពាល់ទៅតាមប្រភេទនៃរចនាសម្ពន្ធ័ (សំខាន់ រឺបន្ទាប់បន្សំ)<br>• ស្ថានភាពស្របច្បាប់នៃដីដែលទទួលរងនូវផលប៉ះពាល់ និងទ្រព្យសម្បត្តិផ្សេងៗ និងក្នុងកំឡុងពេលកាន់កាប់ និងភាព ជា ម្ចាស់។<br>• បរិមាណ និងប្រភេទនៃដើមឈើ និងដំណាំដែលបានប៉ះពាល់<br>• បរិមាណ និងការបាត់បង់ផ្សេងៗទៀត ឧ... មុខរបរ រឺប្រាក់ចំណូល ការងារ រឺទ្រព្យសម្បត្តិដែលផ្តល់ផលផ្សេងៗទៀត ត្រូវបានប៉ាន់ប្រមាណនូវប្រាក់ចំណូលប្រចាំថ្ងៃពីតូបលក់ដូរធម្មតា។ |

| | |
|---|---|
| | • បរិមាណ/តំបន់នៃទ្រព្យសម្បត្តិសម្ភូហភាពដែលបានរងនូវផលប៉ះពាល់ សហគមន៍ រឺទ្រព្យសម្បត្តិសាធាណៈ ទៅតាម ប្រភេទនីមួយៗ។<br>• ទិន្នន័យសង្ខេបស្តីពីគ្រួសារដែលទទួលរងផលប៉ះពាល់ ជនជាតិដើមភាគតិច យេនឌ័រនៃមេគ្រួសារ ទំហំនៃគ្រួសារ ប្រភពចំណូលសំខាន់ៗ និងបន្ទាប់បន្សំនៃគ្រួសារ កម្រិតនៃប្រាក់ចំណូល ថាតើគ្រួសារដែលស្ត្រីជាមេគ្រួសារ ចាស់ជរា ពិការ ក្រីក្រ រឺក្រុមជនជាតិដើមភាគតិច។<br>• កំណត់ថាតើដីដែលទទួលរងនូវផលប៉ះពាល់ រឺប្រភពនៃប្រាក់ចំណូលគឺជាប្រភពដ៏សំខាន់នៃចំណូល និង<br>• ការយល់ដឹងនៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ទៅលើការវិនិយោគ និងការពេញចិត្តចំពោះសំណង និងដែល ត្រូវបានតម្រូវចំពោះការតាំងទីលំនៅថ្មី និងវិធានការស្តារឡើងវិញ។ |
| **ការអង្កេតសេដ្ឋកិច្ចសង្គម** | នៅកម្រិតទាប ការអង្កេតទៅលើសេដ្ឋកិច្ចសង្គម នឹងប្រមូលព័ត៌មានពីគំរូពី ១០ ភាគរយនៃប្រជាពលរដ្ឋដែលទទួលរង ផលប៉ះពាល់ និង ២០ ភាគរយនៃប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដែលមិនបានដាក់បញ្ចូលដោយយេនឌ័រ និង ជនជាតិដើមភាគតិច។ គោលបំណងនៃការអង្កេតសេដ្ឋកិច្ចសង្គម គឺដើម្បីផ្តល់នូវព័ត៌មានមូលដ្ឋានស្តីពីប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដើម្បីវាយតម្លៃផលប៉ះពាល់នៃការតាំងលំនៅដ្ឋានថ្មី និងធ្វើឱ្យប្រាកដថាការផ្តល់សិទ្ធិដែលបានស្នើឡើងគឺមាន ភាពពេញចិត្ត និងត្រូវបានប្រើប្រាស់ដើម្បីការតាមដាននៃការតាំងលំនៅដ្ឋានថ្មី។ សេចក្តីសង្ខេបនៃទិន្នន័យដែលត្រូវបាន ប្រមូលរួមមាន:<br>ក. មេគ្រួសារ: ឈ្មោះ ភេទ អាយុ ការប្រកបមុខរបរចិញ្ចឹមជីវភាព រឺមុខរបរ ការសិក្សា និងជនជាតិ<br>ខ. សមាជិកគ្រួសារ: ចំនួន ការប្រកបមុខរបរចិញ្ចឹមជីវភាព ចំនួនកូនសិក្សា និងចេះអក្សរ ដោយមិនបានរួមបញ្ចូលដោយ យេនឌ័រ។<br>គ. លក្ខខណ្ឌរស់នៅ: ការប្រើប្រាស់ទឹក អនាម័យ និងថាមពលសម្រាប់ចំអិនអាហារ និងការបំភ្លឺផ្ទះ ភាពជាម្ចាស់នៃសម្ភារៈ ដែលមានភាពរឹងមាំ និង<br>ង. ការប្រើប្រាស់សេវា និងការសម្របសម្រួលចាំបាច់នានា |
| **ការអង្កេតទៅលើតម្លៃនៃការតាំងលំនៅដ្ឋានថ្មីឡើងវិញ** | ការអង្កេតទៅលើតម្លៃនៃការតាំងលំនៅដ្ឋានថ្មីនឹងត្រូវបានធ្វើឡើងដោយស្របគ្នាទៅនឹងសកម្មភាពនៃវិធានការអង្កេត លំអិតនិងការអង្កេតសេដ្ឋកិច្ចសង្គមតាមរយៈការប្រមូលទិន្នន័យពីប្រភព សំខាន់ៗ និងបន្ទាប់បន្សំ (ដោយធ្វើសម្ភាសន៍ផ្ទាល់ជាមួយ ប្រជាពលរដ្ឋនៅតាមតំបន់ប៉ះពាល់ អ្នកផ្គត់ផ្គង់សម្ភារៈ ម្ចាស់កិច្ចសន្យាសាងសង់ផ្ទះ) និងពីអ្នកដែលទទួលរងនូវផល ប៉ះពាល់ រឺអ្នកដែលមិនទទួលរង។ |

៤. ទិន្នន័យនឹងជាយែនឌ័រ និង ក្រុមជនជាតិដែលមិនត្រូវបានរើសអើង

៥. វានឹងបញ្ចូលនូវការវិភាគលើយែនឌ័រ ហើយទិន្នន័យនឹងជា យែនឌ័រ និង ក្រុមជនជាតិដែលមិនត្រូវបានរើសអើង

៦. ប្រសិនបើមានប្រភេទថ្មីនៃ PAPs រឺក៏ការបាត់បង់ដែលត្រូវបានកំណត់កំឡុងពេលនៃ DMS (ក្រៅពីការបាត់បង់ដែលពណ៌នានៅក្នុងម៉ាទ្រិកនៃការផ្តល់សិទ្ធិ) ការផ្តល់សិទ្ធនឹងស្របទៅតាម គោលនយោបាយ និង គោលការណ៍ណែនាំរបស់ធនាគារពិភពលោក

## ២. ការអនុវត្តផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានថ្មី

១២. ការទទួលដី សំណង និងការតាំងទីលំនៅដ្ឋានថ្មីឡើងវិញនៃប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់មិនអាចចាប់ផ្តើមរហូត ដល់ផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានថ្មីត្រូវបានសង្ខេប និងអនុមត័ដោយធនាគារពិភពលោក។ ការចាប់ផ្តើម

នៃ ការងារសង្គមអាចចាប់ផ្តើមនៅក្នុងផ្នែកខ្លះៗដែលមិនមានផលប៉ះពាល់ដល់ការតាំងលំនៅដ្ឋានថ្មី។ រាល់សកម្មភាព នៃការ តាំងលំនៅដ្ឋានថ្មី នឹងត្រូវបានសម្របសម្រួលជាមួយផែនការការងារសង្គម។ ធនាគារពិភពលោកនឹងមិនអនុញ្ញាត ឱ្យមាន សកម្មភាពសាងសង់នៅតាមទីតាំងជាក់លាក់នានារហូតដល់សកម្មភាពតាំងលំនៅដ្ឋានថ្មីត្រូវបានបញ្ចប់ដោយការ ពេញចិត្ត យល់ព្រមនូវជំនួយស្តារឡើងវិញចូលជាធរមាន និងទីតាំងទាំងនោះមិនមានការជំទាស់។

## ក១.៥ ការពិគ្រោះយោបល់នៅតាមសហគមន៍ និងដំណើរការចូលរួម

១៣.គម្រោងសម្រាប់ដំណើរការចូលរួមនៅក្នុងគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គត្រូវបានបង្ហាញនៅក្នុងតារាង ទី៩ដែលកំណត់នូវតួនាទីនានានៃអ្នកដែលទទួលនូវផលប្រយោជន៍ និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ និង ហេតុផល នានាសម្រាប់ការការចូលរួមរបស់ពួកគេនៅរាល់ដំណាក់ការនៃសកម្មភាពសហគមន៍ និងសកម្មភាពនៃការ តាំង លំនៅដ្ឋានថ្មី។

**តារាងទី ៥: គម្រោងសម្រាប់ការពិគ្រោះយោបល់នៅតាមសហគមន៍ និងដំណើរការចូលរួមនៅក្នុងគម្រោងគ្រប់គ្រងធនធានទឹក ចម្រុះទន្លេមេគង្គ (M-IWRMP)**

| ជំហាននានា | កម្មវត្ថុនៃការពិគ្រោះយោបល់ | តួនាទីនៃសហគមន៍ដែលផ្តោត និង គ្រួសារ/មនុស្សដែលបានទទួលផលប៉ះពាល់ | ហេតុផលនានានៃការចូលរួមរបស់សហគន៍ |
|---|---|---|---|
| **ជំហាននៃការរៀបចំ**<br>• ការពិគ្រោះ និងក្រុមដែលផ្តោតលើក្នុងការប្រជុំ និងពិភាក្សា ។<br>• ផែនការសម្រាប់ការវិនិយោគ<br>• គំរូនៃការផ្តល់សំណង និងកញ្ចប់នៃការផ្តល់សិទ្ធិ ។<br>• កិច្ចពិគ្រោះយោបល់ស្តីពីការវិនិយោគដែលបានស្នើឡើង/មុនពេលការដាក់ស្នើទៅគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ។ | • ការយល់ដឹងពីការវិនិយោគ<br>• ផែនការ និងការរៀបចំ វិនិយោគ<br>• ការផ្តល់សំណង និងកញ្ចប់នៃការផ្តល់ សិទ្ធិដល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ។<br>• មាតិការនៃការវិនិយោគដែលបានស្នើសុំ | • ការចូលរួមពិគ្រោះយោបល់នៅក្នុងសហគមន៍<br>• បង្កើតគណៈកម្មការយ៉ាងហោច ២៥- ៥0% នៃសមាជិកត្រូវបានចូលរួមដោយស្ត្រី ។<br>• អនុម័តការរៀបចំ និងស្នើដោយអ្នកដែលទទួលនូវផលប្រយោជន៍ និងប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ ។<br>• អនុម័តនូវសំណង និង កញ្ចប់នៃការផ្តល់សិទ្ធិនៃប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់<br>• សង្ខេប និងមាតិការដែលស្របគ្នានៃការវិនិយោគដែលបានស្នើសុំ | • ប្រាកដថាអ្នកដែលទទួលផលប្រយោជន៍ដែលផ្តោតលើ និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់មានការដឹងយ៉ាងច្បាស់ពីការវិនិយោគដែលបានដាក់ស្នើ និងបានដឹងនូវផលប្រយោជន៍របស់វា ។<br>• លើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តជាសមូហភាព<br>• ប្រមូលនូវបញ្ហានានា និងភាពទាក់ទងទៅនឹងសហគមន៍ដែលអាចត្រូវបានដាក់បញ្ចូលទៅក្នុងការវិនិយោគគម្រោងគ្រប់គ្រងធនធានចម្រុះទន្លេមេគង្គ ។<br>• វិធានការនេះនឹងកាត់បន្ថយនូវជំលោះនានា និងផ្ញើសារទៅកាន់អ្នកទទួលផលប្រយោជន៍ និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ទាំងឡាយដែលពួកគេបានជាប់ពាក់ព័ន្ធ និងដែលមកពីការសម្រេចចិត្តជាសមូហភាពរបស់ពួកគេ ។<br>• វាក៏ត្រូវបានលើកកម្ពស់ផងដែរចំពោះការសម្រេចចិត្តសមូហភាពក្នុងចំណោមអ្នកទទួលផលប្រយោជន៍ និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់នានា ។<br>• ការពិគ្រោះយោបល់បែបនេះផ្តល់នូវសារនៃការមើលឃើញនូវសមភាពដែលពួកគេពន្យល់/ស្នើ និងត្រូវបានភ្ជាប់នៅក្នុងការវិនិយោគដែលបានស្នើ ឡើង ។ |
| **ជំហាននៃការអនុវត្ត**<br>• កិច្ចពិគ្រោះយោប់ស្តីពីការអនុវត្តនៃវិនិយោគ និងការផ្តល់ និងប្រគល់ឱ្យ រឹការតាំងលំនៅដ្ឋានថ្មីប្រសិនបើមាន | • គ្រប់ដំណាក់កាលនៃការផ្លាស់ប្តូរ និងការអនុវត្តវិនិយោគ ត្រូវមានការយល់ព្រមពីប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ។<br>• កិច្ចយល់ព្រមស្តីពីផែនការនៃការផ្លាស់ប្តូរ រឹការតាំង | • ប្រសិនបើមាន ការសាងសង់ឡើងវិញ និងការរុះរើនោះប្រកបដោយសណ្តាប់ធ្នាប់ នូវរចនាសម្ព័ន្ធដែលប៉ះពាល់ ។ | • ធានាថាផលប៉ះពាល់នានានៃការរំខានត្រូវបានកាត់បន្ថយ<br>• វានឹងអាចឱ្យភ្នាក់ងារអនុវត្តផងដែរ ដើម្បីធ្វើការសម្រេចចិត្តលើថវិកាសម្រាប់ការធ្វើដំណើរ និងអាហារដល់ប្រជាពលរដ្ឋដែលទទួលរងនូវផល |

| ជំហាននានា | កម្មវត្ថុនៃការពិគ្រោះយោបល់ | តួនាទីនៃសហគមន៍ដែលផ្តោត និង គ្រួសារ/មនុស្សដែលបានទទួលផលប៉ះពាល់ | ហេតុផលនានានៃការចូលរួមរបស់សហគន៏ |
|---|---|---|---|
| • ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ទាក់ទងទៅនឹងផលប៉ះពាល់ និងរចនាសម្ព័ន្ធនានា មុខរបរចិញ្ចឹមជីវិត..... ។ល ។<br>• ភាពជាប់ទាក់ទងនៅក្នុងជីវភាពរស់នៅ<br>• ការផ្តល់ការងារដល់អ្នកដែលទទួលផលប្រយោជន៏នៅក្នុងការវិនិយោគ<br>• ការជួសជុល និងការឈើចាប់ (សំណង)<br>• ការតាមដានផ្នែកខាងក្រៅ | លំនៅថ្មីតាមតំបន់ដែលព្រមព្រៀងនៅតាមសហគមន៏ ។<br>• ព្រំប្រទល់នៃក្បាលដី ផ្លូវ និងទីតាំងដែលបំរុង ទុកសម្រាប់ សេវាសង្គម ឧ. ទឹកស្អុយ និងការបង្ហូរកាកសំណល់ ។<br>• ជីវភាពរស់នៅសហគមន៏ដែលទទួលផលប្រយោជន៏ និងប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ទាំងនោះ ។<br>• ជំនួយបន្ថែមទៅដល់អ្នកទទួលផលប្រយោជន៏ និង ប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ ។<br>• យន្តការនៃការសារទុក្ខ<br>• ការអនុវត្តន៏នៃវិនិយោគ | • ផ្តល់ព័តិមានដល់ប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់នូវផែនការនៃការផ្លាស់ប្តូរ<br>• កត់សំគាល់នូវទីតាំងដែលមានផលប៉ះពាល់ដូចដែលបានកំណត់តាមរយៈអ្នកពិនិត្យដីដែលស្របទៅតាមផែនការ និងតំបន់ដែលបានកំណត់ ។<br>• ផ្តល់ព័តិមានស្តីពីផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានទៅដល់ប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ ។<br>• ភាពពាក់ព័ន្ធនៃស្ត្រីនៅក្នុងការអភិវឌ្ឍន៏ជីវភាពរស់នៅ<br>• អ្នកទទួលផលប្រយោជន៏ រឺសមាជិកនៃក្រុមគ្រួសាររបស់ពួកគេនឹងត្រូវបានផ្តល់ការងារក្នុងកំឡុងពេលនៃការសាងសង់នៃការវិនិយោគ ។<br>• ផ្តល់នូវសារតានៃបញ្ហាទាំងនោះ<br>• ផ្តល់នូវធាតុចូល និងស្ថានភាពសម្រាប់ការអនុវត្តន៏ការវិនិយោគរបស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ។ | ប៉ះពាល់ (គ្រួសារ) ។<br>• ការចូលរួមនៅក្នុងការកំណត់ក្បាលដីនៅក្នុងវត្តមាននៃមន្ត្រីដែលបានកំណត់/អ្នកសម្របសម្រួល និងជៀសវាងនូវភាពយល់ខុសក្នុងចំណោមអ្នកដែលទទួលផលប្រយោជន៏ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ។<br>• អាចឱ្យភ្នាក់ងារអនុវត្តដើម្បីប៉ាន់ប្រមាណនូវថវិកាសម្រាប់ការផ្តល់ឈ្នោះ ដូចជា ប្រាក់ឧបត្ថម្ភសម្រាប់អាហារ ការធ្វើដំណើរ និងជំនួយពិសេសថែមទៀត ។<br>• ស្ត្រីត្រូវបានគេស្គាល់ថាមានជំនាញនៅក្នុងការគ្រប់គ្រងជីវភាពរស់នៅប្រចាំថ្ងៃ ដែលបង្កើនប្រាក់ចំណូលដល់គ្រួសារ ។<br>• ការងារជាមួយគម្រោងនឹងផ្តល់បន្ថែមផងដែរ រឺបង្កើនប្រាក់ចំណូលរបស់ពួកគេ ។<br>• ធានាថាបញ្ហានានាគឺបង្ហាញទៅតាមពេលវេលាសមស្របមួយ មន្ត្រីមួយចំនួននឹងបម្រើដូចជាគណកម្មការដោះស្រាយផលប៉ះពាល់ ហើយពួកគេនឹងជួយភ្នាក់ងារផងដែរនៅក្នុងការអនុវត្តគោលនយោបាយនានានៅតាមសហគមន៏ ដែលជាផ្នែកមួយនៃការគ្រប់គ្រងវិនិយោគ ។<br>• ព័តិមានពីប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ និងអ្នកដែលទទួលបានផលប្រយោជន៏នឹងជួយផ្នែកវិនិយោគគម្រោង ដើម្បីវាយតម្លៃពីកម្រិតនៃការយល់ព្រមនូវរាល់ជំហាននៃការអនុវត្តវិនិយោគ ។<br>• ទាំងនេះនឹងផ្តល់នូវមេរៀននៅក្នុងការសម្រួចគោលនយោបាយទៅពេលអនាគតស្តីពីការតាំងលំនៅដ្ឋានឡើងវិញសម្រាប់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ។ |

## ក១.៦ យុទ្ធសាស្ត្រនានានៃយេនឌ័រ

***១៤.*** បរិមាណនៃយុទ្ធសាស្ត្រនានានឹងត្រូវបានយល់ព្រមដើម្បីធានានូវការតាំងលំនៅដ្ឋានឡើងវិញ និងវិធានការនានាក្នុងការស្ដាបនាឡើងវិញ និងដើម្បីឱ្យស្ត្រីមានភាពសកម្មនៅក្នុងការអនុវត្ត និងរៀបចំផែនការនៃកម្មវិធីតាំងលំនៅដ្ឋានឡើងវិញ ក៏ដូចជាកម្មវិធីផ្សេងៗទៀត។ គណៈកម្មការតាំងលំនៅដ្ឋានឡើងវិញ អ្នកជំនាញការតាំងលំនៅដ្ឋាននឹងត្រូវបានជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនូវរាល់ទិដ្ឋភាពនៃការអនុវត្តន៍ និងការអភិវឌ្ឍន៍នៃយុទ្ធសាស្ត្រយេនឌ័រដើម្បីធានាថាវិធានការទាំងនេះគឺត្រូវបានអនុវត្តត្រឹមត្រូវ។

***១៥.*** យុទ្ធសាស្ត្រនានាសម្រាប់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់នឹងតាំងលំនៅថ្មីពី រឺសាងសង់ឡើងវិញនូវលំនៅដ្ឋាន និង/រឺដីដែលមានលក្ខណៈសេដ្ឋកិច្ចដែលពួកគេកាន់កាប់នៅក្នុងតំបន់វិនិយោគនឹងត្រូវប្រកាន់យកនូវការគិតគូរដល់ស្ត្រី តាមមធ្យោបាយនានាដូចខាងក្រោម:

១. គណកម្មការតាំងលំនៅដ្ឋានថ្មីនឹងធ្វើកិច្ចខិតខំប្រឹងប្រែងដើម្បីពិគ្រោះយោបល់ជាមួយស្ត្រីដែលទទួលរងនូវផលប៉ះពាល់ (មេគ្រួសារ និងស្ត្រីនៅក្នុងគ្រួសារ)។ នេះនឹងត្រូវបានធ្វើឡើងតាមរយៈការពិភាក្សាជាក្រុម រឺដាច់ដោយឡែកជាមួយស្ត្រី។ តួនាទីនៃក្រសួងកិច្ចការនារី និងអតីតយុទ្ធជន តំណាងមូលដ្ឋាន នឹងជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងការសម្របសម្រួលនូវកិច្ចពិគ្រោះយោបល់ទាំងនេះ និងដើម្បីធានាថាតម្រូវការជាក់លាក់របស់ស្ត្រីត្រូវបានដោះស្រាយ។

២. ជាបន្ថែមទៅលើកិច្ចប្រជុំភូមិ ការប្រជុំក្រុមស្ត្រីនឹងត្រូវបានធ្វើឡើងដើម្បីបង្កើននូវការយល់ដឹងពីបញ្ហា នានាទាក់ទងទៅនឹងការតាំងលំនៅដ្ឋានថ្មី ដូចជាពេលវេលានៃគម្រោងការផ្ដល់សិទ្ធិ ការកំណត់នូវសំណង និងចំនួនប្រាក់សំណង ដំណើរការនៃការព្រួយបារម្ភ គាំទ្រដល់ការតាំងលំនៅដ្ឋានថ្មី រឺការសាងសង់ឡើងវិញ។

៣. ស្ត្រីនឹងត្រូវបានពិគ្រោះយោបល់យ៉ាងពិសេសដើម្បីបង្កើតនូវលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្ដល់ដីជំនួស រឺបង្កើនលើដីដែលមានស្រាប់ ជាពិសេសទាក់ទងទៅនឹងផែនការនៃដីដែលអាចមាន និងរក្សានូវតំបន់-ដីដែលមានអត្ថប្រយោជន៍ដល់គ្រួសារ ក៏ដូចជាបញ្ហានានាទាក់ទងទៅនឹងភាពទទួលបាននូវសម្ភារៈបរិក្ខារ និងសេវាកម្មដល់សហគមន៍ ដូចជាសាលារៀន បរិក្ខារសុខភាព និងផ្សារ ក៏ដូចជាសកម្មភាពសេដ្ឋកិច្ចនានា។

៤. កិច្ចពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ដែលទាក់ទងទៅនឹងការរៀបចំសម្រាប់សិទ្ធិដែលជៀសវាងនូវភាពគ្រោះថ្នាក់ និងធានាថាស្ត្រីដោយរួមទាំងស្ត្រីដែលជាមេគ្រួសារ និងស្ត្រីផ្សេងៗទៀតនៅក្នុងគ្រួសារឱ្យបានយល់ច្បាស់ពីអ្វីជាតួនាទី និងជម្រើសរបស់ពួកគេ និងអ្វីជាទស្សនៈរបស់ស្ត្រីត្រូវបានគិតគូរនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។

៥. ការចុះបញ្ជីដីថ្មី នឹងត្រូវបានធ្វើឡើងដោយរួមមានទាំងឈ្មោះប្តី និងប្រពន្ធ ប្រសិនបើដីដែលទទួលតាមរយៈគម្រោងត្រូវបានផ្តល់ឱ្យទៅប្តី និងប្រពន្ធក្នុងពេលរៀបការ រឺក្នុងករណីគ្រួសារមានស្ត្រីជាមេគ្រួសារហើយដែលមានឈ្មោះជាស្ត្រី ។

៦. ការចំណាយប្រាក់សំណងនឹងត្រូវបានបញ្ជាក់ដោយប្តី ប្រពន្ធ រឺនៅក្នុងករណីគ្រួសារដែលមានស្ត្រីដែលជាមេគ្រួសារ ។

៧. កិច្ចសន្យាការងារសង្គមនានា នឹងរួមបញ្ចូលទាំងការងារទៅដល់អ្នកក្រ និងស្ត្រីនៅតាមមូលដ្ឋាន និងតាមភូមិដែលទទួលរងផលប៉ះពាល់ពីគម្រោង ។ ពួកគេក៏នឹងត្រូវបានរួមបញ្ចូលផងដែរនូវការដាក់បញ្ចូលដោយប្តេជ្ញាចិត្តលើសមធមិនៃយេនឌ័រៈ (១).ធានាថាគ្មានការប្រើប្រាស់រំលោភលើកំលាំងពលកម្មចំពោះកុមារត្រូវបាន ប្រើប្រាស់, (២).គ្មានការរើសអើងប្រឆាំងទៅនឹងការផ្តល់ការងារដល់ស្ត្រីដែលមានលទ្ធភាពធ្វើការបាន និង (៣). គ្មានការផ្តល់ប្រាក់ឈ្នួលលខុសគ្នារវាងស្ត្រី និងបុរសចំពោះការងារដែលមានតម្លៃដូចគ្នា ។

៨. វិធានការពិសេសនានានឹងត្រូវបានអនុវត្តទៅក្នុងព័ត៌មាននៃការរើសអើង និងពិគ្រោះយោបល់ជាមួយស្ត្រីដើម្បីធានាថាពួកគេមានការយល់ដឹងយ៉ាងច្បាស់នូវគោលនោបាយ សិទ្ធិ និងនីតិវិធីនានាស្តីពីកម្មវិធីនៃការ តាំងលំនៅដ្ឋានឡើងវិញ និងអាចផ្តល់នូវការសម្រេចចិត្តដែលបានឱ្យជាដំណឹងជាមុន ។

៩. ក្រសួងកិច្ចការនារី និងអតីតយុទ្ធជននៅតាមតំបន់ភូមិប៉ះពាល់នឹងពិនិត្យលើប្រជាពលរដ្ឋដែលទទួលរងនូវ ផលប៉ះពាល់ដោយរួមមានទាំងស្ត្រីដែលជាមេគ្រួសារសម្រាប់កំណត់ពីការបារម្ភ និងផលប៉ះពាល់សុខភាព ដោយសារសកម្មភាពនានានៃការតាំងលំនៅដ្ឋានឡើងវិញ ។ ប្រសិនបើត្រូវបានកត់ទាំងនេះត្រូវបាន រាយការណ៍ទៅដល់គណកម្មការតាំងលំនៅដ្ឋានឡើងវិញ ។

១០. ប្រពន្ធ័ព័ត៌មានស្តីពីការតាំងទីលំនៅដ្ឋានឡើងវិញ នឹងធានាថារាល់សូចនាករតាមដាន និងទិន្នន័យត្រូវបានបញ្ចូលទៅក្នុងយេនឌ័រ ។

១១. ផ្នែកគ្រប់គ្រងគម្រោង នឹង ផ្តល់ការបណ្តុះបណ្តាលសម្រាប់គណកម្មការតាំងលំនៅដ្ឋានឡើងវិញទាំងអស់ ដើម្បីការកសាងសមត្ថភាពនៅក្នុងការគ្រប់គ្រងនៃការតាំងលំនៅដ្ឋានឡើងវិញ និងដើម្បីលើកកម្ពស់យេនឌ័រ និងជនជាតិដើមភាគតិចនៅក្នុងការគ្រប់គ្រងការតាំងលំនៅដ្ឋានឡើងវិញ ។

***១៦.*** ស្ត្រីដែលជាមេគ្រួសារ រឺជាសមាជិកនៃគ្រួសារដែលទទួលរងនូវផលប៉ះពាល់ ក៏ដូចជាស្ត្រីផ្សេងៗទៀតនៅក្នុងសហគមន៍នឹងត្រូវបានលើកទឹកចិត្ត និងជួយដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងការអនុវត្ត និងការធ្វើផែនការនៃកម្មវិធីតាំងលំនៅដ្ឋានរបស់គម្រោង តាមរយៈការទាញយកនូវចំណេះដឹងរបស់ពួកគេ ជំនាញ និងការចាប់អារម្មណ៍ ។ សកម្មភាពនានាដែលមាននៅក្នុងគម្រោងវាយតម្លៃ មានគោលបំណងដើម្បីសម្របសម្រួលការចូលរួមនេះ ដោយរួមទាំងចំណោមអ្នកផ្សេងៗទៀត ។

១. សមាជិកស្ត្រីនៃគណៈកម្មការតាំងលំនៅដ្ឋានឡើងវិញ នឹងត្រូវបានគាំទ្រនៅក្នុងតួនាទីរបស់វាតាមរយៈការផ្លាស់ប្តូរជាមួយស្ត្រីនៅក្នុងគណៈកម្មការតាំងលំនៅដ្ឋានឡើងវិញ ពីផ្នែកផ្សេងៗនៃផ្លូវលំដើម្បីយកបទពិសោធន៍ពីបណ្តាភូមិផ្សេងៗទៀត ។

២. ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ជាស្ត្រី (មេ រឺសមាជិកនៃគ្រួសារទទួលរងផលប៉ះពាល់) នឹងត្រូវបានជាប់ទាក់ទងជាមួយមន្ត្រីនៅតាមមូលដ្ឋាននៅក្នុងការកំណត់ សង្ខេប និងជ្រើសរើសនៃទីតាំងដីជំនួសសម្រាប់បុគ្គលម្នាក់ រឺដីដែលមានលក្ខណៈពាណិជ្ជកម្ម ក៏ដូចជាកន្លែងតាំងលំនៅដ្ឋានឡើងវិញ។ ស្ត្រីក៏នឹងត្រូវបានពិគ្រោះយោបល់ផងដែរអំពីការអភិវឌ្ឍន៍ទីតាំងលំនៅដ្ឋានឡើងវិញ ដូចជាកន្លែងផ្គត់ផ្គង់ទឹក ។

៣. ស្ត្រីនឹងត្រូវបានពិគ្រោះយោបល់នៅក្នុងការរៀបចំផែនការសម្រាប់ការតាំងលំនៅដ្ឋានថ្មី រឺការផ្លាស់ទីកន្លែងនៃភូមិដែល ទទួលរងផលប៉ះពាល់ ដូចជាកន្លែងផ្តល់ទឹក និងម៉ាស៊ីនកិនស្រូវ ជាពិសេសដូចជាស្ត្រី និងកុមារដែលជាអ្នកដងទឹក យ៉ាងសំខាន់ ។

៤. ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ជាស្ត្រី និងស្ត្រីផ្សេងៗទៀតនៅក្នុងសហគមន៍មូលដ្ឋាននឹងត្រូវបានជាប់ទាក់ទងនៅក្នុងការធ្វើផែនការនៃសកម្មភាពតាំងលំនៅដ្ឋានឡើងវិញ តាមរយៈការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយសហគមន៍ដែលផ្លាស់ប្តូរទីតាំង ហើយត្រូវបានជួយតាមរយៈពួកគេដើម្បីអភិវឌ្ឍន៍ផែនការសម្រាប់គ្រួសាររបស់ពួកគេ រួមទាំងភាពចាំបាច់ ការសម្របសម្រួលបច្ចេកទេស ការផ្តល់ប្រឹក្សានៃការតាំងលំនៅដ្ឋានឡើងវិញ និងការសាងសង់ ដែលគាំទ្រចាប់តាំងពីមន្ត្រីថ្នាក់ភូមិទៅដល់ស្រុក ។

៥. ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ជាស្ត្រី និងស្ត្រីផ្សេងៗទៀតនៅក្នុងសហគមន៍មូលដ្ឋាននឹងត្រូវបានជាប់ទាក់ទងនៅក្នុងគំនិតផ្តួចផ្តើមមួយចំនួន ដើម្បីបង្ហាញពីផលប៉ះពាល់នានារបស់គម្រោងទៅលើនៃបរិស្ថាន និងសង្គម ដូចជា ក). ការបណ្តុះបណ្តាលពីសុវត្ថិភាពផ្លូវ (ដោយសារការកើនឡើងនៃការធ្វើចរាចរ និងឡានដឹកទំនិញធំៗ) និង ខ). កម្មវិធីទប់ស្កាត់នៃមេរោគ ហ៊ីវ- អេដស៍ (HIV/AIDS/STI) និងការជួញដូរលើស្ត្រី និងកុមារ ។

*គម្រោងនឹងផ្តល់ការយកចិត្តជាពិសេសទៅលើស្ត្រី និងគ្រួសារស្ត្រីដែលជាអ្នកទទួលនូវផលប្រយោជន៍នៃការធ្វើអន្តរាគមន៍ពីគម្រោង ។*

១៧. ការចូលរួមដោយស្មើភាពរបស់ស្ត្រីនៅគ្រប់វដ្តនៃសកម្មភាពនានារបស់គម្រោងគឺចាំបាច់ដើម្បីបង្កើនជីវភាពរស់នៅនៃនិរន្តរភាពគម្រោង។ ស្ត្រីនៅតាមបណ្តាភូមិជនបទមានតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍន៍ជីវភាពតាមសហគមន៍ និងសេដ្ឋកិច្ចគ្រួសារ ។ ពួកគេត្រូវបានគេផ្តល់សិទ្ធិអំណាចដើម្បីក្លាយជាសមាជិកសកម្មនៅក្នុងសកម្មភាពសហគមន៍ និងគម្រោងនានា និងកិច្ចខិតខំសម្ហូហភាពនៅក្នុងការគាំទ្រនៃការតាមដាន និងអនុវត្តគម្រោង។ តារាងទី ៦ គឺជាតារាងម៉ាទ្រិកស្តីពីផែនការសកម្មភាពយេនឌ័រ ។

## តារាងទី ៦: ម៉ាទ្រិកស្តីពីផែនការសកម្មភាពយេនឌ័រ

| ផ្នែកគម្រោង | គោលបំណង | សកម្មភាព/មុខងារ | អង្គភាពទទួលខុសត្រូវ | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|
| ១. ការរៀបចំគម្រោង | កំណត់បញ្ហាជាក់លាក់នានាពីយេនឌ័រ និងតម្រូវការដែលត្រូវយកចិត្តទុកដាក់នៅក្នុងការរៀបចំនៃការធ្វើអន្តរាគមន៍ជីវភាពរស់នៅ និងការវិនិយោគ។<br>ស្ត្រីដែលជាប់ពាក់ព័ន្ធនៅក្នុងការកំណត់នូវតម្រូវការ និងបញ្ហាទាំងនេះ។<br>អភិវឌ្ឍន៍នូវសូចនាករយេនឌ័រជាក់លាក់សម្រាប់ការផ្តល់អំណាច និងការចូលរួមរបស់ស្ត្រីត្រូវបានប្រើសម្រាប់ការតាមដាន និងវាយតម្លៃគម្រោង។ | រៀបចំព័ត៌មានជាមូលដ្ឋានដើម្បីដាក់បញ្ចូលទៅក្នុងការអង្កេត<br>រៀបចំអង្កេតសូចនាករយេនឌ័រ<br>រៀបចំកិច្ចពិភាក្សាជាក្រុមជាមួយស្ត្រីដើម្បីកំណត់នូវបញ្ហាទាក់ទងនឹងយេនឌ័រជាក់លាក់ និងបញ្ហាពាក់ព័ន្ធនឹងធាតុចូល (ទុន) ទៅក្នុងដំណើរការរៀបចំផែនការសហគមន៍ និងរៀបចំក្នុងការធ្វើអន្តរាគមន៍ការអភិវឌ្ឍន៍។<br>ជ្រើសរើស និងបណ្តុះបណ្តាលស្ត្រីដែលនឹងក្លាយជាអ្នកតាមដាននិងអ្នកលើកទឹកចិត្ត។<br>អភិវឌ្ឍន៍សូចនាករយេនឌ័រសម្រាប់ការតាមដាន និងវាយតម្លៃគម្រោង | ផ្នែកគ្រប់គ្រងគម្រោង ជាមួយការចូលរួមរបស់ក្រុមសហគមន៍ស្ត្រី (WCGs) | សូចនាករយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកនៃការអង្កេត<br>ចំនួននៃការពិភាក្សាជាក្រុមដែលបានធ្វើឡើង។<br>ចំនួនស្ត្រី និងស្ត្រីដែលជាមេគ្រួសារដែលបានចូលរួមនៅក្នុងការពិភាក្សាជាក្រុម។<br>សូចនាករស្តីពីយេនឌ័រត្រូវបានដាក់បញ្ចូទៅក្នុងវិធីសាស្ត្រតាមដាន និងវាយតម្លៃ។<br>ចំនួននៃអ្នកស្ម័គ្រចិត្តស្ត្រីនៅក្នុងសហគមន៍ដែលមានឆន្ទះបម្រើជាអ្នកតាមដាន។ | បរិក្ខារនៃការធ្វើអង្កេតការសិក្សាពីលទ្ធភាព/ផែនការអភិវឌ្ឍន៍តាមភូមិ/ការវាយតម្លៃគម្រោង។<br>រៀបចំឯកសារត្រលប់ដែលបានមកពីក្រុមស្ត្រីដែលបានទទួលផលប្រយោជន៍ និងការចូលរួមនៃការពិភាក្សា ចុះបញ្ជីឈ្មោះនៃស្ត្រីដែលស្ម័គ្រចិត្ត និងបញ្ជីឈ្មោះស្ថាប័ននានា។ |

| ផ្នែកគម្រោង | គោលបំណង | សកម្មភាព/មុខងារ | អង្គភាពទទួលខុសត្រូវ | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|
| ២. ការរៀបចំគម្រោង | ប្រាកដថាផែនការអភិវឌ្ឍន៍សហគមន៍ និងការរៀបចំវិនិយោគត្រូវបានយកចិត្តទុកដាក់លើតម្រូវការរបស់ស្ត្រី នូវសុវត្ថិភាព សន្តិសុខ ភាពឆាប់ប្រែប្រួល និងការគាំពារកុមារ ។<br>អាចប្រើប្រាស់ទឹក សុវត្ថិភាព និងល្អ ការចោលកាកសំណល់ និង<br>ការរៀបចំវិនិយោគប្រកបដោយមានការគិតគូរលើកុមារ និងមនុស្សចាស់ ។ | ផ្តល់នូវការសង្ខេប GAD និងការបង្ហាញទៅដល់សមាជិកស្ត្រីនៅក្នុងសហគមន៍ ។<br>រៀបចំសមាសធាតុ GAD នៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គដើម្បីរួមបញ្ចូលការកសាងសមត្ថភាពនៅក្នុងការយល់ដឹងនូវតំបន់សំខាន់ៗដែលពួកគេអាចចូលរួមក្នុងសកម្មភាពរៀបចំផែនការលំអិតនៃការរៀបចំការសាងសង់ ។ | ផ្នែកគ្រប់គ្រងគម្រោងសហគមន៍/ក្រុមតាមភូមិ | ការរៀបចំវិនិយោគជាមួយយេនឌ័រ និងក្រុមដែលងាយទទួលរងគ្រោះ<br>កម្មវិធីជីវភាពរស់នៅ ជាពិសេសការផ្តោតទៅលើស្ត្រីដែលជាមេគ្រួសារ | ការរៀបចំវិនិយោគ<br>ផែនការកម្មវិធីជីវភាពរស់នៅ |
| ១.ការអនុវត្តគម្រោង<br>ក. សេវាកម្មជាមូលដ្ឋាន | ប្រាកដថាស្ត្រីអាចទទួលបានផលប្រយោជន៍ពីគម្រោង ។<br>ធានាថាការកាន់កាប់លើឧបករណ៍ និងកិច្ចសន្យានានាផ្តល់ដល់ស្ត្រីលើការសម្រេចចិត្តស្មើ | ការអប់រំ និងព័ត៌មានយុទ្ធនាការផ្ទាល់ជាមួយសមាជិកសហគមន៍ ស្ត្រីដើម្បីបង្ហាញដល់ពួកគេនៃផលប្រយោជន៍របស់គម្រោង និងតម្លៃនៃការចូលរួម | ផ្នែកគ្រប់គ្រងគម្រោង អ្នកបង្ហាញហេតុផលស្ត្រី | សម្ភារៈយុទ្ធនាការនៃការអប់រំ និងព័ត៌មានត្រូវបានចែកចាយ ។<br>សម្ភារៈត្រូវបានដាក់បញ្ចូលដូចខាងក្រោម តារាងនៃការវិនិយោគដែលអាចទទួលបាន ។ វិធីសាស្ត្រ | របាយការណ៍វឌ្ឍនៈភាព<br>ឯកសារត្រលប់ពីក្រុមស្ត្រីដែលទទួលផលប្រយោជន៍ |

| ផ្នែកគម្រោង | គោលបំណង | សកម្មភាព/មុខងារ | អង្គភាពទទួលខុសត្រូវ | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|
| | ភាពគ្នា និងសិទ្ធិលើភាពជាម្ចាស់លើទ្រព្យសម្បត្តិ។<br>ពិគ្រោះយោបល់ជាប្រចាំជាមួយក្រុមស្ត្រីក្នុងកំឡុងពេលសាងសង់ សម្រាប់ការដើម្បីតាមដាន និងកែតម្រូវសកម្មភាពសាងសង់។<br>ការចាប់អារម្មណ៍របស់ស្ត្រីលើគម្រោងដោយប្រាកដនូវអ្វីដែលបានព្រមព្រៀងនៅក្នុងជំហាននៃការរៀបចំគឺត្រូវបានបង្ហាញយ៉ាងជាក់លាក់ខណៈដែលកំពុងសាងសង់ រឺជំហាននៃការអនុវត្ត | | | មីក្រូហិរញ្ញវត្ថុ (គួរដាក់ជាឥណទានខ្នាតតូច) សម្រាប់ស្ត្រីដើម្បីចាប់ផ្តើមសកម្មភាពមុខរបរចិញ្ចឹមជីវិត<br>ចំនួននៃស្ត្រីចូលរួមនៅក្នុងការធ្វើផែនការសកម្មភាពសហគមន៍ | |
| ខ.ការធ្វើអន្តរាគមន៍លើជីវភាពរស់នៅ | ធានាថាលទ្ធភាពរបស់ស្ត្រីទៅក្នុងផលប្រយោជន៍ និងសេវាកម្មនានារបស់គម្រោង។<br>បង្កើនសមត្ថភាពសន្សំប្រាក់ដល់ស្ត្រីដែលទទួលបានផលប្រយោជន៍ ជាពិសេសស្ត្រីដែល | យុទ្ធនាការនៃការអប់រំ និងព័ត៌មានបណ្តុះបណ្តាលជំនាញដល់ស្ត្រីដែលជាមេគ្រួសារ។<br>បណ្តុះបណ្តាលស្តីពីការសន្សំ និងការគ្រប់គ្រងហិរញ្ញវត្ថុ។<br>រៀបចំសហគ្រាសសមូហភាព និង | ផ្នែកគ្រប់គ្រងគម្រោង<br>អង្គការសង្គមស៊ីវិលក្នុងស្រុក និងមីក្រូហិរញ្ញវត្ថុនានា | ចំនួនស្ត្រីដែលទទួលសម្ភារៈពីយុទ្ធនាការនៃការអប់រំ និងព័ត៌មាន។<br>ចំនួនវគ្គបណ្តុះបណ្តាលដែលបានធ្វើ<br>ចំនួនអ្នកចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល | សម្ភារៈ យុទ្ធនាការនៃការអប់រំ និងព័ត៌ព័ត៌មានត្រូវបានបង្កើតឡើង និងប្រើប្រាស់ជាព័ត៌ព័ត៌មាន ការសិក្សា និងទំនាក់ទំនង<br>របាយការណ៍វឌ្ឍនភាព |

| ផ្នែកគម្រោង | គោលបំណង | សកម្មភាព/មុខងារ | អង្គភាពទទួលខុសត្រូវ | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|
| | ជាមេគ្រួសារ ។ | ក្រុមជួយខ្លួនឯងដែលគ្រប់គ្រងដោយស្ត្រី ។<br>រៀបចំសហគមន៍ដែលផ្អែកទៅលើក្រុមស្ត្រីសម្រាប់ការចិញ្ចឹមជីវិត ។ | | ចំនួនសហគ្រាស សហការណ៍ ក្រុមសន្សំប្រាក់ ក្រុមជួយគ្នាទៅវិញទៅមកដែលបានបង្កើតឡើងដោយស្ត្រី<br>ចំនួនសមាជិកស្ត្រីនៃក្រុមទាំងនេះ<br>ចំនួននៃកម្ចីមីក្រូហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុទៅដល់ស្ត្រីដែលជាមេគ្រួសារ ។<br>ចំនួននៃអ្នកបញ្ជាក់ជំនាញការងារ និងអ្នកដែលមានបទពិសោធន៍ជោគជ័យលើទីផ្សារ ។ | ទម្រង់នៃការវាយតម្លៃត្រូវបានបំពេញដោយអ្នកដែលបណ្តុះបណ្តាល<br>រយៈពេលនៃក្រុមគាំទ្រជីវភាពរស់នៅ (សហការណ៍ក្រុមជួយគ្នាទៅវិញ ទៅមក និងសហគ្រាសនានា)<br>របាយការណ៍របស់អង្គការសង្គមស៊ីវិល និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនានា ។<br>ព័ត៌មានត្រលប់ពីអ្នកទទួលផលប្រយោជន៍ជាស្ត្រីនៃប្រាក់កម្ចីសម្រាប់ជីវភាពរស់នៅ ។ |
| គ. ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍នៃស្ថាប័ន | អភិវឌ្ឍន៍សមត្ថភាពរបស់ស្ត្រីនៅក្នុងគម្រោង និងការគ្រប់គ្រងសហគមន៍ និងការតាមដានគម្រោង ។<br>ធានាថាការចូលរួមនៅក្នុងការគ្រប់គ្រងគម្រោង កម្មវិធីជីវភាពរស់នៅ និងការតាមដានគម្រោង | វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ ការគ្រប់គ្រងនៃស្ថាប័ន ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងវិនិយោគ និងការតាមដាន និងវាយតម្លៃ ។<br>ការបង្កើតនៃអង្គការរបស់ស្ត្រី និងការប្រជុំនៃអង្គការស្ត្រី ។ | ផ្នែកគ្រប់គ្រងគម្រោង<br>អ្នកដឹកនាំ/មន្ត្រីនៃក្រុមស្ត្រី និងគណៈកម្មការ ។ | ចំនួននៃវគ្គបណ្តុះបណ្តាលដែលបានធ្វើ ។<br>ឯកសារណែនាំស្តីពីការបណ្តុះ-បណ្តាល ។<br>ចំនួនអ្នកចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល ។<br>ចំនួននៃស្ត្រីនៅក្នុងក្រុម និងគណកម្មការដែលបានបង្កើត ។ | របាយការណ៍វឌ្ឍនៈភាព<br>ទម្រង់វាយតម្លៃដែលបានបំពេញដោយអ្នកចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលដែលបានធ្វើ ។<br>កំណត់ហេតុនៃកិច្ចប្រជុំ<br>បញ្ជីឈ្មោះនៃអ្នកទទួលផល និងការប្រៀបធៀបប្រាក់ចំណូល ។ |

| ផ្នែកគម្រោង | គោលបំណង | សកម្មភាព/មុខងារ | អង្គភាពទទួលខុសត្រូវ | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|
| | | | | | មុនពេលជួយ និងកម្រិតប្រាក់ចំណូលក្រោយពេលជួយ។ |
| ឃ. ការតាមដាន និងវាយតម្លៃ | ភាពពាក់ព័ន្ធរបស់ស្ត្រីនៅក្នុងការតាមដាន និងវាយតម្លៃគម្រោង វាយតម្លៃនូវផលប៉ះពាល់គម្រោងស្តីពីសុខមាលភាពស្ត្រី តាមរយៈការប្រើប្រាស់សូចនាករជាក់លាក់យេនឌ័រ | តាមដាន និងវាយតម្លៃនូវសិក្ខាសិលាជាមួយសហគមន៍<br>ការប្រមូលទិន្នន័យ និងសង្ខេបនូវរបាយការណ៍ និងឯកសារដែលទាក់ទង។ | ផ្នែកគ្រប់គ្រងគម្រោង<br>ភ្នាក់ងារតាមដានពីខាងក្រៅ | វិធីសាស្ត្រនៃការតាមដាន និងវាយតម្លៃ<br>ចំនួននៃសិក្ខាសិលាតាមដាន<br>ចំនួននៃរបាយការណ៍តាមដាន និងវាយតម្លៃ | របាយការណ៍តាមដាន និងវាយតម្លៃ វាយការណ៍ពីទទួលផលនៃគម្រោងនីមួយៗតាមរយៈការផ្តល់ក្រដាស់សរសេរតូចៗ និងភាពរីកចំរើនរបស់ពួកគេអំពីប្រាក់ចំណូល និងស្ថានភាពស្តារឡើងវិញបន្ទាប់ពីជួយដោយគម្រោង។ |

**ក១.៧: ការប៉ះប៉ូវជំងឺចិត្ត (សំណង)**

***១៨.*** នៅក្នុងប្រទេសកម្ពុជា មានការសំរេចចិត្តមួយទៅលើការបង្កើតនៃ ក្រុមការងារទទួលបន្ទុកឆ្លើយតបថ្នាក់ជាតិ (NAWG) និង គោលការណ៍ណែនាំស្តីពីការបង្កើតនៃ ក្រុមការងារទទួលបន្ទុកឆ្លើយតបថ្នាក់ខេត្ត ក្រុង(PAWG) ដែលត្រូវបានសំរេចដោយ ប្រធានគណកម្មការជាតិសំរាប់គ្រប់គ្រងវិមជការ និង ការកែទំរង់វិមជការ (NCDD ដើម្បីធានាដល់ការឆ្លើយតប តម្លាភាព ប្រសិទ្ធភាពនៃការប្រើប្រាស់នៃធនធានជំនួយទាំងអស់ ដែលស្ថិតនៅក្រោមថវិការ NCDD និង មូលនិធិ ឃុំសង្កាត់)។ PAWG អនុវត្តនូវ កិច្ចដំនើរការដោះស្រាយបណ្តឹង និង ការគាំពារ វិធានការ និង ការផ្តន្ទាទោស។

***១៩.*** គោលបំណងនៃយន្តការនេះ គឺដើម្បីធានានូវការពេញចិត្តរបស់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ជាមួយការអនុវត្ត នៃគម្រោងវាយតម្លៃ និងប្រសិទ្ធភាពសម្រាប់ការតាមដាននៅតាមមូលដ្ឋានតាមរយៈប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់នៃការអនុវត្តត្រឹមត្រូវរបស់គម្រោងវាយតម្លៃ។

***២០.*** ភាពទទួលខុសត្រូវដ៏សំខាន់សម្រាប់ដោះស្រាយភាពឈឺចាប់ គឺអ្នកប្រនាំងនៃគម្រោង ឧ. គណៈកម្មការទន្លេមេគង្គជាតិកម្ពុជា វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ទឹកសាប។ ស្ថាប័នទាំងនេះទទួលខុសត្រូវសម្រាប់ការអនុវត្តន៍គម្រោងដែលទំនងជាប្រភពនៃការឈឺចាប់ (ដូចជា ការអង្កេតវិធានការលំអិត បង្កើតតម្លៃនៃការផ្លាស់ទីលំនៅថ្មី ការកំណត់ប្រាក់ឧបត្ថម្ភផ្សេងៗទៀត) ពួកគេត្រូវបានផ្តល់ទីតាំងយ៉ាងប្រសើរដើម្បីឆ្លើយតប និងដោះស្រាយភាពឈឺចាប់ទៅតាមវិធីសាស្រ្តដែលអាចទទួលបាន និងទាន់ពេលវេលា។ ទោះជាយ៉ាងណា ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់នៅតែមិនពេញចិត្ត ពួកគេអាចលើកឡើងនូវការតវ៉ាតាមរយៈមធ្យោបាយផ្សេងៗទៀតដែលបានពណ៌នាដូចខាងក្រោម។

***២១.*** គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនឹងបង្កើតឡើងនូវគណៈកម្មការដោះស្រាយភាពប៉ះពាល់ (ទុក្ខព្រួយ) នៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ដែលរួមមានមន្ទីរពាក់ព័ន្ធ មន្ត្រីតាមមូលដ្ឋាន មេភូមិ អ្នកតំណាងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ អ្នកតំណាងស្ត្រី អង្គការនានា នឹងមានតួនាទីដូចជាមន្ត្រីដោះស្រាយផលប៉ះពាល់ដែរ។ រាល់ការតវ៉ា និងទុក្ខព្រួយនឹងត្រូវបានចងក្រងយ៉ាងល្អតាមរយៈអជ្ញាធរស្រុក និងការិយាល័យតាមភូមិ ផ្នែកគ្រប់គ្រងថ្នាក់ខេត្ត និងត្រូវបានបង្ហាញតាមរយៈនៃការពិគ្រោះយោបល់ ដោយលក្ខណៈតម្លាភាពដែលមានគោលបំណងដើម្បីដោះស្រាយបញ្ហាតាមរយៈមតិភាគច្រើន។

តារាងទី ៧ នីតិវិធីដោះស្រាយផលប៉ះពាល់(សារទុក្ខ)សំរាប់គំរោងវិនិយោគ

| នីតិវិធី | យុត្តាធិការ | ពេលវេលាឆ្លើយតប | ស្ថាប័ន/ផ្នែកឆ្លើយតប | មធ្យោបាយផ្ទៀងផ្ទាត់/ឯកសារ |
|---|---|---|---|---|
| ជំហានទី១- ថ្នាក់ភូមិ | ការតវ៉ារបស់មតិសាធារណៈ/អ្នកដែលទទួលផលប្រយោជន៍ វីប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ | រយៈពេល ៥ ថ្ងៃ | មេភូមិ និងគណៈកម្មាការភូមិ | របាយការណ៍ស្តីពីផលប៉ះពាល់(សារទុក្ខ) តាមរយៈជំនួយរបស់ផ្នែកគ្រប់គ្រងថ្នាក់ខេត្ត។ ការស្នើសុំប្រចាំត្រីមាសនៃឈ្មោះ និងព័ត៌មានពាក់ព័ន្ធអំពីការតវ៉ានានា មូលហេតុនៃការទាមទារ ថ្ងៃ ខែ នៃការតវ៉ាដែលបានប្តឹង និងដំណោះស្រាយនៃផ្នែកគ្រប់គ្រង។<br>ថ្នាក់ខេត្ត |
| ជំហានទី ១- ថ្នាក់<br>ស្រុក | ការិយាល័យអភិបាលស្រុក | រយៈពេល ១០ ថ្ងៃ | អភិបាលស្រុក/ផ្នែកគ្រប់គ្រងថ្នាក់ខេត្ត | របាយការណ៍ស្តីពីផលប៉ះពាល់(សារទុក្ខ) ពីគណកម្មការភូមិ តាមរយៈ ជំនួយពីផ្នែកគ្រប់គ្រងថ្នាក់ខេត្ត។<br>ការដាក់ស្នើសុំប្រចាំត្រីមាសនៃឈ្មោះ និងព័ត៌មានពាក់ព័ន្ធអំពីការតវ៉ានានាមូលហេតុនៃការទាមទារ ថ្ងៃ ខែនៃការតវ៉ាដែលបានប្តឹង និងដំណោះស្រាយនៃផ្នែកគ្រប់គ្រងថ្នាក់ខេត។ |
| ជំហានទី ៣- ថ្នាក់ខេត្ត | ការិយាល័យរដ្ឋាភិបាលថ្នាក់ខេត្ត | រយៈពេល ១០ ថ្ងៃ | រដ្ឋាភិបាលថ្នាក់ខេត្ត/ផ្នែកគ្រប់គ្រងគម្រោង | របាយការណ៍ស្តីពីផលប៉ះពាល់(សារទុក្ខ)ពីគណកម្មការភូមិ និងអភិបាលស្រុកតាមរយៈជំនួយពីផ្នែកគ្រប់គ្រងគម្រោង។<br>ការដាក់ស្នើសុំប្រចាំត្រីមាសនៃឈ្មោះ និងព័ត៌មានពាក់ព័ន្ធអំពី |

| | | | | |
|---|---|---|---|---|
| | | | | ការតវ៉ានានាមូលហេតុនៃការទាមទារ ថ្ងៃ ខែ នៃការតវ៉ាដែលបានប្តឹងនិងដំណោះស្រាយនៃផ្នែកគ្រប់គ្រងគម្រោង។ |

២២. ការតវ៉ាជាមធ្យោបាយចុងក្រោយនឹងត្រូវបានប្តឹងឡើងទៅតុលាការ និងអ្នកណាដែលធ្វើការសម្រេចចិត្តគួរត្រូវបញ្ចប់ ។ ទោះបីជាសេចក្តីណែនាំបច្ចេកទេសមួយចំនួនសម្រាប់ការតាំងលំនៅដ្ឋានឡើងវិញកំណត់ នោះការបង្កើតឡើងនៃការតវ៉ា ទៅដល់អង្គការនានាតាមមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលដែលមិនបម្រើផលផលប្រយោជន៍ និងអ្នកតំណាងក្នុងការតវ៉ា ដើម្បីធានានូវលទ្ធភាពនៃធនធានគ្រប់ទគាន់ដើម្បីអនុវត្តនូវនីតិវិធីនេះ។ ផ្នែកគ្រប់គ្រងគម្រោងនឹងទទួលខុសត្រូវសម្រាប់ ពាំនាំនូវការតវ៉ា និងធានាថាដំណើរការរបស់វាប្រព្រឹត្តិទៅតាមរយៈតុលាការ។

២៣. លើសពីនេះទៅទៀត យុន្តការនៃសារទុក្ខ (ផលប៉ះពាល់) ដែលបានរៀបរាប់ខាងលើ ការតវ៉ានានាអាច រឺអនុញ្ញាតតំណាង ក្នុងនាមជាអ្នកតំណាងរបស់ពួកគេលើកឡើងនូវភាពពាក់ពន្ធ័ រឺបណ្តឹងដល់ការិយាល័យបេសកកម្មតាំងលំនៅដ្ឋានរបស់ ធនាគារពិភពលោកដែលមានទីតាំងនៅប្រទេសកម្ពុជា ប្រសិនបើការតវ៉ានោះនៅតែមិនពេញចិត្តជាមួយដំណោះស្រាយនៃ បណ្តឹង របស់គេដែលដាក់នៅតាមថ្នាក់ខេត្ត និងគម្រោង។

២៤. រាល់ការចំណាយទៅលើផ្នែករដ្ឋបាលនិងឯកសារដែលបានដោះស្រាយតាមរយៈនៃការតវ៉ានិងតំណាងរបស់ពួកគេនៅតាម គណៈកម្មការដោះស្រាយផលប៉ះពាល់ត្រូវបានដោះស្រាយដោយគម្រោង។

## ក១.៨ ការតាមដាន និងវាយតម្លៃ

១. ការតាមដាននៅក្នុងគម្រោង

***២៥.*** គំរោងវិនិយោគ ត្រូវបានរៀបចំឡើងដើម្បីពាក់ពន្ធ័ទៅនឹងអ្នកទទួលផលប្រយោជន៍នៃសហគមន៍ និងអ្នកដែលទទួលរងនូវ ផលប៉ះពាល់នានានៅក្នុងការតាមដានពីស្ថានភាព និងការអនុវត្តន៏វិនិយោគ។ រាល់ការអនុវត្តន៏គម្រោង នឹងតម្រូវលើ បរិមាណ និងគុណភាពដែលត្រូវបានកំណត់។ អាជ្ញាធរភូមិ និងស្រុក រួមទាំងអ្នកទទួលផលប្រយោជន៍ពីសហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល នឹងចូលរួមគ្នាដើម្បីទទួលខុសត្រូវដល់ការតាមដាននៅក្នុងគម្រោងលើការអនុវត្តជាក់ស្តែងទៅនឹងសកម្មភាពដែលបានគ្រោង តារាងពេលវេលា ថវិកា និងការផ្តល់សិទ្ធិដែលនឹងត្រូវបានធ្វើ និងកំពុងបន្តរតាមរយៈ កំលុងពេលនៃការសាងសង់នៃវិនិយោគ។

***តារាងទី ៨*** គឺសូចនាករសម្រាប់ការតាមដាននៅក្នុងគម្រោងតាមរយៈអាជ្ញាធរភូមិ និងស្រុកដើម្បីផ្តល់នូវលទ្ធផលត្រលប់ដល់ផ្នែកគ្រប់គ្រងថ្នាក់ខេត្ត។

តារាងទី ៨: សូចនាករសម្រាប់តាមដាននៅក្នុងគម្រោង

| **ប្រភេទនៃការតាមដាន** | **មូលដ្ឋានគ្រឹះសម្រាប់សូចនាករ** | **ប្រភពនៃព័ត៌មាន** |
|---|---|---|
| ថវិកា និងកាលវិភាគ | • តើមានបុគ្គលិកនៃផ្នែកវិនិយោគគម្រោង និងមន្ត្រីគម្រោងពីអាជ្ញាធរភូមិ និងស្រុកត្រូវបានរៀបចំតែងតាំង និងផ្តល់នូវការិយាល័យដល់ពួកគេដូចដែលបានគ្រោងទុកដែរឺទេ?<br>• តើមានការបណ្តុះបណ្តាល និងកសាងសមត្ថភាពនៃមន្ត្រីផ្នែកវិនិយោគគម្រោង មន្ត្រីភូមិ និងស្រុកត្រូវបានរៀបចំទាន់ពេលវេលាដែរឺទេ?<br>• តើអាជ្ញាធរស្រុកបានផ្តល់នូវថវិកាគាំទ្រគ្រប់គ្រាន់សម្រាប់សំណងទៅដល់អ្នកទទួលផលប្រយោជន៍ និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ដែរឺទេ?<br>• តើអាជ្ញាធរស្រុកបានផ្តល់ និងចំណាយប្រាក់ស្មើភាពគ្នាសម្រាប់ការអនុវត្តគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គដែរឺទេ?<br>• តើជំហាននៃការរៀបចំសង្គមត្រូវបានអនុវត្តទៅតាមការគ្រោងទុកដែរឺទេ?<br>• តើគម្រោងវិនិយោគដែលបានស្នើ ត្រូវបានយល់ព្រមដោយអ្នកទទួលផល និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ និងបានព្រមព្រៀងដោយអាជ្ញាធរភូមិ និងស្រុកដែរឺទេ? | ផ្នែកគ្រប់គ្រងគម្រោង<br>និងអាជ្ញាធរស្រុក |
| ការផ្តល់វិនិយោគ និងសិទ្ធិ | • តើរាល់អ្នកទទួលផល និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់បានទទួលនូវសំណង និងវិនិយោគរៀងខ្លួន និងសិទ្ធិទៅតាមចំនួនរបស់ពួកគេដែរឺទេ?<br>• តើប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ទទួលនូវប្រាក់សំណងទាន់ពេលដែរឺទេ?<br>• តើជំនួយពិសេសត្រូវបានផ្តល់ទៅដល់ប្រជាជនដែលងាយរងគ្រោះដែរឺទេ?<br>• តើរាល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ទទួលព្រមនូវប្រាក់ឧបត្ថម្ភសម្រាប់អាហារ និងការធ្វើដំណើរដែរឺទេ?<br>• តើរាល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ដែលបាត់បង់នូវជីវភាពរស់នៅ រឺមុខរបរតិចតួចបានទទួលនូវប្រាក់សំណងដែរឺទេ?<br>• តើអ្នកទទួលផលទាំងអស់ត្រូវបានផ្តល់សិទ្ធិដើម្បីអនុវត្តការវិនិយោគដែរឺទេ?<br>• តើស្ត្រីត្រូវបានបណ្តុះបណ្តាលទៅតាមមុខរបរដែលពួកគេចង់បានដែរឺទេ?<br>• តើចំនួននៃស្ត្រីដែលបានបណ្តុះបណ្តាលលើមុខរបរដូចគ្នាទៅនឹងចំនួនដែលបានជាប់ពាក់ពន្ធ័ទៅនឹងសហគ្រាសធុនតូចដែរឺទេ?<br>• តើអ្នកទទួលផលត្រូវបានជាប់ពាក់ពន្ធ័នៅក្នុងសហគ្រាសធុនតូចដែលបានជួយដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុដែរឺទេ?<br>• តើចំនួនពិតប្រាកដនៃតម្លៃវិនិយោគ និងសំណងត្រូវបានបង្ហាញទៅដល់អ្នកទទួលផល និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ដែរឺទេ? | ផ្នែកគ្រប់គ្រងគម្រោង<br>និងអាជ្ញាធរស្រុក<br><br>អ្នកទទួលផលប្រយោជន៍/<br>សហគមន៍ |

| | | |
|---|---|---|
| ការពិគ្រោះយោបល់ សារទុក្ខ និងបញ្ហាសំខាន់ៗ | • តើសម្ភារៈយុទ្ធនាការអប់រំ និងព័ត៌មានត្រូវបានរៀបចំ និងចែកចាយទៅដល់អ្នកពាក់ព័ន្ធក្នុងកំលុងពេលនៃការប្រកាសឱ្យដឹងពីវិនិយោគដែរឺទេ?<br>• តើមានការពិគ្រោះយោបល់ ពិភក្សាជាក្រុមដែរ រឺទេ រឺការជួបប្រជុំជាសាធារណៈត្រូវបានធ្វើដូចដែលបានគ្រោងទុកដែរឺទេ?<br>• តើអ្នកទទួលផល និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់បានចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើផែនការ និងការអនុវត្តដែលស្របទៅតាមអ្វីដែលបានដាក់បញ្ញាតនៅក្នុងគម្រោងគ្រប់គ្រងធនធានចម្រុះទន្លេមេគង្គដែរ រឺទេ?<br>• តើមានអ្នកទទួលផល នឹងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់បានប្រើនីតិវិធីនៃការសារទុក្ខ (សំណង) ដែរឺទេ?<br>• តើមានប៉ុន្មាននាក់បានត្រូវបានសង? តើអ្វីជាលទ្ធផល?<br>• តើការរៀបចំសង្គមសម្រាប់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ត្រូវបានអនុវត្តដែរឺទេ? | អ្នកទទួលផលប្រយោជន៍/អាជ្ញាធរស្រុក/ផ្នែកគ្រប់គ្រងគម្រោង |
| **ការតាមដានទូរ ផលប្រយោជន៍** | • តើមានការផ្លាស់ប្តូរកើតឡើងនៃមុខរបររបស់អ្នកទទួលផល បើប្រៀបធៀបទៅស្ថានភាពមុនអនុវត្តគម្រោងអនុវត្ត?<br>• តើមានការផ្លាស់ប្តូរអ្វីខ្លះទាក់ទងទៅនឹងគំរូនៃប្រាក់ចំណូល និងការចំណាយបើប្រៀបធៀបទៅនឹងស្ថានភាពមុនពេលអនុវត្តគម្រោង? តើអ្វីត្រូវបានផ្លាស់ប្តូរនូវតម្លៃនៃការរស់នៅបើប្រៀបធៀបទៅនឹងស្ថានភាពមុនពេលអនុវត្តគម្រោង? តើប្រាក់ចំណូលនៃអ្នកទទួលផលរក្សាបានជាមួយការប្រែប្រួលទាំងនេះដែរឺទេ?<br>• តើអ្វីជាការផ្លាស់ប្តូរត្រូវបានអនុវត្តនៅក្នុងរបៀបនៃការរស់នៅនៃអ្នកទទួលផល? | អ្នកទទួលផលប្រយោជន៍<br>អ្នកទទួលផលប្រយោជន៍<br>អ្នកទទួលផលប្រយោជន៍ |

២. ការតាមដានពីផ្នែកខាងក្រៅ

២៩. ដែលអាចអនុវត្តបាន ផ្នែកគ្រប់គ្រងគម្រោងនឹងស្វែងរកសេវានានានៃភ្នាក់ងារតាមដានពីខាងក្រៅដើម្បីវាយតម្លៃនូវការអនុវត្តនៃការវិនិយោគរបស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនិងត្រូវបានរាយការណ៍ផ្ទាល់ទៅដល់ធនាគារពិភពលោក។ ការតាមដានពីផ្នែកខាងក្រៅនឹងត្រូវបានរៀបចំពីរដងក្នុងមួយឆ្នាំក្នុងកំលុងនៃការអនុវត្តគម្រោង M-IWRMP ដើម្បីកំណត់នូវបញ្ហានានាដែលអាចត្រូវការឆ្លើយតបភ្លាមៗពីផ្នែកគ្រប់គ្រងគម្រោងនានា និងអនុវត្តដោយរដ្ឋបាលថ្នាក់ស្រុក។ ទាក់ទងទៅនឹងនីតិវិធីដើម្បីអនុវត្ត ភ្នាក់ងារតាមដានមកពីផ្នែកខាងក្រៅ (ស្ថាប័នឯករាជ្យ)នឹងកំណត់នូវបញ្ហាពាក់ព័ន្ធ ក៏ដូចជានីតិវិធីប្រតិបត្តិនានា ដូចជាការផ្តល់នូវការគាំទ្រថវិកាឱ្យបានគ្រប់គ្រាន់។

តារាងទី ៩ បង្កើតនូវសូចនាករសំខាន់ៗដែលនឹងត្រូវបានបង្ហាញនៅក្នុងការតាមដានរបស់ភ្នាក់ងារឯករាជ្យ

| ប្រភេទសូចនករ | សូចនករ | ព័ត៌មានដែលតម្រូវក្នុងការតាមដាន និងវាយតម្លៃ |
|---|---|---|
| **ដំណើរការសូចនាករ** | បុគ្គលិក | ▪ ចំនួននៃផ្នែកវិនិយោគគម្រោង និងចំនួនបុគ្គលិកថ្នាក់ស្រុកដែលបានពាក់ពន្ធ័ដើម្បីអនុវត្តគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ។<br>▪ ចំនួននៃអ្នកជំនាញនៃការតាំងលំនៅដ្ឋានថ្មី និងអភិវឌ្ឍសង្គមដែលពាក់ពន្ធ័តាមរយៈផ្នែកគ្រប់គ្រងគម្រោង ។ |
| | ការពិគ្រោះយោបល់ ការចូលរួម និង ដំណោះស្រាយ | ▪ ចំនួននៃការពិគ្រោះយោបល់ និងកម្មវិធីចូលរួមដែលបានរៀបចំជាមួយប្រជាពលរដ្ឋ ដែលទទួលរងនូវផលប៉ះពាល់ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត ។<br>▪ ប្រភេទនៃសម្ភារៈយុទ្ធនាការអប់រំ និងព័ត៌មានដែលបានចែកចាយទៅដល់អ្នកទទួលផល និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ។<br>▪ ចំនួន និងប្រភេទនៃសំណង (សារទុក្ខ) ដែលបានទទួលពីអ្នកទទួលផល និងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ និងចំនួននៃថ្ងៃដែលបានចំណាយក្នុងការដោះស្រាយតាមរយៈគណៈកម្មការដោះស្រាយផលប៉ះពាល់ (សារទុក្ខ) ។<br>▪ ចំនួន និងឈ្មោះនៃតំណាងដែលបានចូលរួមនៅក្នុងកិច្ចពិភាក្សា និងនៅក្នុងការអនុវត្តការវិនិយោគគម្រោងគ្រប់គ្រងទន្លេធនធានទឹកចម្រុះមេគង្គ ។ |
| | នីតិវិធីប្រតិបត្តិ | ▪ ប្រភេទនៃទំរង់នានាដែលបានប្រើក្នុងការកត់ត្រាសកម្មភាពនានាដែលបានអនុវត្តនៅក្នុងគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ។<br>▪ ភាពផ្តល់ផលល្អនៃការសម្របសម្រួលជាមួយផ្នែកគ្រប់គ្រងគម្រោង អាជ្ញាធរស្រុក ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ពីគម្រោង និងស្ថាប័ន និងអ្នកពាក់ពន្ធ័ផ្សេងៗ ទៀត ។<br>▪ ប្រភេទនៃទិន្នន័យដែលបានរក្សាទុក<br>▪ ភាពផ្តល់ផលល្អនៃផ្នែកគ្រប់គ្រងគម្រោង និងមន្ត្រីរដ្ឋាភិបាលថ្នាក់ស្រុក<br>▪ ភាពផ្តល់ផលល្អនៃប្រពន្ធ័ផ្តល់សំណង<br>▪ ភាពគ្រប់គ្រាន់នៃការគាំទ្រសម្រាប់ការអនុវត្តការវិនិយោគគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ<br>▪ វាយតម្លៃប្រសិនបើគោលនយោបាលគម្រោងនៅក្នុងតំណាក់កាលរៀបចំសិក្សាត្រូវបានប្រតិបត្តិតាមត្រឹមត្រូវ ។ |
| | បញ្ហានានាដែលត្រូវបានជួបប្រទះ | ▪ បង្ហាញនូវបញ្ហានានាដែលបានជួបប្រទះក្នុងនាមជាមន្ត្រី កំលុងពេលនៃការពិគ្រោះយោបល់ និងដំណោះស្រាយផលប៉ះពាល់ (សារទុក្ខ) និងនៅក្នុងការប្រតិបត្តិនីតិវិធី ។ |

| | | |
|---|---|---|
| | ការផ្តល់សំណង និង ផ្តល់សិទ្ធិ | ▪ ចំនួននៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ដែលបានផ្តល់រង្វាន់ជាមួយផ្នែកនៃការផ្តល់លំនៅដ្ឋាន នោះប្រសិនបើមាន ។<br>▪ បង្ហាញ ប្រសិនបើប្រភេទនៃការផ្តល់សំណង គឺទាន់ពេលវេលា រឺការធ្វើម្តងបន្តិចៗ ។<br>▪ បង្ហាញនូវចំនួននៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ដែលបានជាប់ពាក់ពន្ធ័នៅក្នុងមុខរបរខ្នាតតូច ដែលត្រូវបានគេផ្តល់នូវសំណងសម្រាប់ការបាត់បង់ប្រាក់ចំណូលនៃមុខរបររបស់ពួកគេ ។<br>▪ បង្ហាញ ប្រសិនបើចំនួននៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់បានផ្តល់ជាមួយជំនួយផ្នែកធ្វើសំណើរ<br>▪ បង្ហាញ ប្រសិនបើជំនួយផ្នែកខាងម្ហូបអាហារត្រូវបានផ្តល់ទៅដល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ដែលបានផ្លាស់ទៅកាន់តំបន់បណ្តោះអាសន្ន រឺទៅកាន់គោលដៅផ្សេងៗទៀត ។<br>▪ បង្ហាញប្រសិនបើប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភ/ជំនួយសម្រាប់ការសាងសង់ឡើងវិញ និងការរុះរើរនៃលំនៅដ្ឋានរបស់ពួកគេ ក៏ដូចជាសម្រាប់ការរុះរើនៃរចនាសម្ពន្ធ័របស់ពួកគេ ។ |
| | ការស្តាបនាសង្គមឡើងវិញ | ▪ បង្ហាញនូវចំនួននៃស្ត្រីដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលជីវភាពរស់នៅ ។<br>▪ បង្ហាញនូវចំនួននៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ជាពិសេសស្ត្រី ដែលបានរៀបចំសហគ្រាសខ្នាតតូចបន្ទាប់ពីបានទទួលវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍ជីវភាពរស់នៅមក ។<br>▪ បង្ហាញប្រសិនបើប្រជាពលរដ្ឋដែលប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់បានទទួលនូវទឹកស្អាតសម្រាប់ ហូបដោយសុវត្ថិភាព ។ |
| | បញ្ហានានាដែលត្រូវបានជួបប្រទះ | ▪ បង្ហាញនូវបញ្ហានានាដែលបានជួបប្រទះនៅក្នុងការអនុវត្តនៃវិនិយោគ/ការចំណាយលើសំណង និងការផ្តល់សិទ្ធិ និងការស្តារឡើងវិញនូវសង្គមរបស់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ។ |
| **សូចនាករនៃភាពប៉ះពាល់** | សមត្ថភាពសន្សំប្រាក់តាមគ្រួសារ | ▪ បង្ហាញនូវប្រាក់ចំណូល ដូចដែលបានប្រៀបធៀបទៅនឹងកម្រិតប្រាក់ចំណូលមុនគម្រោងអនុវត្ត ។<br>▪ ផ្តល់ការងារដល់សមាជិកគ្រួសារទទួលផលលំនៅដ្ឋាននៅក្នុងការសាងសង់វិនិយោគ ។<br>▪ ភាពផ្លាស់ប្តូរប្រាក់ចំណូលនៃសហគ្រាសធន់តូចទាំងនោះ ។ |
| | បរិស្ថាន និង សុខភាព | ▪ បញ្ហានានាស្តីពីការគ្រប់គ្រងកាកសំណល់ ។<br>▪ ទឹកសម្រាប់ហូប-ប្រើប្រាស់ដែលមានសុវត្ថិភាពត្រូវបានបង្កើន ។<br>▪ ការបង្កើនលក្ខខណ្ឌសុខមាភាពរបស់កុមារ និងស្ត្រី ។ |
| | គំរូនៃការប្រែប្រួលសេដ្ឋកិច្ចសង្គម | ▪ មានស្ត្រីច្រើនចូលរួមនៅក្នុងសហគ្រាសធន់តូច ។<br>▪ ឆ្ពោះទៅរកបច្ចេកវិទ្យាថ្មីៗដែលនាំឱ្យមានការតភ្ជាប់នូវចរន្តអគ្គីសនី ។ |

## ក១.៩ គោលនយោបាយរបស់ធនាគារពិភពលោកសម្រាប់ការពិគ្រោះយោបល់ និងផ្សព្វផ្សាយ

៣០. ការព្រឹក្សាសាធារណៈ និង ការផ្សព្វផ្សាយពតិមាន(OP 17.50)កំណត់នូវតំរូវការរបស់ធនាគារពិភពលោកសំរាប់ប្រើប្រាស់ជាសាធារណៈចំពោះឯកសារ និង ពតិមានរបស់គំរោង។គោលនយោបាយធនាគារពិភពលោកតម្រូវថានៅក្នុងកំលុងពេលនៃដំណើរការធ្វើផែនការ និងការរៀបចំ អ្នកទទួល ផលពីគម្រោង និងក្រុមដែលទទួលរងនូវផលប៉ះពាល់ និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនឹងត្រូវបានពិគ្រោះយោបល់ និង ធ្វើបទបង្ហាញពីទិដ្ឋភាពសង្គម និងបរិស្ថាននៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ។ កិច្ចពិគ្រោះយោបល់នឹងត្រូវ បានពិគ្រោះយោបល់ស្តីពីដំណើរការកំពុងអនុវត្តដោយទូទៅនូវការអនុវត្ត និងការរៀបចំនៃការវិនិយោគ និងត្រូវតែជា បណ្តឹងជាមួយគោលនយោបាយសុវត្ថិភាពដែលត្រូវបានអនុវត្ត។លើសពីនេះ ធនាគារតម្រូវថាគម្រោងត្រូវធ្វើតាមទៅលើការពិគ្រោះយោបល់ជាសាធារណៈ និងគោលនយោបាយផ្សព្វផ្សាយព័តិមាន (OP 17.50). គោលនយោបាយតម្រូវរដ្ឋាភិបាល រឺអ្នកខ្ចីជំនួយដើម្បីធ្វើឱ្យងាយទទួលបានទាន់ពេលវេលា មានសម្ភារៈ និងឧបករណ៍គ្រប់គ្រាន់ដូចជា ការសិក្សានូវការវាយតម្លៃបរិស្ថានសង្គម ការវាយតម្លៃគម្រោង ផែនការអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច ក្នុងទម្រង់ដែលអាចយល់ដឹងបានពីភាសាសម្រាប់ក្រុមជនជាតិដើមភាគតិចដែលបានពិគ្រោះយោបល់។

## <u>និយមន័យនៃពាក្យមួយចំនួន</u>

**អ្នកទទួលផល**- រាល់បុគ្គល និងគ្រួសារមកពីតាមបណ្តាភូមិ ដែលស្វែងរកដោយស្មគ្រ័ចិត្តដើម្បីឱ្យប្រយោជន៍នៃ រឺជាផ្នែកនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ

**ការផ្តល់សំណង**- ការចំណាយជាសាច់ប្រាក់ រឺប្រភេទនៃការចំណាយលើការផ្លាស់លំនៅដ្ឋាននៃទ្រព្យសម្បត្តិដែលបានតម្រូវ

**ពេលវេលា**- ពេលវេលាដែលធ្វើការសម្រេចចិត្តស្តីពីអ្នកទទួលផលដែលផ្តោតលើ និងការទទួលដីធ្លីនៃតំបន់នានារបស់គម្រោងដែលត្រូវបានចេញឱ្យដោយអាជ្ញាធរដែលមានសមត្ថកិច្ច និងដែលបានប្រកាសជាសាធារណៈទៅដល់សហគមន៍ដែលផ្តោតលើមួយចំនួន និងទៅដល់ប្រជាពលរដ្ឋដែលប៉ះពាល់ រឺផ្លាស់ទីលំនៅដ្ឋាន។

**ការផ្តល់សិទ្ធិ**- លំដាប់នៃវិធានការនានារួមមាន ការផ្តល់សំណង ការជួសជួសប្រាក់ចំណូល ជំនួយការក្នុងការផ្លាស់ប្តូរ ប្រាក់ចំណូលនៃការតាំងលំនៅដ្ឋានឡើងវិញ និងការយកមកជំនួសដល់ប្រជាពលរដ្ឋដែលទទួលរងនូវប៉ះពាល់ដែលពឹងទៅលើធម្មជាតិដែលពួកគេបាត់បង់ ដើម្បីស្តារឡើងវិញនូវផ្នែកសង្គម និងសេដ្ឋកិច្ចរបស់ពួកគេ។

**គ្រួសារ**- មានន័យថារាល់មនុស្សដែលកំពុងរស់នៅ និងហូបចុករួមគ្នាដែលជាផ្នែកនៃសង្គមតែមួយ។ ការជំរឿនដែលបានប្រើប្រាស់នូវនិយមន័យនេះ និងព័តិមានដែលបានធ្វើឡើងតាមរយៈជំរឿនបង្កើតនូវមូលដ្ឋានសម្រាប់ការកំណត់នូវគ្រួសារ។

**ការជួសជុលប្រាក់ចំណូលឡើងវិញ**- មានន័យថា បង្កើតនូវប្រភពប្រាក់ចំណូលឡើងវិញ និងជីវភាពរស់នៅនៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ទៅក្នុងកម្រិតនៃមុនពេលគម្រោងរបស់ពួកគេ។

**ការលើកកម្ពស់**- រចនាសម្ព័ន្ធដែលបានសាងសង់ (ការរស់នៅ របង រោងតូចៗ ទ្រុងជ្រូក សារៈប្រយោជន៍នានាមធ្យោបាយនានា សហគមន៍ តូប ឃ្លាំងអីវ៉ាន់.....។ល។) និងធញ្ញជាតិ ដើមឈើដែលបានដាំដោយប្រជាពលរដ្ឋ គ្រួសារ រឺអង្គភាព (ក្រុម)។

**ការផ្តល់នូវដី**- ជាដំណើរការដែលបុគ្គលម្នាក់ដែលត្រូវបានបង្គាប់-ផ្តល់ដោយភ្នាក់ងាររដ្ឋាភិបាលដើម្បីផ្ទេរសិទ្ធិទាំងអស់ រឺផ្នែកខ្លះៗនៃដីដែលបុគ្គលនោះកាន់កាប់ដើម្បីធ្វើជាម្ចាស់
និងកាន់កាប់នៃភ្នាក់ងាររដ្ឋាភិបាលសម្រាប់គោលបំណងសាធារណៈ ដើម្បីផ្លាស់ប្តូរសម្រាប់ធ្វើការពិចារណា។

**ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ដោយគម្រោង**- រួមមានទាំងប្រជាពលរដ្ឋទាំងឡាយណា រឺអង្គភាព រឺអង្គការដែលបានទទួលផលប៉ះពាល់ដោយគម្រោង អ្នកដែលស្ថិតនៅក្រោមករណីនៃអ្នកដែលមិនស្ម័គ្រចិត្តទទួលយកនៃទ្រព្យ-សម្បត្តិនៅក្នុងការគាំទ្រលើការអនុវត្តនៃគម្រោងអ្នកទាំងនោះគួរមាន (១). កម្រិតនៃការរស់នៅដែលបានទទួលផលប៉ះពាល់អាក្រក់ (២). សិទ្ធិ សិទ្ធិទទួល រឺ រាល់ផលប្រយោជន៍ រឺផ្នែកផ្សេងៗទៀតនៃផ្ទះ និងសំណង់នានា ដី (រួមទាំងដីតាំងលំនៅដ្ឋាន ជំនួញ កសិកម្ម ចំការធំៗ ព្រៃឈើ និងដីវាលស្មៅ)ធនធានទឹក ស្រះត្រី ដែននេសាទតាមឃុំ ឈើហូបផ្លែ និងដំណាំដែលមានរយៈពេលតាមរដូវ រឺរយពេលយូរ រឺទ្រព្យសម្បត្តិ ដែលអាចផ្លាស់ប្តូរបាន រឺមិនអាចផ្លាស់ប្តូរបានដែលត្រូវបានតម្រូវ រឺកាន់កាប់ទាំងស្រុង រឺដោយផ្នែកខ្លះៗ ដោយអចិន្ត្រៃ រឺបណ្តោះអាសន្ន និង (៣). មុខរបរ វិជ្ជាជីវៈ ការងារ រឺប្រភពនៃប្រាក់ចំណូល និងជីវភាពរស់នៅដែលបាត់បង់ទាំងស្រុង រឺផ្នែកខ្លះៗ ដោយអចិន្ត្រៃ រឺបណ្តោះអាសន្ន។

**តម្លៃនៃការផ្លាស់ប្តូរ**- គឺជាពាក្យដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់នូវចំនួនគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរនូវទ្រព្យសម្បត្តិដែលបាត់បង់នានា និងដែលរួមបញ្ចូលទាំងតម្លៃស្រុះស្រួល។ នៅពេលដែលច្បាប់នៅតាមមូលដ្ឋានមិនបំពេញនូវស្តង់ដានៃការផ្តល់សំណងពេញលេញនៃតម្លៃនៃការផ្លាស់ប្តូរ សំណងស្ថិតនៅក្រោមច្បាប់នៅតាមមូលដ្ឋានគឺត្រូវបានបន្ថែមតាមរយៈភាពចាំបាច់នៃនីតិវិធី ដើម្បីឱ្យស្របទៅ តាមកម្រិតស្តង់ដាតម្លៃ។

**ការតាំងលំនៅដ្ឋានឡើងវិញ**- គឺជាពាក្យទូទៅដែលទាក់ទងទៅនឹងការផ្តល់ដី និងសំណងសម្រាប់ការបាត់បង់នៃទ្រព្យសម្បត្តិ ទោះបីជាពាក់ពន្ធ័ជាមួយការតាំងលំនៅថ្មីជាក់ស្តែង ការបាត់បង់ដី ជម្រក ទ្រព្យសម្បត្តិ រឺជីវភាពរស់នៅ។

**ក្រុមដែលងាយទទួលរងនូវផលប៉ះពាល់**- គឺជាក្រុមដែលផ្សេងៗនៃមនុស្សដែលអាចទទួលនូវភាពឈឺចាប់ដោយមិនស្មើភាព រឺប្រឈមទៅនឹងភាពគ្រោះថ្នាក់នៃការគម្រាមកំហែងនាពេលខាងមុខដោយ សារផលប៉ះពាល់នៃការតាំងលំនៅដ្ឋានឡើងវិញ និងជាពិសេសផលប៉ះពាល់ទាំងនោះរួមមានៈ (១). គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មនុស្សចាស់ រឺពិការ (២). គ្រួសារដែលរស់នៅស្ថិនៅក្រោមភាព ក្រីក្រខ្លាំង (៣). គ្រួសារដែលគ្មានដី និងទី (៤). ក្រុមជនជាតិដើមភាគតិច។

## ឧបសម្ព័ន្ធទី ១- ទម្រង់បញ្ជីនៃការតាំងលំនៅដ្ឋានឡើងវិញដោយមិនស្ម័គ្រចិត្តរបស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ

**គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (M-IWRMP)**

**តារាងបញ្ជី**

## ឧបសម្ព័ន្ធទី ២: បែបបទនៃបញ្ជីគាំពារសង្គម

**សកម្មភាពដែលស្នើ:** ………………………………………………………………………….

**សេចក្តីលំអិត** :…………………………………………………………………………………….

……………………………………………………………………………………………………..

**ទីតាំង** :……………………………………………………………………………………..

**បំពេញដោយ** :……………………………………………………………………………………..

**ស្ថាប័ន** :……………………………………………………………………………………….

**ថ្ងៃ ខែ ឆ្នាំ** :……………………………………………………………………………………….

**ឯកសារភ្ជាប់** :…………………………………………………………………………………….

**បានរៀបចំជាមួយស្ថាប័នដៃគូរដូចខាងក្រោម/ តំណាងសហគមន៍:**

**កំណត់សំគាល់:**

**របៀបទូទៅក្នុងការអនុវត្ត:**

- *តារាងបញ្ជីនេះគឺត្រូវបានបំពេញដើម្បីផ្ទៀងផ្ទាត់នៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គដែលបានគាំទ្រថវិកាទៅលើសកម្មភាព ។ វាត្រូវបានភ្ជាប់ជាមួយកិច្ចព្រមព្រៀងថវិកាជំនួយជាមួយសាម៉ីរដ្ឋាភិបាល រឺដោយសហគមន៍នានា ។*
- *តារាងបញ្ជីនេះផ្តោតទៅលើបញ្ហាសង្គមនានា និងភាពទាក់ទងនានា ដើម្បីធានាថាភាពសំខាន់សៃង្គមនានាត្រូវបានយកចិត្តទុកដាក់គ្រប់គ្រាន់នៅក្នុងការវាយតម្លៃអនុថវិកាជំនួយ ។*
- *គោលបំណងគឺដើម្បីកំណត់ភាពដែលអាចធ្វើបានរបស់វា និងផលប៉ះពាល់សង្គមនានានៃថវិកាជំនួយដែលបានគាំទ្រសកម្មភាពនានា ។ ប្រសិនបើជាអាចអនុវត្តបាន សូមប្រើផ្នែក " កំណត់សំគាល់ " ដើម្បីពិភាក្សាលើទីតាំងវិធីសម្រាលនានាដែលបានស្នើ ។*

- *ព័ត៌មានគួរត្រូវបានប្រមូលនៅក្នុងការសម្របសម្រួល និងពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកដឹកនាំសហគមន៍ដែលបានទទួលរងនូវផលប៉ះពាល់ ។*

| សំណួរ | ទេ | បាទ/ចាស | តើទីតាំវិធីសម្រាលត្រូវបានតម្រូវ? |
|---|---|---|---|
| **ក. ទីតាំងគម្រោង** | | | |
| តើមានដូចខាងក្រោម<br>រចនាសម្ព័ន្ធ រឺធនធាននានានៅក្នុងតំបន់សាងសង់អនុគម្រោង? | | | |
| • គ្រួសារឯកជន | ☐ | ☐ | |
| • តូប/មុខរបរតូចៗ | ☐ | ☐ | |
| • ផ្លូវលំតូចៗ ផ្លូវថ្មើជើងតូចៗ រឺផ្លូវផ្សេងៗទៀត | ☐ | ☐ | |
| • ដីកសិកម្ម | ☐ | ☐ | |
| • ធនធានធម្មជាតិត្រូវបានប្រើរួមគ្នាដោយសមាជិកសហគមន៍ | ☐ | ☐ | |
| • ផ្នូរសាកសព រឺកន្លែងផ្សេងៗទៀត/រចនាសម្ពន្ធ័សាសនារឺវប្បធមិសំខាន់ៗ | ☐ | ☐ | |
| • ផ្សេងៗទៀត | ☐ | ☐ | |
| ការស្នើ/កំណត់សំគាល់បន្ថែម: | | | |
| **ខ. សក្តានុពលផលប៉ះពាល់សង្គម**<br>នឹងបណ្តាលមកពីអនុគម្រោង: | | | |
| • តើមានការបាត់បង់បណ្តោះអាសន្ននៃដី រឺធនធាននានាសម្រាប់គ្រួសារនានាដែររឺទេ? | ☐ | ☐ | |
| • តើមានការបាត់បង់អចិន្ត្រៃនៃដី រឺធនធានសម្រាប់គ្រួសារនានាដែររឺទេ? | ☐ | ☐ | |
| • តើមានទំនាស់នានានៅក្នុងសិទ្ធិផ្គត់ផ្គង់ទឹក និងទំនាស់នានាទាក់ទងទៅ នឹងសង្គមដែររឺទេ? | ☐ | ☐ | |
| • តើមានឧបសគ្គនានាក្នុងការធ្វើចរាចររបស់មនុស្ស និងសត្វដែររឺទេ? | ☐ | ☐ | |
| • តើមានការផ្លាស់ទី រឺការតាំងលំនៅដ្ឋានឡើងវិញដោយមិនយល់ព្រមដែររឺទេ? | ☐ | ☐ | |
| • តើមានសក្តានុពលជំលោះសង្គមកើតឡើងពីការកាន់កាប់ដី និងបញ្ហានានានៃប្រើប្រាស់ដីដែររឺទេ? | ☐ | ☐ | |
| • តើមានការធ្វើឱ្យអន់ថយឡើងនៃជីវភាពរស់នៅ រឺលក្ខខណ្ឌរស់នៅនៃ ស្ត្រី រឺគ្រួសារដែក្រីក្របំផុតនៅក្នុងតំបន់សេវាអនុគម្រោងដែររឺទេ? | ☐ | ☐ | |

| **សំណួរ** | **ទេ** | **បាទ/ចាស** | **តើនីតិវិធីសម្រាលត្រូវបានតម្រូវ?** |
|---|---|---|---|
| • ផ្សេងៗទៀត: ........................................... | ☐ | ☐ | |

**គ. កំណត់សំគាល់ផ្សេងៗទៀត:**

**ឃ. ផ្នែកនៃការតាំងលំនៅដ្ឋានឡើងវិញដោយមិនស្ម័គ្រចិត្ត:**

បន្ទាប់ពីសង្ខេបនូវសំណួរដែលឆ្លើយតបខាងលើ ទីប្រឹក្សាផ្នែកគ្រប់គ្រងគម្រោងនានាយល់ព្រមដើម្បីបញ្ជាក់បន្ថែម ដែលគម្រោងគឺថា:

‘ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់គឺមិនត្រូវបានផ្លាស់ទីតាំងជារូបសាស្ត្រ និងដែលតិចជាង ១០ ភាគរយនៃទ្រព្យសម្បត្តិដែលត្រូវបានបាត់បង់’ ផែនការសកម្មភាពនៃការតាំងលំនៅដ្ឋាលឡើងវិញដែលបានបំពេញគឺត្រូវបានតម្រូវ។

ការវិនិយោគដែលបានស្នើអាចមានលទ្ធផលដែលមានផលប៉ះពាល់យ៉ាងសំខាន់ច្រើន ឧ. ការផ្លាស់ទីតាំងនៃប្រជាពលរដ្ឋ និងតិចជា ១០ ភាគរយនៃទ្រព្យសម្បត្តិរបស់ពួកគេដែលត្រូវបានបាត់បង់ និងបន្ទាប់មកការវាយតម្លៃគម្រោងនឹងត្រូវបានរៀបចំ។

គ្មានការផ្លាស់ទីតាំងដែលបានស្មានទុកជាមុន និងការបាត់បង់នៃទ្រព្យសម្បត្តិគឺត្រូវបានទាត់ចោល

**ង. សក្តានុពលនៃផលប៉ះពាល់សង្គមទៅលើក្រុមដែលងាយរងគ្រោះ-ប្រសិនជាមាន:**

បណ្តាលមកពីអនុគម្រោង:

| | | | |
|---|---|---|---|
| • តើប៉ះពាល់ទៅដល់ក្រុមគ្រួសារក្រីក្រដែរឺទេ? | ☐ | ☐ | |
| • តើមានផលប៉ះពាល់ទៅដល់គ្រួសារដែលមានស្ត្រីជាមេដែរឺទេ? | ☐ | ☐ | |
| • តើមានផលប៉ះពាល់ទៅលើជនជាតិដើមភាគតិចដែរឺទេ? | ☐ | ☐ | |
| • តើមានផលប៉ះពាល់ទៅលើក្រុមដែលងាយរងគ្រោះដែរឺទេ? | ☐ | ☐ | |

**ច. កំណត់សំគាល់ផ្សេងៗទៀត:**

**ឯកសារសុវត្ថិភាពដែលបានតម្រូវ:**

| | | | |
|---|---|---|---|
| • តើមានផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានឡើងវិញដែរឺទេ? | ☐ | ☐ | |

| សំណួរ | ទេ | បាទ/ចាស | តើនីតិវិធីសម្រាលត្រូវបានតម្រូវ? |
|---|---|---|---|
| • តើមានផែនការអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិចដែររឺទេ? | ☐ | ☐ | |
| • តើមានកម្មសិទ្ធិដីរឺឯកសារដែររឺទេ? | ☐ | ☐ | |
| • តើមានការប្រកាសសហគមន៍ដែររឺទេ? | ☐ | ☐ | |
| • តើមានអ្វីផ្សេងៗទៀតដែររឺទេ? ……………………………………… | ☐ | ☐ | |

**ឆ. កំណត់សំគាល់ផ្សេងៗទៀតៈ**

**ជ. សេចក្តីសន្និដ្ឋាន/និងអនុសាសន៍**

## ឈ. ហត្ថលេខាៈ

**ភ្នាក់ងារអនុវត្តសកម្មភាពៈ**

**ឈ្មោះ ……………………………..………..**

**តួនាទីៈ………………………………………..**

**ថ្ងៃ ខែ ឆ្នាំៈ……………………………..………..**

**អ្នកសម្របសម្រួលសុវត្ថិភាពគម្រោង M-IWRMP**

**ឈ្មោះៈ……………………………..**

**តួនាទីៈ………..……………………**

ថ្ងៃ ខែ ឆ្នាំៈ **…………………………**

## ឧបសម្ព័ន្ធទី ៣: តារាងសង្ខេបព័ត៌មានស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងដីដែលបានទទួលផលប៉ះពាល់

ការអង្កេតវិធានការលំអិត (DMS)

ខេត្ត: ____________ ស្រុក: __________________ ភូមិ/ឃុំ: ________________________

| | | | | | | ការបាត់បង់ទ្រព្យសម្បត្តិ | | | ការបាត់បង់ផលដំណាំ | | | ការបាត់បង់ នៃទ្រព្យសម្បត្តិ ផ្សេងៗទៀត | ការបាត់បង់ផ្សេងៗទៀត | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួន គ្រួសារ | ឈ្មោះមេ គ្រួសារ | ចំនួនសមាជិក នៅក្នុងគ្រួសារ | ចំនួនដីសរុប តាមគ្រួសារ (m2) | ដីដែលត្រូវ បានទទួល (m2) | ដីដែល បាត់បង់ (%) | រចនាសម្ព័ន្ធ អចិន្ត្រៃយ៍ (m2) | រចនាសម្ព័ន្ធ បណ្តោះអាសន្ន (m2) | ទីតាំងនៃ ការបាត់បង់ដី លំនៅដ្ឋាន (m2) | ដើមឈើហូប ផ្លែ (ប្រភេទ និងចំនួន) | ទីតាំងនៃការ បាត់បង់ដើមឈើ រឺដំណាំ (m2) | ផ្សេងៗ ទៀត (បញ្ជាក់) | ឧ. កន្លែងកប់ សាកសព.. ។ល។ (ប្រភេទ និងចំនួន) | ដីតាំលលំនៅ (ជួល) | ការបាត់បង់ មុខរបរ | ការបាត់បង់ ប្រាក់ចំណូល |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

**ឧបសម្ព័ន្ធ ៤- មាតិកានៃ RAP**

- ការពណ៌នា និង ទីតាំងរបស់គំរោង
- ការរើទីតាំងទ្រង់ទ្រាយធំព្រោះតែគំរោងរងដែលបានស្នើ
- គំរោងស្របច្បាប់
- ការស្រង់ស្ថិតិប្រជាជន និង ការស្ទាបស្ទង់លើសេដ្ឋកិច្ចសង្គម សំរាប់គ្រួសារ ទ្រព្យសម្បត្តិ និង មុខជំនួញ ដែលរងផលប៉ះពាល់
- ផលប៉ះពាល់ដែលបណ្តាលមកពីការរើទីលំនៅ
- ជំនួយដែលបានស្នើសំរាប់ប្រជាជន និង ក្រុមគ្រួសារដែលរងផលប៉ះពាល់
- អង្គការ និង ស្ថាប័នដៃគូដែលទទួលបន្ទុក
- ធនធាននៃមូលនិធិ និង ការប៉ាន់ស្មានទៅលើការចំណាយ
- ពេលវេលាសំរាប់ការរើលំនៅស្ថានឡើងវិញ
- ការត្រួតពិនិត្យតាមដាន និង ការវាយតំលៃ

**ឧបសម្ពន្ធ័ទី៥- គំរោងសំរាប់ផែនការការងាររើលំនៅស្ថានឡើងវិញ**

**១. សេចក្តីផ្តើម**

- ការពិពណ៌នាទៅលើសមាសភាពរបស់គំរោង
- ការពណ៌នាសង្ខេបសំរាប់ផលប៉ះពាល់ធ្ងន់ធ្ងរ និង ការកាន់កាប់ដីធ្លី
  - អត្តសញ្ញាណនៃអ្នកដែលពាក់ពន្ធ័សំខាន់ៗ រួមមានក្រុមសង្គមដែលងាយរងគ្រោះ រហូតដល់ជនក្រីក្រ រឺក៏ជនអត់ឃ្លាន
  - វិធានការដែលត្រូវបានចាត់ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ធ្ងន់ធ្ងរ

**២. ការស្រង់ស្ថិតិប្រជាជន និង លទ្ធផលនៃការស្ទាប់ស្ទង់លើសេដ្ឋកិច្ចសង្គម**

- ត្រួតពិនិត្យមើលលក្ខណៈរបស់សេដ្ឋកិច្ចសង្គម សំរាប់ប្រជាជនដែលងាយរងគ្រោះពីគំរោង(PAPs) រួមមានការបរិច្ឆាគតាមទំហំ ទំហំផ្ទះសំបែង និង សំណង, រចនាសម្ពន្ធ័ភេទ-អាយុ, កំរិតចំនូល, រួមបញ្ចូលនឹង ការងារបឋម ប្រភព បន្ថែមសំរាប់ប្រាក់ចំនួល និង ការងារចិញ្ចឹមជីវិត សិទ្ធិកាន់កាប់(ដីធ្លី និង សំណង់ផ្សេងៗ),លក្ខណៈនៃការកាន់កាប់ដីធ្លីរួម រួមមានតំបន់ និង លក្ខណៈស្តង់ដារ លក្ខណៈនៃសំណង់ រួមានប្រភេទសំណង់ផ្សេងៗ។
- ពតិមានគួរត្រូវបានផ្តល់ដោយមិនមានការរើសអើងសំរាប់ក្រុមជនជាតិ និង ភេទ
- ក្រុម និង ចំនួននៃ PAPs តាមប្រភេត និង កំរិតនៃផលប៉ះពាល់ដូចជា:

  ក. ផ្ទះសំបែងដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារតែការបាត់បង់ ទ្រព្យសម្បត្តិបង្កបង្កើតផលនិង ការរើចេញ

  ខ. ផ្ទះសំបែងដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារតែការបាត់បង់លំនៅស្ថាន និង មុខរបរ

  គ. ផ្ទះសំបែងដែលរងផលប៉ះពាល់ដែលទំនងនឹងត្រូវបានត៏រឹម ដោយសារតែការបាត់បង់ដី ផ្ទះ រឺក៏មុខរបរតែមិនត្រូវការរើចេញឡើយ

  ឃ. ផ្ទះសំបែងដែលរងផលប៉ះពាល់បន្តិចបន្តួច ដែលទទួលនូវសំណងសមរម្យ រឺក៏ជំនួយក្នុងការរើចេញ

  ង. អ្នកដែលជួលដី កម្មករ បុគ្គលិក រឺក៏ប្រជាជនដែលមិនមានដីធ្លីដែលរងផលប៉ះពាល់ដោយគំរោង

**៣. លក្ខខណ្ឌ័វិនច្ឆ័យនៃការផ្តល់សិទ្ធិសំរាប់សំណង**

- ការពណ៌នាពីគោលបំណងនៃគោលនយោបាយសំណង
- លក្ខខណ្ឌ័នៃសិទ្ធិទទួលបានសំរាប់ PAPs ដោយរួមបញ្ចូលនូវ "កាលបរិច្ឆេទដាក់លាក់" ប្រសិនបើចាំបាច់
- ការពណ៌នាពីការផ្តល់សិទ្ធិសំរាប់សំណង និង បែបបទនៃជំនួយដទៃទៀតសំរាប់ក្រុមនៃ PAPs នីមួយៗ

- ការពណ៌នាពីវិធានការដាក់លាក់ដើម្បីជួយសំរាលនូវផលប៉ះពាល់ធ្ងន់ធ្ងរទៅលើក្រុមដែលងាយរងគ្រោះ (ប្រសិនបើពាក់ពន្ធ័)
- ម៉ាទ្រិកនៃការផ្តល់សិទ្ធិ

## ៤. ផែនការការងាររើលំនៅស្ថានឡើងវិញ (ប្រសិនបើសំខាន់)

- ការត្រួតពិនិត្យឡើញវិញសំរាប់ភាពសមរម្យនៃតំបន់ដែលត្រូវរើទៅ
- លក្ខខណ្ឌវិនិច្ឆ័យនៃការជ្រើសរើសតំបន់
- ការត្រួតពិនិត្យឡើងវិញនៃការការពារ និង គ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់ដែលត្រូវតាំងទីជំរកជាថ្មី
- ជំរើសនៃការតាំងលំនៅជាថ្មីជាជំហានដំបូងសំរាប់ PAPs
- ការត្រួតពិនិត្យឡើងវិញនៃជំរើសសំរាប់វត្ថុបំរុងទុកនៃជំរក ហេដ្ឋារចនាសម្ពន្ធ័ និង សេវាសង្គម
- ការត្រួតពិនិត្យឡើងវិញនៃនិតិវិធីព្រឹក្សាជាមួយនឹង PAPs នៅក្នុងការជ្រើសរើសនៃការតាំងទីលំនៅជាថ្មី កំឡុងពេលនៃការអនុវត្តន៏។
- ទិន្នន័យសេដ្ឋកិច្ចសង្គមដែលប្រមូលពីចំនួនប្រជាជនដ៏ច្រើន ប្រសិនបើអនុវត្ត

## ៥. វិធានការស្តារឡើងវិញនូវប្រាក់ចំណូល (ចាំបាច់)

- ការពិពណ៌នាពីលក្ខខណ្ឌនៃសិទ្ធិទទួលបាន សំរាប់វិធានការស្តារប្រាក់ចំណូលឡើងវិញ
- ការវិភាគនៃភាពងាយស្រួលសំរាប់កម្មវិធីស្តារប្រាក់ចំណូលឡើងវិញដែលរួមមានការប្រើប្រាស់សំរាប់ សំណងដីធ្លី តំរូវការខាងផ្នែកបណ្តុះបណ្តាលសំរាប់ PAPs នៅក្នុងបរិបទនៃឱកាសការងារ និង តំរូវការទីផ្សារ លទ្ធភាពទទួលបានប្រាក់ចំណូល និង ការឧបត្ថម្ភពី សហគ្រាសខ្នាតតូវ សំរាប់ PAPs ដែលចាប់អារម្មណ៏ទៅលើការអភិវឌ្ឍន៍មុខជំនួញខ្នាតតូច។
- ការរៀបចំតាមស្ថាប័ន ដើម្បីផ្តល់ជាថវិការ និង គ្រប់គ្រងកម្មវិធីស្តារប្រាក់ចំណូលឡើងវិញ

## ៦. ការចូលរួម ការព្រឹក្សា ការផ្សព្វផ្សាយ និង យន្តការដោះស្រាយជំងឺចិត្តជាសាធារណ:

- ការអនុវត្តន៏ព្រឹក្សាជាសាធារណ: ដែលបានអនុវត្តក្នុងកំឡុងពេលនៃការរៀបចំនៃRAP (ផ្តល់ពតិមានលំអិត) រួមមាន ការព្រឹក្សាដ៏ច្បាស់លាស់ពីយែនឌ័រ និង ការផ្សព្វផ្សាយពតិមាន។ វានឹងរួមបញ្ចូលនូវ ចំណាប់អារម្មណ៏ពិសេសដើម្បីធានាលើ ទ្រព្យសម្បត្តិ កម្មសិទ្ធិ និង សិទ្ធិប្រើប្រាស់ដីធ្លីរបស់ស្ត្រី និង ដើម្បីធានាដល់ការស្តារនៃប្រាក់ចំណូល និង គំរិតជីវភាព របស់ពួកគេ

- ការពណ៌នាពីឱកាសសំរាប់ PAPs ដើម្បីរួមចំនែកនៅក្នុង ការរៀបចំផែនការ និង ការអនុវត្តន៏លើការតាំងលំនៅស្ថានឡើងវិញ
- និតិវិធីដែលត្រូវបានអនុមត័សំរាប់រៀបចំពាក្យបណ្ដឹង ការត្រួតពិនិត្យឡើងវិញ និង ការធ្វើការសំរេចចិត្ត
- និតិវិធីសំរាប់ធ្វើការផ្សព្វផ្សាយ RAP និង ពត៌មានស្ដីការតាំងទីលំនៅឡើងវិញ ចំពោះសំណង និង ជំរើសនៃការតាំងទីលំនៅឡើងវិញ ទៅកាន់ RAPs នៅក្នុងទំរង់ និង ភាសាមួយដែលពួកគេអាចយល់បាន ។

## ៧. ការបង្កើតការចាត់ចែង

- ការបង្កើត និង ផែនការរដ្ឋបាលសំរាប់ការបណ្ដុះបណ្ដាល និង ការកសាងសមត្ថភាពដូចដែលបានត្រូវការ

## ៨. ការត្រួតពិនិត្យតាមដាន និង គ្រប់គ្រង

- បញ្ជីនៃ សូចនាករ ដែលត្រួតពិនិត្យតាមដានកិច្ចដំនើរការ
- ការទទួលបន្ទុកនៃស្ថាប័ន និង និតិវិធីសំរាប់ការត្រួតពិនិត្យតាមដានគំរោងខាងក្នុង
- ការពិភាក្សាលើតួនាទី( ប្រសិនបើមាន) នៃសហគមន៏ដែលផ្អែកលើ អង្គភាព និង អង្គភាពដែលមិនគិតកំរៃ
- មាតិការ និង ភាពទូទៅនៃរបាយការណ៏ត្រួតពិនិត្យតាមដាន

## ៩. ការប៉ាន់ស្មានលើការចំនាយ និង ថវិការ

- ការប៉ាន់ស្មាននៃការចំណាយសរុបសំរាប់ប្រភេទនីមួយនៃការបាត់បង់ទ្រព្យសម្បត្តិ
- ការចំនាយដែលប៉ាន់ស្មាន សំរាប់កម្មវិធីស្ដារប្រាក់ចំនូលឡើងវិញ សំរាប់ផ្នែករដ្ឋបាល ការគ្រប់គ្រង និង ការត្រួតពិនិត្យតាមដាន
- លិខិតស្ដីពីការទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ សំរាប់ការចំនាយដែលពាក់ពន្ធ័នឹងការរើទីលំនៅទាំងអស់
- យថាភាពសំរាប់ផ្នែកសំភារ និង ថវិការ

## ១០. ការចាត់ចែងលើការអនុវត្តន៏

- កាលវិភាគសំរាប់ការអនុវត្តន៏សំរាប់ការងារតាំងទីលំនៅឡើងវិញទាំងអស់ ដោយភ្ជាប់ជាមួយនឹងកាលវិភាគនៃគំរោងរងទាំងអស់
- និតិវិធីសំរាប់ការអនុវត្តន៏ រឺក៏ការផ្សព្វផ្សាយនៃសមាភាពគន្លឹះ ដែលពាក់ពន្ធ័:

ក. ការត្រួតពិនិត្យឡើងវិញសំរាប់ការចាត់ចែងលើដីធ្លីដែលត្រូវជំនួស ដោយរួមមានកាលវិភាគ និង មូលនិធិសំរាប់ការអភិវឌ្ឍន៏នៃតំបន់ដែលត្រូវរើចេញ និង សេវាសំខាន់ៗ រឺក៏វត្ថុដែលរួមចំណែកដទៃទៀត

ខ. ការត្រួតពិនិត្យឡើងវិញនៃនីតិវិធី សំរាប់ការចំណាយលើសំណង

គ. នីតិវិធីសំរាប់ធ្វើការប៉ាន់ស្មានលើ ភាពសមរម្យសំរាប់សំណង

ឃ. នីតិវិធីនៃកិច្ចដំនើរការសំរាប់ ការរកការងារធ្វើ មីក្រូហិរញ្ញវត្ថុ រឺក៏កម្មវិធីស្តារប្រាក់ចំនូលឡើងវិញ

**ឧបសម្ព័ន្ធ ៦- ពត៌មានដែលត្រូវការសំរាប់ការរៀបចំនៃ IPDP**

- ការស្រង់ចំនួនប្រជាជនជាមូលដ្ឋាន ទិន្នន័យសេដ្ឋកិច្ចសង្គម និង បញ្ជីសារពើភណ្ឌ័នៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់
- កម្មសិទ្ធិផ្ទះសំបែងនៃ ទ្រព្យសម្បត្តិបង្កបង្កើនផល និង ទ្រព្យសម្បត្តិសេដ្ឋកិច្ច
- ប្រាក់ចំនូលប្រចាំឆ្នាំដែលបានមកពី ឱកាសការងារសំខាន់ៗ និង ការងារបន្ទាប់បន្សំ
- ពត៌មានសេដ្ឋកិច្ចរបស់សហគមន៍(ឧ ពត៌មានលំអិតស្តីពីធនធានធម្មជាតិ និង សេដ្ឋកិច្ច ប្រពន្ធ័ផលិតកម្ម និង ការចិញ្ចឹមជីវិត ប្រពន្ធ័ភាពជាម្ចាស់)
- ពត៌មានសង្គមនៃសហគមន៍(ឧ ការណាណិនាពីខ្សែស្រឡាយ ប្រពន្ធ័នៃតំលៃ ប្រភេទនៃអង្គការណ៏សង្គមសំរាប់ក្រុមផ្លូវការ និង ក្រុមមិនផ្លូវការ)
- ផលប៉ះពាល់ធ្ងន់ធ្ងរសំរាប់គំរោងរងដែលបានស្នើស្តីពី សេវាសង្គមជាមូលដ្ឋាន(ឧ ការផ្គត់ផ្គងទឹក សាលារៀន និង មណ្ឌលសុខភាព)
- ផលប៉ះពាល់នៃគំរោងរងស្តីពី ការចិញ្ចឹមជីវិតក្នុងសង្គម និងសេដ្ឋកិច្ច

**ឧបសម្ពន្ធ ៧: ការគាំពារចំបងសំរាប់ប្រជាជនក្នុងស្រុក**

**ពេលវេលាដែលធ្វើការគាំពារ:** នៅពេលនៃការព្រឹក្សាដំបូងជាមួយនឹងភូមិ ឃុំ

**អ្វីជាពតិមានដែលត្រូវប្រមូល:** ការគាំពារនឹងប្រមូលទិន្នន័យប្រជាសាស្ត្ររបស់មនុស្សក្នុងស្រុកដែលរស់នៅក្នុងតំបន់នៃគំរោងរង

**វិធីដើម្បីប្រមូលយកពតិមាន:** វាអាចត្រូវបានយកពីមេកុលសម្ពន្ធ័នៃក្រុមជនជាតិ មេភូមិ និង អាជ្ញាធរឃុំ

**អ្នកដែលនឹងអនុវត្តការគាំពារ:** អ្នកព្រឹក្សា និង បុគ្គលិកស្រុកដែលទទួលបានការបណ្តុះបណ្តាល

**ខេត្តៈ** __________ **ស្រុកៈ** ______________ **ឃុំ/ភូមិ:** ____________

| ឈ្មោះភូមិ ឃុំដែលស្ថិតក្នុងតំបន់នៃគំរោងរង | ឈ្មោះរបស់ប្រជាជនក្នុងស្រុកដែលរស់នៅក្នុងតំបន់នៃគំរោងរង | ចំនួនលំនៅស្ថានរបស់ប្រជាជនក្នុងស្រុក | ចំនួនប្រជាជនក្នុងស្រុកសរុប | |
|---|---|---|---|---|
| | | | ស្ត្រី | បុរស |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |